# អដ្ឋកថា ព្រះសុត្តន្តបិដក

## មនោរថបូរណី

## នវកនិបាត

## ភាគ ៤៩

ពុទ្ធសករាជ ២៥៥៨

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## នវកនិបាត

## ភាគ ៤៩

ពុទ្ធសករាជ ២៥៥៨

អធិប្បាយ

អដ្ឋកនិបាត មាន ១ បណ្ណាសកៈ

មាន ៥ វគ្គ និងវគ្គមិនសង្គ្រោះក្នុងបណ្ណាសកៈ ៥ វគ្គ

រួមមាន ៧៩ សូត្រ ព្រះអដ្ឋកថាកែសេចក្តី ៦៣ សូត្រ

# អង្គុត្តរនិកាយ នវកនិបាត

## រួមមាន

### ១ បណ្ណាសកៈ មាន ៥ វគ្គ និងវគ្គមិនសង្គ្រោះក្នុងបណ្ណាសកៈ ៥ វគ្គ

### សរុបមាន ៧៩ សូត្រ

### ព្រះអដ្ឋកថាកែសេចក្តី ៦៣ សូត្រ

### បឋមបណ្ណាសកៈ

| | | |
|---|---|---|
| ១ សម្ពោធវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |
| ២ សីហនាទវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |
| ៣ សត្តាវាសវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី ១១ សូត្រ |
| ៤ មហាវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |
| ៥ បញ្ចាលវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ១០ សូត្រ |

### វគ្គមិនសង្គ្រោះក្នុងបណ្ណាសកៈ

| | | |
|---|---|---|
| ១ ខេមវគ្គ | មាន ១១ សូត្រ | អដ្ឋកថាកែសេចក្តី ១១ សូត្រ |
| ២ សតិប្បដ្ឋានវគ្គ | មាន ១០ សូត្រ | អដ្ឋកថាកែសេចក្តី ០១ សូត្រ |
| ៣ សម្មប្បធានវគ្គ | មាន ០២ សូត្រ | មិនមានអដ្ឋកថា |
| ៤ ឥទ្ធិបាទវគ្គ | មាន ០២ សូត្រ | មិនមានអដ្ឋកថា |
| ៥ វគ្គទី ៥ | មាន ០៣ សូត្រ | មិនមានអដ្ឋកថា |

# ស្រៈនិងសញ្ញា

# Signes et accents:



# ស្រៈពេញតួ
# *Voyelles.*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឡូម Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ᩋ | ᩋᩣ | ᩍ | ᩎ | ᩏ | ᩐ | ᩑ | ᩒ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

## Consonnes:

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប<br>Romain | k | kh | g | gh | n̉ |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| សង្ហ<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| សឹង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |


ខ្មែរ
Cambodgien
Romain
ṭ
ṭh
ḍ
ḍh
ṇ
សៀម
Siamois
លាវ
Laotien
Cinghalais
ភូមា
Birman

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត | ថ | ទ | ធ | ន |
| [illegible] | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ຕ | ຖ | ທ | ດ | ນ |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| រូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ບ | ຜ | ພ | ຟ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | យ | រ | ល | វ | ស | ហ | ឡ | ំ | ។ |
| រូប Romain | y | r | l | v | s | h | ḷ | ṃ | ./. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| សិង្ហល Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដី នេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបានទូវសេចក្តី*

រីកភាយ និងសួរជាបន្តៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍ សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្ដាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើប ទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុស ក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីល និងទិដ្ឋិ ផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានធន្ទៈ និង ឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្ដីដែល លំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើប សេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះ វិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធ-សាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់

នឹងព្រះត្រៃបិដកពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ

សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់

ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្ញាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬមិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្រប់សង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះ ម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោ-កុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តា អាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែក ចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្សទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរ នេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមាន ច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះពុទ្ធឃោសៈ តែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សា សិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុង ជម្ពូទ្វីបបាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដ ជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាច ឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ

ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារគ្របសង្កត់ហួត សកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទី ពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេច បដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលីយ៉ាង ត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍ នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍ នោះមក ដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុង គម្ពីរត្រៃវេទ ដែលខ្លួននៅមានការសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិ-ធម្មខ្លះៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះ ថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧប-សម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បាន ប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈគង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនា បករណ៍ឈ្មោះ **ញាណោទយ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរ បរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបាន

ឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីបត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសជ្រូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា (សិរិនិវាស) ១ៈ (សិរិកុជៈ) ១ៈ (សិរិកូដ្ឋៈ) ១ៈ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដកជាភាសាមគធ: ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កា ទទួលស្គាល់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះ ឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀត គម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយ ក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចដ៏យ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារ បានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរកោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេ-

ត្តយ្យពោធិសត្វពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរពីភាសាសីហឡ: មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈនិមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធាទឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា

អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនាក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធាន

ហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្លាត ហ៊ន ឧបាសក នាក់ ម៉ៅ

| | |
|---|---|
| ឧបាសក ធុំ ធួន | ឧបាសក ហុក សីង់ហួត |
| ឧបាសក ជីម ជំនិត | ឧបាសក កើត និត្យ |
| ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន |
| ឧបាសក អ៊ុម វ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត |
| ឧបាសក សោម រតនៈ | ឧបាសក សំ ឆាយ |
| ឧបាសក ម៉ៅ ដុន | ឧបាសក ជា ស៊ីថាន |
| ឧបាសិកា ថាប់ លឿម | ឧបាសិកា ហាយ សារ៉ាត់ |
| ឧបាសិកា ប៊ុត សុម៉ាលី | ឧបាសិកា យស សម្បត្តិ |
| ឧបាសិកា ពូ ហ៊ាង | ឧបាសិកា ប៊ុត សេដាដួង |
| ឧបាសិកា ប៉ែន រមណី | |

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គធិន្នោ | នូវ បូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ជុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ជុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុតេជធរោ | ចាវ ចាន | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បី

បូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូន:

–ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| **នវកនិបាត បឋមបណ្ណាសកៈ** | | |
| **សម្ពោធវគ្គ ទី ១** | | |
| អដ្ឋកថា សម្ពោធិសូត្រ | ទី ១ | ១ |
| អដ្ឋកថា និស្សយសូត្រ | ទី ២ | ៥ |
| អដ្ឋកថា មេឃិយសូត្រ | ទី ៣ | ៧ |
| អដ្ឋកថា នន្ទកសូត្រ | ទី ៤ | ១២ |
| អដ្ឋកថា ពលសូត្រ | ទី ៥ | ១៧ |
| អដ្ឋកថា សេវនាសូត្រ | ទី ៦ | ១៩ |
| អដ្ឋកថា សុតវាសូត្រ | ទី ៧ | ២១ |
| អដ្ឋកថា សជ្ឈសូត្រ | ទី ៨ | ២៣ |
| អដ្ឋកថា បុគ្គលសូត្រ | ទី ៩ | ២៤ |
| អដ្ឋកថា អាហុនេយ្យសូត្រ | ទី ១០ | ២៥ |
| **សីហនាទវគ្គ ទី ២** | | |
| អដ្ឋកថា វុដ្ឋសូត្រ | ទី ១ | ២៦ |
| អដ្ឋកថា សឧបាទិសេសសូត្រ | ទី ២ | ៣៤ |
| អដ្ឋកថា កោដ្ឋិតសូត្រ | ទី ៣ | ៣៧ |
| អដ្ឋកថា សមិទ្ធិសូត្រ | ទី ៤ | ៣៩ |
| អដ្ឋកថា គណ្ឌសូត្រ | ទី ៥ | ៤២ |
| អដ្ឋកថា សញ្ញាសូត្រ | ទី ៦ | ៤៥ |
| អដ្ឋកថា កុលសូត្រ | ទី ៧ | ៤៦ |
| អដ្ឋកថា សត្តសូត្រ | ទី ៨ | ៤៨ |
| អដ្ឋកថា ទេវតាសូត្រ | ទី ៩ | ៤៩ |
| អដ្ឋកថា វេលាមសូត្រ | ទី ១០ | ៥០ |

## សត្តាវាសវគ្គ ទី ៣

| | | |
|---|---|---|
| អដ្ឋកថា ឋានសូត្រ | ទី ១ | ៦៨ |
| អដ្ឋកថា ខឡុង្គសូត្រ | ទី ២ | ៧០ |
| អដ្ឋកថា តណ្ហាសូត្រ | ទី ៣ | ៧១ |
| អដ្ឋកថា វវត្តសញ្ញាសូត្រ | ទី ៤ | ៧៥ |
| អដ្ឋកថា បឋមសិលាយូបសូត្រ | ទី ៥ | ៧៦ |
| អដ្ឋកថា ទុតិយសិលាយូបសូត្រ | ទី ៦ | ៧៧ |
| អដ្ឋកថា បឋមជវសូត្រ | ទី ៧ | ៧៩ |
| អដ្ឋកថា ទុតិយជវសូត្រ | ទី ៨ | ៨០ |
| អដ្ឋកថា បឋមអាឃាតសូត្រ | ទី ៩ | ៨១ |
| អដ្ឋកថា ទុតិយអាឃាតសូត្រ | ទី ១០ | ៨២ |
| អដ្ឋកថា អនុបុព្វនិរោធសូត្រ | ទី ១១ | ៨៤ |

## មហាវគ្គ ទី ៤

| | | |
|---|---|---|
| អដ្ឋកថា បឋមវិហារសូត្រ | ទី ១ | ៨៥ |
| អដ្ឋកថា ទុតិយវិហារសូត្រ | ទី ២ | ៨៦ |
| អដ្ឋកថា និព្វានសូត្រ | ទី ៣ | ៨៨ |
| អដ្ឋកថា គាវីសូត្រ | ទី ៤ | ៨៩ |
| អដ្ឋកថា ឈានសូត្រ | ទី ៥ | ៩១ |
| អដ្ឋកថា អានន្ទសូត្រ | ទី ៦ | ៩៨ |
| អដ្ឋកថា ព្រាហ្មណសូត្រ | ទី ៧ | ១០៣ |
| អដ្ឋកថា ទេវសូត្រ | ទី ៨ | ១០៦ |
| អដ្ឋកថា នាគសូត្រ | ទី ៩ | ១០៩ |
| អដ្ឋកថា តបុស្សសូត្រ | ទី ១០ | ១១១ |

## បញ្ចាលវគ្គ ទី ៥

| | | |
|---|---|---|
| អដ្ឋកថា បញ្ចាលសូត្រ | ទី ១ | ១១៥ |
| អដ្ឋកថា កាយសក្ខិសូត្រ | ទី ២ | ១១៧ |
| អដ្ឋកថា បញ្ញាវិមុត្តសូត្រ | ទី ៣ | ១១៩ |
| អដ្ឋកថា ឧភតោភាគវិមុត្តសូត្រ | ទី ៤ | ១២០ |

| | | |
|---|---|---|
| អដ្ឋកថា បឋមសន្ធិដ្ឋិកសូត្រ | ទី ៥ | អដ្ឋកថាកែរូម ១២៧ |
| អដ្ឋកថា ទុតិយសន្ធិដ្ឋិកសូត្រ | ទី ៦ | |
| អដ្ឋកថា និព្វានសូត្រ | ទី ៧ | |
| អដ្ឋកថា បរិនិព្វានសូត្រ | ទី ៨ | |
| អដ្ឋកថា តទង្គសូត្រ | ទី ៩ | |
| អដ្ឋកថា ទិដ្ឋធម្មិកសូត្រ | ទី ១០ | |


# វគ្គមិនសង្គ្រោះក្នុងបណ្ណាសកះ

## ខេមវគ្គ ទី ១


| | | |
|---|---|---|
| អដ្ឋកថា ខេមសូត្រ | ទី ១ | អដ្ឋកថាកែរូម ១២៨ |
| អដ្ឋកថា ខេមបត្តសូត្រ | ទី ២ | |
| អដ្ឋកថា អមតសូត្រ | ទី ៣ | |
| អដ្ឋកថា អមតបត្តសូត្រ | ទី ៤ | |
| អដ្ឋកថា អភយសូត្រ | ទី ៥ | |
| អដ្ឋកថា អភយបត្តសូត្រ | ទី ៦ | |
| អដ្ឋកថា បស្សទ្ធិសូត្រ | ទី ៧ | |
| អដ្ឋកថា អនុបុព្វបស្សទ្ធិសូត្រ | ទី ៨ | |
| អដ្ឋកថា និរោធសូត្រ | ទី ៩ | |
| អដ្ឋកថា អនុបុព្វនិរោធសូត្រ | ទី ១០ | |
| អដ្ឋកថា ធម្មបហាយភព្វសូត្រ | ទី ១១ | |


## សតិប្បដ្ឋានវគ្គ ទី ២


| | | |
|---|---|---|
| អដ្ឋកថា សិក្ខាសូត្រ | ទី ១ | ១២៩ |
| អដ្ឋកថា នីវរណាសូត្រ | ទី ២ | មិនមានអដ្ឋកថា |
| អដ្ឋកថា កាមគុណាសូត្រ | ទី ៣ | |
| អដ្ឋកថា ឧបាទានក្ខន្ធសូត្រ | ទី ៤ | |
| អដ្ឋកថា ឱរម្ភាគិយសូត្រ | ទី ៥ | |
| អដ្ឋកថា គតិសូត្រ | ទី ៦ | |

| | | |
|---|---|---|
| អដ្ឋកថា មច្ឆរិយសូត្រ | ទី ៧ | មិនមានអដ្ឋកថា |
| អដ្ឋកថា ឧទុម្ភាគិយសូត្រ | ទី ៨ | |
| អដ្ឋកថា ចេតោខីលសូត្រ | ទី ៩ | |
| អដ្ឋកថា វិនិពន្ធសូត្រ | ទី ១០ | |

| | | |
|---|---|---|
| **សម្មប្បធានវគ្គ ទី ៣** | | មិនមានអដ្ឋកថា |
| **ឥទ្ធបាទវគ្គ ទី ៤** | | |
| **វគ្គ ទី ៥** | | |

# អង្គុត្តរនិកាយនវកនិបាត

## បឋមបណ្ណាសកៈ

## សម្ពោធវគ្គវណ្ណនាទី ១

## អដ្ឋកថា សម្ពោធិសូត្រទី ១

### *ហេតុចម្រើននៃពោធិបក្ខិយធម៌*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សម្ពោធិសូត្រទី ១ ដូចតទៅនេះ ៖*

[១] *បទថា* ***សម្ពោធិបក្ខិកានំ*** *(ដែលជាចំណែកនៃធម៌ជាគ្រឿងត្រាស់ដឹង) បានដល់ ចម្រើនក្នុងចំណែកនៃធម៌ជាគ្រឿងត្រាស់ដឹង ពោលគឺ មគ្គ ៤ អធិប្បាយថា ជាឧបការៈ ។ ព្រះមានព្រះភាគ រមែងត្រាស់សួរដល់ធម៌ ៩ ប្រការ ដែលមកហើយក្នុងបាលី ។ បទថា* ***កា ឧបនិសា*** *(អ្វីជាហេតុ) បានដល់ អ្វីជាហេតុ គឺ ជាបច្ច័យ ។ កថាពោលថា* ***អភិសល្លេខិកា*** *(ដែលប្រព្រឹត្តទៅដើម្បីជុសខាត់កិលេស) ព្រោះអត្ថថា រមែងជុសខាត់កិលេស ។ ឈ្មោះថា* ***ចេតោវិវរណសប្បាយា*** *(ជាទីសប្បាយក្នុង*

**ការបើកចិត្ត** ព្រោះអត្ថថា ជាទីសប្បាយ និងជាឧបការៈក្នុងការបើកចិត្ត ដោយសមថៈ និងវិបស្សនា ។ ពាក្យដែលប្រព្រឹត្តទៅប្រារព្ធដល់សេចក្តីប្រាថ្នាតិច ឈ្មោះថា **អប្បិច្ឆកថា** សូម្បីក្នុងពាក្យដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **អសុភា ភាវេតព្វា រាគស្ស បហានាយ (គប្បីចម្រើនអសុភៈ ដើម្បីលះរាគៈ)** គប្បីជ្រាបបទឧបមាដោយការច្រូតស្រូវសាលី ។ ពិតហើយ បុរសម្នាក់កាន់កណ្តៀវច្រូតស្រូវសាលីក្នុងស្រែស្រូវសាលី តាំងអំពីចុងស្រែ ។ ពេលនោះ ហ្វូងគោទាំងឡាយទម្លាយរបងស្រែស្រូវសាលីនោះ ហើយចូលទៅ ។ បុរសនោះដាក់កណ្តៀវចុះ ហើយកាន់យកឈើហើយដេញគោឲ្យត្រឡប់ទៅកាន់ទីដើមនោះឯង ហើយជួសជុលរបងឲ្យដូចដើមវិញ កាន់យកកណ្តៀវច្រូតស្រូវតទៅទៀត ។ ក្នុងការឧបមានោះ គប្បីឃើញពាក្យទូន្មានរបស់ព្រះមានព្រះភាគ ដូចជាស្រែស្រូវសាលី ព្រះយោគាវចរដូចបុរសច្រូតស្រូវសាលី បញ្ញាដូចកណ្តៀវ វេលាញុំាងវិបស្សនាឲ្យកើតឡើង ដូចវេលាដែលច្រូតស្រូវ អសុភកម្មដ្ឋានដូចមែកឈើ ការ

សន្ទ្រមដូចជារបង ការកើតឡើងនៃរាគៈព្រោះសេចក្ដីប្រមាទ ដោយមិនពិចារណាឲ្យរហ័ស ដូចហ្វូងគោទម្លាយរបងហើយចូលទៅ វេលាដែលគ្របសង្កត់រាគៈទុកបានដោយអសុភកម្មដ្ឋាន ហើយផ្ដើមវិបស្សនាទៀត ដូចជាការដាក់កណ្ដៀវចុះ កាន់យកមែកឈើដេញគោឲ្យត្រឡប់ចេញទៅតាមផ្លូវដែលវាចូលមកនោះឯង ជួសជុលរបងឲ្យដូចដើមវិញ ទើបប្រូតស្រូវសាលីតាំងអំពីចុងស្រែតទៅទៀត ។ ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីនេះទើបត្រាស់ថា **គប្បីចម្រើនអសុភៈដើម្បីលះរាគៈ** ។ ក្នុងបទទាំងនោះ បទថា **រាគស្ស (រាគៈ)** បានដល់ រាគៈប្រកបដោយបញ្ចកាមគុណ ។

មេត្តាកម្មដ្ឋាន ដែលបុគ្គលគប្បីចម្រើនដើម្បីលះសេចក្ដីក្រោធ ដែលកើតឡើងដោយន័យដែលត្រាស់ថា **ព្យាបាទស្ស បហានាយ (ដើម្បីលះព្យាបាទ)** ។ បទថា **អានាបានស្សតិ** បានដល់ អានាបានស្សតិ (សតិកំណត់ដង្ហើមចេញចូល) មានអារម្មណ៍ ១៦ ។ បទថា **វិតក្កុបច្ឆេទាយ (ដើម្បីកាត់វិតក្កៈ)** បានដល់ ដើម្បីចូលទៅកាត់វិតក្កៈទាំងឡាយដែលកើតឡើង ដូចន័យដែលពោលហើយនោះឯង ។ បទថា **អស្មិមានសមុគ្ឃាតាយ**

(ដើម្បីដកចេញនូវអស្មិមានះ) បានដល់ ដើម្បីដកមានះ ៩ យ៉ាង ដែលកើតឡើងថា យើងដូច្នេះ ។ បទថា **អនត្តសញ្ញា សណ្ឋាតិ** (អនត្តសញ្ញារមែងប្រាកដ) បានដល់ កាលបុគ្គលឃើញអនិច្ចលក្ខណៈហើយ អនត្តលក្ខណៈក៏ឈ្មោះថា បានឃើញដូចគ្នា ព្រោះថា ក្នុងលក្ខណៈបីទាំងនោះ កាលឃើញលក្ខណៈមួយហើយ លក្ខណៈពីរក្រៅពីនេះក៏បានឃើញដូចគ្នា ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **អនិច្ចសញ្ញិនោ ភិក្ខវេ អនត្តសញ្ញា សណ្ឋាតិ** (អនត្តសញ្ញារមែងប្រាកដដល់ភិក្ខុអ្នកបានអនិច្ចសញ្ញា) ។ បទថា **ទិដ្ឋេវ ធម្មេ និព្វានំ** (និព្វាន... ក្នុងបច្ចុប្បន្នតែម្យ៉ាង) បានដល់ បុគ្គលដែលបានអនត្តសញ្ញា រមែងដល់ព្រះនិព្វានដែលមិនមានបច្ច័យក្នុងបច្ចុប្បន្ននោះឯង ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទុកទាំងវដ្តៈ និងវិវដ្តៈ ។

ចប់អដ្ឋកថា សម្ពោធសូត្រទី ១

# អដ្ឋកថា និស្សយសូត្រទី ២

## និស្ស័យ និងឧបនិស្ស័យ

*គប្បីជ្រាបវិនិច្ឆ័យក្នុង និស្សយសូត្រទី ១ ដូចតទៅនេះ ៖*

*[២] បទថា **និស្សយសម្បន្នោ** (អ្នកដល់ព្រមដោយទីអាស្រ័យ) បានដល់ អ្នកដល់ព្រមដោយទីពឹង ។ បទថា **សទ្ធំ**[១] (សទ្ធា) បានដល់ សទ្ធាតាំងមាំ ។ បទថា **វីរិយំ** (វីរិយៈ) បានដល់ សេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **សយា** កាត់បទជា **យំ អស្ស** (ភិក្ខុ... អកុសលណា) ។ បទថា **អរិយាយ បញ្ញាយ** (ដោយបញ្ញាដែលជាអរិយៈ) បានដល់ មគ្គបញ្ញាព្រមទាំងវិបស្សនា ។ បទថា **សង្ខាយ** (ពិចារណាហើយ) បានដល់ ដឹងហើយ ។ បទថា **ឯកំ បដិសេវតិ** (សេពរបស់ណាមួយ) បានដល់ រមែងសេពរបស់ដែលគួរសេព ។ បទថា **អធិវាសេតិ** (អត់ធន់) បានដល់ រមែងអត់ធន់ក្នុងរបស់ដែលគួរអត់ធន់ ។ បទថា **បរិវជ្ជេតិ** (វៀរ) បានដល់ រមែងវៀររបស់ដែលគួរវៀរ ។ បទថា **វិនោទេតិ** (បន្ទោបង់ចោល) បានដល់ រមែងនាំចេញនូវរបស់ដែលគួរនាំ*

*ចេញ ។ បទថា ឯវំ ខោ ភិក្ខុ (ដោយហេតុយ៉ាងនេះឯង ភិក្ខុ) បានដល់ ដោយហេតុយ៉ាងនេះឯង ភិក្ខុកាលធ្វើសេចក្តីចូលចិត្តក្នុងវត្ថុដែលនឹងគប្បី សេព រហូតកាល ឲ្យប្រចក្សច្បាស់ដោយល្អ ដោយអំណាចការរៀន និង ការសាកសួរ និងដោយអំណាចការកំណត់ធម៌ហើយ ទើបសេព អត់ធន់ វៀរ និងបន្ទោបង់ រមែងឈ្មោះថា ជាអ្នកដល់ព្រមដោយទីពឹង ។*

ចប់អដ្ឋកថា និស្សយសូត្រទី ២

# អដ្ឋកថា មេឃិយសូត្រទី ៣

## *អកុសលវិតក្កៈគ្របសង្កត់ព្រះមេឃិយៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង មេឃិយសូត្រទី ៣ ដូចតទៅនេះ ៖*

[៣] *បទថា* ***ចាលិកាយំ (ជិតក្រុងចាលិកា)*** *បានដល់ ក្នុងក្រុងដែលមានឈ្មោះយ៉ាងនោះ ។ ន័យថា ក្រុងនោះ រមែងប្រាកដនៅឆ្ងាយដល់បុគ្គលអ្នកក្រឡេកមើល ព្រោះគេបានអាស្រ័យដីដែលសាងទុកហើយ ព្រោះដូច្នោះ ទើបហៅថា ក្រុងចាលិកា ។ បទថា* ***ចាលិកាបព្វតេ (ភ្នំចាលិក)*** *បានដល់ ភ្នំនោះ រមែងប្រាកដនៅឆ្ងាយដល់បុគ្គលដែលកំពុងក្រឡេកមើលក្នុងថ្ងៃឧបោសថខាងខ្នើត ព្រោះសសុទ្ធ ព្រោះហេតុនោះ ទើបហៅថា ចាលិកបព៌ត ។ បុគ្គលទាំងឡាយឲ្យសាងវិហារធំទុកខាងលើភ្នំចាលិយនោះ ។ ព្រះមានព្រះភាគទ្រង់អាស្រ័យក្រុងនោះ ប្រថាប់នៅទីនំភ្នំចាលិយមហាវិហារ ដោយប្រការដូច្នេះ ។ បទថា* ***ជត្តុគ្គាមំ (ជន្តុគាម)*** *បានដល់ ជាពួកអ្នកស្រុកដទៃទៀត ដែលមានឈ្មោះយ៉ាងនេះ ជាគោចរនៃវិហារនោះឯង ។ លោកពោលថា* ***ជន្តុគាមំ*** *ដូច្នេះក៏មាន ។*

បទថា **បធានត្ថិកស្ស** (អ្នកត្រូវការបំពេញសេចក្តីព្យាយាម) បានដល់ អ្នកធ្វើសេចក្តីព្យាយាម ។ បទថា **បធានាយ** (ដើម្បីបំពេញសេចក្តីព្យាយាម) បានដល់ ដើម្បីធ្វើសមណធម៌ ។ បទថា **អាគមេហិ តាវ** (អ្នកចូររង់ចាំមុន) បានដល់ ព្រះសាស្តាស្តាប់ពាក្យរបស់ព្រះថេរៈហើយ ទ្រង់ត្រិះរិះ ទ្រង់ដឹងថា ញាណរបស់ព្រះថេរៈនោះនៅមិនទាន់ចាស់ក្លា ទើបបានត្រាស់ហាមយ៉ាងនេះ ។ ចំណែកបទនេះថា **ឯកកម្ហិ តាវ** (ដ្បិតតថាគតនៅតែម្នាក់ឯង) ព្រះមានព្រះភាគបានត្រាស់ដល់មេឃិយៈនោះ ដើម្បីឲ្យកើតចិត្តទន់ ដោយទ្រង់ត្រិះរិះថា ព្រះមេឃិយៈនេះ សូម្បីទៅហើយយ៉ាងនេះ កាលកម្មដ្ឋាននៅមិនទាន់សម្រេច អស់សេចក្តីសង្ស័យ នឹងត្រឡប់មកវិញដោយអំណាចសេចក្តីស្រឡាញ់ ។ បទថា **នត្ថិ កិញ្ចិ ឧត្តរឹ ករណីយំ** (មិនមានកិច្ចអ្វីដែលនឹងធ្វើឲ្យក្រៃលែង) បានដល់ ឈ្មោះថា កិច្ចដែលគប្បីធ្វើឲ្យក្រៃលែងដទៃ រមែងមិនមាន ព្រោះព្រះអង្គទ្រង់ធ្វើកិច្ច ៤ ក្នុងសច្ចៈ ៤ សម្រេចហើយ ។ បទថា **កតស្ស វា បដិចយោ** (ការសន្សំកិច្ចដែលធ្វើហើយ) បានដល់ រមែងមិនមានការសន្សំអរិយមគ្គ ដែលទ្រង់ធ្វើហើយ

ទៀត ក៏មគ្គដែលទ្រង់ចម្រើនហើយ ព្រះអង្គក៏ទ្រង់មិនចម្រើនទៀត កិលេសដែលទ្រង់លះបានហើយ មិនមានការលះទៀត ។ បទថា **បក្កមន្តិ ខោ មេឃិយ វទមានំ កិន្តិ** (តថាគតនឹងគប្បីពោលអ្វីបានចំពោះអ្នកដែលពោលថា) បានដល់ តថាគតនឹងគប្បីពោលដល់អ្វីដទៃហ្ន៎ចំពោះអ្នក ដែលពោលថា តថាគតនឹងធ្វើសមណធម៌ ។

បទថា **ទិវាវិហារំ និសីទិ** (អង្គុយសម្រាកក្នុងវេលាថ្ងៃ) បានដល់អង្គុយដើម្បីត្រូវការសម្រាកក្នុងវេលាថ្ងៃ ។ ព្រះមេឃិយៈជាព្រះរាជាមករហូត ៥០០ ជាតិជាប់គ្នាតាមលំដាប់ក្នុងកាលមុន កាលលេងក្នុងឧទ្យានមានអ្នករាំច្រៀង ៣ ពួក ជាបរិវារ អង្គុយហើយលើផែនសិលាដែលជាមង្គលណា ព្រះមេឃិយៈគ្រានោះឯង ក៏អង្គុយលើផែនសិលានោះឯង ។ ពេលនោះ តាំងពីវេលាដែលលោកអង្គុយហើយ ភាពជាសមណៈដូចជាវិនាសទៅ ។ លោកដូចជាបុគ្គលកាន់យកភេទជាព្រះរាជា មានអ្នកស្រីរបាំរាំច្រៀងព័ទ្ធជុំវិញហើយ ប្រថាប់អង្គុយលើបល្ល័ង្កដែលមានតំលៃខាងក្រោមស្វេតឆត្រ ។ ទីនោះ កាលលោកត្រេកអរក្នុងសម្បត្តិនោះ កាមវិតក្កៈ ក៏

កើតឡើង ។ ក្នុងខណៈនោះឯង លោកបានឃើញមហាចោរដែលត្រូវគេចាប់បាន ដូចជាឃើញចំពោះមុខនូវចោរ ២ នាក់ត្រូវនាំមកទុកខាងមុខ ។ ព្យាបាទវិតក្កៈរមែងកើតឡើងដល់លោក ដោយអំណាចការបញ្ជាឲ្យសម្លាប់ចោរម្នាក់ក្នុងបណ្តាលចោរទាំងនោះ វិហឹង្សាវិតក្កៈ រមែងកើតឡើងដោយអំណាចការបញ្ចេញពាក្យបញ្ជាថា ចូរចងចោរម្នាក់ទៀត ។ ព្រះមេឃិយៈនោះ ត្រូវអកុសលវិតក្កៈលោមព័ទ្ធហើយ ទើបបានដូចជាដើមឈើដែលត្រូវពួកវល្លិ៍គ្របសង្កត់រួបរឹតទុក និងដូចជាមនុស្សរវាយឃ្មុំ ត្រូវសត្វឃ្មុំចោមរោម ដូច្នេះ ។ ព្រះធម្មសង្គាហកាចារ្យសំដៅដល់ប្រការនោះ ទើបពោលពាក្យជាដើមថា **អថខោ អាយស្មតោ មេឃិយស្ស** (គ្រានោះឯង កាលព្រះមេឃិយៈ) បានដល់ ជាអ្នកត្រូវអកុសលវិតក្កៈជាប់តាម រួបរឹតហើយ ។ បទថា **យេន ភគវា តេនុបសង្កមិ** (ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់) សេចក្តីថា ព្រះមេឃិយៈ លំបាកហើយដោយអកុសលធម៌ដ៏លាមកយ៉ាងនេះ មិនអាចនឹងធ្វើកម្មដ្ឋានឲ្យជាទីសប្បាយបាន ទើបកំណត់ថា ព្រះមានព្រះភាគទ្រង់មានក្រសែព្រះនេត្រឆ្ងាយ ទ្រង់ឃើញហេតុនេះហ្ន៎

ទើបទ្រង់ហាម គិតថា យើងនឹងក្រាបទូលហេតុនេះចំពោះព្រះទសពល ទើបក្រោកចាកអាសនៈដែលអង្គុយហើយ ចូលទៅគាល់ព្រះមានព្រះភាគ ដល់ទីប្រថាប់ ។

ចប់អដ្ឋកថា មេឃិយសូត្រទី ៣

# អដ្ឋកថា នន្ទកសូត្រទី ៤

## ទ្រង់សំដែងព្រហ្មចារ្យដោយសន្សេបដល់ព្រះនន្ទកៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង នន្ទកសូត្រទី ៤ ដូចតទៅនេះ ៖

[៤] បទថា **ឧបដ្ឋានសាលាយំ** (ឧបដ្ឋានសាលា) បានដល់ សាលាឆាន់ ។ បទថា **យេនុបដ្ឋានសាលា** (ទៅកាន់ឧបដ្ឋានសាលា) សេចក្តីថា ព្រះសាស្តាស្តាប់ការសំដែងធម៌ដែលព្រះនន្ទកត្ថេរៈផ្តើមហើយ ដោយសំឡេងដ៏ពីរោះ ទើបត្រាស់សួរថា នោះនន្ទកៈសំដែងធម៌ដោយបទដ៏ពីរោះក្នុងឧបដ្ឋានសាលាឬ ។ ទ្រង់ស្តាប់ថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃនេះ ជាវារៈរបស់ព្រះនន្ទកត្ថេរៈដែលជាធម្មកថិក ។ បានត្រាស់ថា អានន្ទ ភិក្ខុនោះសំដែងធម៌ពីរោះណាស់ហ្ន៎ សូម្បីតថាគតនឹងទៅស្តាប់ ទើបស្តេចចូលទៅកាន់ឧបដ្ឋានសាលា ។ បទថា **ឧបសង្កមិត្វា ពហិទ្វារកោដ្ឋកេ អដ្ឋាសិ** (ប្រថាប់នៅទៀបខ្លោងទ្វារខាងក្រៅ) បានដល់ ទ្រង់បិទបាំងឆព្វណ្ណរង្សីទុកក្នុងចីវរហើយ ប្រថាប់ឈរដោយភេទជាមនុស្សមិនស្គាល់ ។ បទថា **កថា-បរិយោសានំ អាគមយមានោ** (រង់ចាំរហូតចប់កថា) បានដល់ ប្រថាប់ឈរ

ស្ដាប់ធម្មកថារហូតដល់កថាចុងក្រោយនេះថា **ឥទមវោច** ដូច្នេះ ។ គ្រានោះ ព្រះអានន្ទ បានទូលថ្វាយសញ្ញាដល់ព្រះសាស្ដា កាលកន្លងបឋម-យាមហើយថា បពិត្រព្រះអង្គដ៏ចម្រើន បឋមយាមកន្លងទៅហើយ ព្រះអង្គទ្រង់សម្រាកបន្តិចចុះ ព្រះមានព្រះភាគក៏ទ្រង់ប្រថាប់ឈរនៅទីនោះឯង ។ លុះតមក កាលកន្លងមជ្ឈិមយាមទៅហើយ ព្រះអានន្ទបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គជាខត្តិយសុខុមាលជាតិដោយប្រក្រតី ទ្រង់ជាពុទ្ធសុខុមាលជាតិ ទ្រង់ជាសុខុមាលជាតិយ៉ាងក្រៃលែង សូម្បីមជ្ឈិមយាមក៏កន្លងទៅហើយ សូមទ្រង់សម្រាកបន្តិចសិនចុះព្រះអង្គ ព្រះសាស្ដាក៏ទ្រង់ប្រថាប់ឈរនៅក្នុងទីនោះឯង ។ ពន្លឺអរុណប្រាកដហើយដល់ព្រះសាស្ដាព្រះអង្គនោះ ដែលទ្រង់ប្រថាប់ឈរនៅក្នុងទីនោះឯង ។ អរុណរះឡើងក្ដី ការបញ្ចប់កថា ដល់ពាក្យថា **ឥទមវោច** របស់ព្រះនន្ទកក្ដី ការបញ្ចេញធញ្ញាណរង្សីរបស់ព្រះទសពលក្ដី ក៏មានក្នុងគ្រាតែមួយនោះឯង ។ បទថា **អគ្គលំ អាកោដេសិ** (ក៏គ្រហែមហើយគោះសន្ទះទ្វារ) បានដល់ ទ្រង់យកចុងព្រះនខគោះសន្ទះទ្វារ ។

បទថា **សារជ្ជមានរូបោ** (ជីងត្រឹមតែរសោប់រសល់) បានដល់លំបាកចិត្ត កោតក្រែង រង្កៀសខ្លាច ។ តែព្រះនន្ទកត្ថេរៈនោះ មិនមានសេចក្ដីរសោប់រសល់ដោយទោមនស្ស ។ បទថា **ឯត្តកំបិ នោ នប្បដិភាសេយ្យ** (ខ្ញុំព្រះអង្គទាំងឡាយក៏នឹងមិនពោលពាក្យសូម្បីប៉ុណ្ណោះ) បានដល់បុគ្គលបានបដិសម្ភិទាឈ្មោះថា អស់បដិភាណ រមែងមិនមាន ។ តែព្រះនន្ទកៈសំដែងថា យើងមិនគប្បីពោលពាក្យប្រមាណប៉ុណ្ណោះ ។ បទថា **សាធុ សាធុ** (ល្អហើយៗ) បានដល់ ទ្រង់ត្រាស់សរសើរដល់ការសំដែងធម៌របស់ព្រះថេរៈ ។ ក៏ក្នុងប្រការនេះ មានសេចក្ដីដូច្នេះថា ធម្មទេសនាលោកកាន់យកសេចក្ដីបានល្អ ហើយសំដែងបានល្អ ។ បទថា **កុលបុត្តានំ** (កុលបុត្រ) បានដល់ កុលបុត្រអ្នកមានមារយាទ និងកុលបុត្រមានជាតិត្រកូល ។ បទថា **អរិយោ វា តុណ្ហីភាវោ** (គប្បីស្ងៀមដោយភាពជាព្រះអរិយៈ) បានដល់ ត្រាស់សំដៅយកសមាបត្តិក្នុងទុតិយជ្ឈានប៉ុណ្ណោះ ។

បទថា **អធិប្បញ្ញាធម្មវិបស្សនាយ** (ការឃើញច្បាស់នូវធម៌ដោយបញ្ញាដ៏ក្រៃលែង) បានដល់ វិបស្សនាញាណកំណត់សង្ខារ ។ បទថា

ចតុប្បាទកោ (ឬជើង ៤) បានដល់ ប្រៀបដូចសត្វចតុប្បាទ មានសេះគោ និងលាជាដើម ។ បទថា **ឥទំ វត្វា (គ្រាត្រាស់)** បានដល់ ត្រាស់ធម៌នេះប្រកបដោយអង្គ ៤ ។ បទថា **វិហារំ បាវិសិ (ចូលទៅកាន់វិហារ)** បានដល់ ស្តេចចូលទៅកាន់ព្រះគន្ធកុដិ ។

បទថា **កាលេន ធម្មស្សវនេ (ការស្តាប់ធម៌តាមកាល)** បានដល់ ក្នុងការស្តាប់ធម៌តាមកាលដែលសមគួរ ។ បទថា **ធម្មសាកច្ឆាយ (ក្នុងការសន្ទនាធម៌)** បានដល់ ក្នុងការសាកសួរគ្នា ។ បទថា **គម្ភីរំ បញ្ញាយ (នូវបទនៃអត្ថដ៏ជ្រាលជ្រៅ)** បានដល់ អត្ថដ៏ជ្រាលជ្រៅ គឺ កំបាំង ល្អិត ។ បទថា **បញ្ញាយ (ដោយបញ្ញា)** បានដល់ មគ្គបញ្ញាព្រមដោយវិបស្សនា ។ បញ្ញាដែលដឹង ដែលចាក់ធ្លុះដោយការពិចារណាក្តី បញ្ញាដែលកើតអំពីការរៀន និងការសាកសួរក្តី រមែងគួរទាំងអស់ ។ បទថា **បត្តោ វា គច្ឆតិ វា (សម្រេចហើយ ឬកំពុងសម្រេច)** បានដល់ គេរមែងសរសើរដោយការសរសើរគុណយ៉ាងនេះថា បុគ្គលនេះសម្រេចហើយឬ នឹងសម្រេចអរហត្ត ។ ក្នុងបទថា **អប្បត្តមានសា (នៅមិនទាន់សម្រេចអរហត្ត)** ឈ្មោះ

ថា នូវមិនទាន់សម្រេចអរហត្ត ព្រោះអត្ថថា នៅមិនទាន់សម្រេចអរហត្ត ឬពួកភិក្ខុទាំងនោះ មានចិត្តមិនទាន់សម្រេចអរហត្តដូច្នេះ ក៏មាន ។ ក្នុងពាក្យថា ទិដ្ឋធម្មសុខវិហារំ (ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន) នេះ ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ទាំងជាលោកិយៈ ទាំងជាលោកុត្តរៈ ។

ចប់អដ្ឋកថា ឆន្ទកសូត្រទី ៤

# អដ្ឋកថា ពលសូត្រទី ៥

## កម្លាំង ៤ និងភ័យ ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង ពលសូត្រទី ៥ ដូចតទៅនេះ ៖

[៥] គប្បីឃើញកម្លាំង គឺ បញ្ញាជាដើម ព្រោះមិនញាប់ញ័រដោយអវិជ្ជា សេចក្តីខ្ជិលច្រអូស ការងារដែលមានទោស និងការមិនជឿ ។ បទថា **អកុសលសង្ខាតា (រាប់ថាជាអកុសល)** បានដល់ ដឹងថា ជាអកុសល ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា **នាលមរិយា (មិនអាចធ្វើភាពជាអរិយៈ)** បានដល់ ធម៌ដែលមិនអាចធ្វើឲ្យជាព្រះអរិយៈ ឬមិនសមគួរដល់ព្រះអរិយៈ ។ បទថា **វោទិដ្ឋា (ឃើញច្បាស់)** បានដល់ ដែលឃើញហើយដោយល្អ ។ បទថា **វោចរិតា (ពិចារណាបាន)** បានដល់ ដែលដល់សេចក្តីស្ទុះទៅក្នុងមនោទ្វារ ។ បទថា **អត្ថិកស្ស (ដល់បុគ្គលដែលត្រូវការ)** បានដល់ អ្នកត្រូវការធម្មទេសនា ។ បទថា **អាជីវិតភយំ (ភ័យដែលជាប់ដោយការចិញ្ចឹមជីវិត)** បានដល់ ភ័យដែលប្រព្រឹត្តទៅក្នុងជីវិត ។ បទថា **អសិលោកភយំ (ភ័យ គឺ ការតិះដៀល)** បានដល់ ភ័យ

*អំពីការតិះដៀល ។ បទថា **បរិសសារជ្ជភយំ** (ភ័យ គឺ សេចក្តីភ័យក្នុងបរិស័ទ) បានដល់ ភ័យដែលបុគ្គលចូលកាន់ប្រជុំជនហើយ កើតការភ័យខ្លាច ។ ក្នុងសូត្រនេះត្រាស់ទាំងវដ្តៈ និងវិវដ្តៈ ។*

ចប់អដ្ឋកថា ពលសូត្រទី ៥

# អដ្ឋកថា សេវនាសូត្រទី ៦

## វត្ថុដែលគួរសេព និងមិនគួរសេព

*គប្បីជ្រាបវិនិច្ឆ័យក្នុង សេវនាសូត្រទី ៦ ដូចតទៅនេះ ៖*

*[៦] បទថា **ជីវិតបរិក្ខារា (បរិក្ខារនៃជីវិត)** បានដល់ វត្ថុចម្រើនដល់ជីវិត ។ បទថា **សមុទានេតព្វា (គប្បីរួបរួមទុក)** បានដល់ បព្វជិតគប្បីរក្សារួបរួមទុក ។ បទថា **កសិរេន សមុទាគច្ឆន្តិ (រមែងកើតឡើងបានដោយលំបាក)** បានដល់ រមែងកើតឡើងដោយសេចក្ដីលំបាក ។ បទថា **រត្តិភាគំ វា ទិវសភាគំ វា (ក្នុងកណ្ដាលយប់ ឬកណ្ដាលថ្ងៃ)** នេះ បុគ្គលនោះដឹងក្នុងកណ្ដាលយប់ គប្បីចៀសចេញទៅក្នុងកណ្ដាលយប់ កាលអន្តរាយ មានសត្វសាហាវជាដើមមាននៅក្នុងកណ្ដាលយប់ គប្បីរង់ចាំដល់ព្រះអាទិត្យរះឡើង , ដឹងក្នុងវេលាថ្ងៃ គប្បីចៀសចេញទៅក្នុងវេលាថ្ងៃ កាលអន្តរាយមានក្នុងវេលាថ្ងៃ គប្បីរង់ចាំដល់ព្រះអាទិត្យលិច ។ បទថា **សង្ខាបិ (គ្រាដឹងហើយ)** បានដល់ ដឹងហេតុនៃសេចក្ដីចម្រើនបរិបូណ៌នៃភាពជាសមណៈ ។ ចំណែកបទថា **សោ បុគ្គលោ (បុគ្គលនោះ)** គប្បី*

ភ្ជាប់ជាមួយពាក្យនេះថា **នានុពន្ធិតព្វោ** (មិនគប្បីជាប់តាម... ទៅ) ក៏ក្នុងបទថា **អនាបុច្ឆា** (ដោយមិនត្រូវលា) មានអធិប្បាយថា គប្បីចៀសចេញទៅ មិនត្រូវលាបុគ្គលនោះ ។ បទថា **អបិ បនុជ្ជមានេន** (សូម្បីត្រូវបណ្តេញចេញ) បានដល់ សូម្បីត្រូវចៀសចេញទៅ ។ ក៏បុគ្គលបែបនេះដាក់ទោសឲ្យយកខ្សែចងអុសមួយរយបាច់ ធ្នាំងទឹកមួយរយ ឬធ្នាំងដីខ្សាច់មួយរយ ឬពោលដោយមាត់ដេញថា លោកកុំនៅក្នុងទីនេះ សូម្បីឲ្យបុគ្គលនោះអត់ទោសហើយ គប្បីជាប់តាមទៅ គឺ មិនគប្បីលះបុគ្គលនោះអស់ជីវិត ។

ចប់អដ្ឋកថា សេវនាសូត្រទី ៦

# អដ្ឋកថា សុតវាសូត្រទី ៧

## *ត្រាស់ឋានៈដែលព្រះអរហន្ត*

## *មិនកន្លងល្មើសដល់សុតវាបរិព្វាជន*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សុតវាសូត្រទី ៧ ដូចតទៅនេះ ៖*

[៧] *បទថា* ***បញ្ចដ្ឋានានិ អជ្ឈាចរិតុំ*** *(ដើម្បីប្រព្រឹត្តកន្លងឋានៈ៥ប្រការ) បានដល់ ដើម្បីកន្លងហេតុ ៥ ប្រការ ។ បទថា* ***បាណំ*** *(សត្វ) បានដល់ ដោយទីបំផុតស្រមោចខ្មៅ ស្រមោចក្រហម ។ បទថា* ***អទិន្នំ*** *(វត្ថុរបស់ដែលគេមិនឲ្យ) បានដល់ របស់អ្នកដទៃដោយទីបំផុតសូម្បីស្មៅមួយទង ។ បទថា* ***ថេយ្យសង្ខាតំ*** *(ដោយអាការលួច) បានដល់ សូម្បីដោយចិត្តគិតលួច ។ បទថា* ***សន្និធិការកំ កាមេ បរិភុញ្ជិតុំ*** *(ធ្វើការសន្សំបរិភោគកាមគុណ) បានដល់ មិនគួរដើម្បីធ្វើការសន្សំ គឺ រក្សាទុកហើយបរិភោគវត្ថុកាម និងកិលេសកាម ។ ប្រការនោះ ព្រះមានព្រះភាគត្រាស់សំដៅយកវត្ថុដែលជាអកប្បិយៈ (មិនគួរ) ។ បទថា* ***ពុទ្ធំ បច្ចក្ខាតុំ***[១]

(១) បទដើមនេះ មិនមានក្នុងសុតវាសូត្រ តែប្រាកដក្នុងសជ្ឈសូត្របន្ទាប់ ។

*(មិនគួរពោលលះបង់ព្រះពុទ្ធ) បានដល់ ដើម្បីបដិសេធយ៉ាងនេះថា បុគ្គលនេះមិនមែនជាព្រះពុទ្ធ ។ សូម្បីក្នុងបទថា ព្រះធម៌ ជាដើម ក៏មានន័យនេះដូចគ្នា ។ ប្រការដែលមកហើយក្នុងអដ្ឋកថាយ៉ាងនេះ ចំណែកក្នុងព្រះបាលីព្រះសូត្រនេះ ពោលការដល់សេចក្ដីលំអៀង ។*

ចប់អដ្ឋកថា សុតវាសូត្រទី ៧

# អដ្ឋកថា សជ្ឈសូត្រទី ៨

## ត្រាស់ឋានៈដែលព្រះអរហន្ត

## មិនកន្លងល្មើសដល់សជ្ឈបរិព្វាជក

[៨] ក្នុងសជ្ឈសូត្រទី ៨ ព្រះមានព្រះភាគ ត្រាស់ដល់ការលះបង់ព្រះពុទ្ធជាដើម ។

ចប់អដ្ឋកថា សជ្ឈសូត្រទី ៨

# អដ្ឋកថា បុគ្គលសូត្រទី ៩

## *បុគ្គល ៩ ចំពូក*

*[៩] ក្នុងបុគ្គលសូត្រទី ៩ ព្រះមានព្រះភាគត្រាស់ថា បុគ្គលដែលគួរទទួលរបស់ដែលគេនាំមកបូជា ព្រោះទ្រង់កាន់យករួមទាំងបុថុជ្ជន ។*

ចប់អដ្ឋកថា បុគ្គលសូត្រទី ៩

# អដ្ឋកថា អាហុនេយ្យសូត្រទី ១០

## *បុគ្គលគួរទទួលរបស់ដែលគេនាំចូលមកជាដើម*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អាហុនេយ្យសូត្រទី ១០ ដូចតទៅនេះ ៖*

*[១០] ក្នុងបទថា* ***គោត្រភូ*** *(គោត្រភូបុគ្គល) បានដល់ បុគ្គលដែលប្រកបដោយវិបស្សនាដ៏មានកម្លាំងដល់ទីបំផុត ជាអនន្តរប្បច្ច័យដល់សោតាបត្តិមគ្គ ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានសេចក្ដីងាយហើយ ។*

ចប់អដ្ឋកថា អាហុនេយ្យសូត្រទី ១០

**ចប់សម្មោធវគ្គវណ្ណនាទី ១**

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# សីហនាទវគ្គវណ្ណនាទី ២

## អដ្ឋកថា វុដ្ឋសូត្រទី ១

### *បុគ្គលចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង វុដ្ឋសូត្រទី ១ ដូចតទៅនេះ៖*

[១១] *ក្នុងបទថា **យេន ភគវា តេនុបសង្កមិ** (ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់) បានដល់ ព្រះសារីបុត្រគិតថា បើព្រះសាស្តាបំណាងនឹងចៀសចេញទៅកាន់ទីចារិក គប្បីទ្រង់ចៀសចេញក្នុងកាលនេះហើយចុះ យើងនឹងទូលលាព្រះសាស្តាដើម្បីទៅកាន់ទីចារិក ជាអ្នកដែលពួកភិក្ខុហែហមចូលទៅគាល់ហើយ ។ បទថា **អាយស្មា មំ ភន្តេ** (បពិត្រព្រះអង្គដ៏ចម្រើន... ខ្ញុំព្រះអង្គ) សេចក្តីថា ភិក្ខុនោះឃើញព្រះថេរៈមកព្រមទាំងភិក្ខុជាបរិវារដ៏ច្រើន គិតថា ពួកភិក្ខុទាំងនេះលះបង់ព្រះសាស្តាហើយចេញទៅ ហែហមព្រះសារីបុត្រ យើងនឹងទូលហាមការទៅរបស់ព្រះថេរៈនោះ បានចងសេចក្តីក្រោធដោយមិនមានហេតុ ទើបបានក្រាបទូលហើយ*

យ៉ាងនោះ ។ ក្នុងបទទាំងនោះ បទថា **អាសជ្ជ** (ប៉ះ) បានដល់ ប៉ះខ្ទប់ហើយ ។ បទថា **អប្បដិនិស្សជ្ជ** (មិនសូមទោស) បានដល់ មិនសូមខមា គឺ មិនសម្ដែងកំហុស ។ សួរថា ក៏ភិក្ខុនោះ ចងអាឃាតព្រោះហេតុអ្វី ។ ឆ្លើយថា ជាយចីវររបស់ព្រះថេរៈដែលកំពុងក្រោកឡើង ទៅថ្វាយបង្គំព្រះទសពល ប៉ះត្រូវខ្លួនរបស់ព្រះថេរៈនោះ ។ អាចារ្យពួកខ្លះពោលថា ខ្យល់បក់ទៅត្រូវ ដូច្នេះក៏មាន ។ លោកចងអាឃាតដោយហេតុមានប្រមាណប៉ុណ្ណេះ ហើយកាលបានឃើញព្រះថេរៈទៅព្រមនឹងបរិវារដ៏ច្រើន ក៏កើតឥស្សា គិតថា យើងនឹងទូលហាមការទៅរបស់ព្រះថេរៈនោះ ទើបបានពោលយ៉ាងនេះ ។

បទថា **ឯហិត្វំ ភិក្ខុ** (ភិក្ខុអ្នកចូរមកទីនេះ) បានដល់ ព្រះសាស្ដាស្ដាប់ពាក្យរបស់ភិក្ខុនោះហើយ ទ្រង់ដឹងថា កាលតថាគតពោលថា ភិក្ខុសារីបុត្រមិនបានវាយអ្នក លោកនឹងទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គកាន់ជើងព្រះអគ្គសាវករបស់ព្រះអង្គប៉ុណ្ណោះ មិនបានកាន់ជើងខ្ញុំព្រះអង្គនឹងប្រទុស្សរាយតថាគត ហើយគប្បីកើតក្នុងអបាយ ទ្រង់ត្រិះរិះថា តថាគត

ឲ្យហៅសារីបុត្រមកហើយ នឹងសួររឿងនេះ ទើបបានហៅភិក្ខុមួយរូបមក ហើយត្រាស់យ៉ាងនេះ ។

បទថា **អបាបុរណំ អាទាយ (កាន់យកនូវកូនសោ)** បានដល់ កាន់កូនសោរ ។ បទថា **សីហនាទំ (សីហនាទ)** បានដល់ បន្លឺសីហនាទដ៏ប្រសើរ បន្លឺសីហនាទចំពោះព្រះភក្ត្រ បន្លឺសីហនាទដែលនរណាក៏ជំទាស់មិនបាន ។ ភិក្ខុសង្ឃដែលព្រះមហាថេរៈទាំងពីររូបប្រកាសហើយយ៉ាងនេះ ក៏នាំគ្នាលះទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ហើយបានទៅកាន់សំណាក់របស់ព្រះសាស្ដា ។ បទថា **ឱយធម្មំ (ពោលរក)** បានដល់ហេតុនៃពាក្យ ។ បទថា **គូថគតម្បិ (គូថ)** បានដល់ លាមកនោះឯង ។ ក្នុងពាក្យដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **បឋវីសមេន (ស្មើដោយផែនដី)** បានដល់ ឈ្មោះថា មានចិត្តស្មើដោយផែនដី ដោយអត្ថថា មិនក្រោធ មិនប្រទុស្សរាយ ។ ពិតណាស់ ផែនដីនឹងមិនអាចធ្វើសេចក្ដីត្រេកអរថា ជនទាំងឡាយចោលរបស់ស្អាតចុះត្រង់យើង និងមិនអាចធ្វើសេចក្ដីទាស់ចិត្តថា ជនទាំងឡាយចោល

របស់មិនស្អាតចុះត្រង់យើង ព្រះសារីបុត្រសំដែងថា ចិត្តរបស់ខ្ញុំព្រះអង្គក៏ដូច្នោះ ។ បទថា **វិបុលេន (ដែលទូលាយ)** បានដល់ មិនតិច ។ បទថា **មហគ្គតេន (ធំទូលាយ)** បានដល់ ដល់នូវភាពធំទូលាយ ។ បទថា **អប្បមាណេន (ប្រមាណមិនបាន)** បានដល់ បរិយាយចេញទៅប្រមាណមិនបាន ។ បទថា **អវេរេន (មិនមានពៀរ)** បានដល់ វៀរហើយចាកពៀរពីអកុសល និងពៀរពីបុគ្គល ។ បទថា **អព្យាបជ្ជេន (មិនមានព្យាបាទ)** បានដល់ មិនមានទុក្ខ គឺ ប្រាសចាកទោមនស្ស ។ បទថា **សោ ឥធ (ភិក្ខុនោះ)** បានដល់ ព្រះសារីបុត្របន្លឺសីហនាទជាគ្រាដំបូងថា ភិក្ខុនោះ គឺ អ្នកមិនចូលទៅតាំងកាយានុបស្សនាសតិដ្ឋានទុក ទើបធ្វើយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលដូចខ្ញុំព្រះអង្គ នឹងធ្វើកម្មបែបនោះបានយ៉ាងណា ។ គប្បីជ្រាប បទដែលប្រកបសេចក្តីក្នុងទីទាំងពួងយ៉ាងនេះ ។

បទថា **រជោហរណំ (សំពត់ជូតធូលី)** បានដល់ សម្រាប់ពួករាជត្រកូល ពួកគេមិនសម្អាតដោយឈើសម្អាត តែពួកគេជូតដោយកំណាត់សំពត់ ។ នោះ ជាឈ្មោះរបស់សំពត់ជូតធូលីនោះឯង ។ បទថា **កឡោ-**

**ឋិហត្ថោ** (មានដៃកាន់កញ្ជើ) បានដល់ កាន់កញ្ជើ ឬកាន់ថ្នាំងបាយ ។ បទថា **នន្តិកវាសី** (ស្លៀកសំពត់រេចជាយ) បានដល់ ជាអ្នកស្លៀកសំពត់ចាស់រេចជាយ ។ បទថា **សុរតោ** (ស្ងប់ស្ងៀម) បានដល់ ជាអ្នកមានប្រក្រតីស្រស់ស្រាយប្រកបដោយសេចក្តីស្ងប់ស្ងៀម ។ បទថា **សុទន្តោ** (ហ្វឹកហាត់ល្អហើយ) បានដល់ បានទទួលការហ្វឹកហាត់ល្អហើយ ។ បទថា **ន កញ្ចិ ហឹសតិ** (មិន... ខូចអ្វីៗ) បានដល់ មិនបៀតបៀននរណាៗ សូម្បីនឹងចាប់ត្រង់ស្នែងជាដើម សូម្បីនឹងស្ទាបអង្អែល ។ បទថា **ឧសភ-ឆិន្នវិសាណសមេន** (ស្មើដូចគោបាក់ស្នែង) បានដល់ ដូចចិត្តរបស់គោឧសភៈបាក់ស្នែង ។

បទថា **អដ្ដិយេយ្យ** (គប្បីធុញទ្រាន់) បានដល់ គប្បីជាអ្នកធុញទ្រាន់ព្រោះត្រូវសេចក្តីបៀតបៀន ។ បទថា **ហរាយេយ្យ** (នឿយណាយ) បានដល់ ខ្មាស់ ។ បទថា **ជិគុច្ឆេយ្យ** (ខ្ពើមរអើម) បានដល់ ដល់នូវភាពខ្ពើមរអើម ។ បទថា **មេទកថាលិកំ** (ភាជនៈខ្លាញ់) បានដល់ ភាជនៈដែលពួកអ្នកជញ្ជាំសាច់បោះជារន្ធទុកក្នុងទីនោះៗ ដើម្បីបង្ហូរទឹកចេញអំពី

សាច់ ហៅកាជនៈខ្លាញ់ ។ បទថា **បរិហរេយ្យ** (ផ្គង) បានដល់ គប្បីដាក់ឲ្យពេញដោយសាច់ ហើយកាន់ដើរទៅ ។ បទថា **ឆិទ្ទាវឆិទ្ទំ** (មានរន្ធតូចធំ) បានដល់ ប្រកបដោយរន្ធតូចធំ ។ បទថា **ឧគ្ឃរន្តំ** (ប្រោះចេញ) បានដល់ ទឹកហូរចេញអំពីសាច់តាមរន្ធត្រង់មាត់ខាងលើ ។ បទថា **បគ្ឃរន្តំ** (ហូរចេញ) បានដល់ ទឹកហូរចេញអំពីសាច់តាមរន្ធខាងក្រោម ។ រាងកាយទាំងអស់របស់ពួកអ្នកជញ្ជាំសាច់ ប្រឡាក់ដោយទឹកចេញអំពីសាច់ ដោយអាការយ៉ាងនេះ ។ បទថា **ឆិទ្ទាវឆិទ្ទំ** (ដែលមានរន្ធតូចធំ) បានដល់ ជារន្ធតូចធំចេញពីមាត់ដំបៅ (ទ្វារ) ទាំង ៩ ។ ក្នុងប្រការនេះ ព្រះថេរៈពោលនូវភាពដែលខ្លួនមិនមានឆន្ទរាគៈក្នុងរាងកាយ ដោយប្រការទី ៨ ឬប្រការទី ៩ ដោយអាការយ៉ាងនេះ ។

បទថា **អថខោ សោ ភិក្ខុ** (លំដាប់នោះ ភិក្ខុនោះ) បានដល់ លំដាប់នោះឯង ភិក្ខុនោះ កាលព្រះថេរៈបន្លឺសីហនាទដោយហេតុ ៩ ប្រការដូច្នេះហើយ ។ បទថា **អច្ចយោ** (ទោស) បានដល់ កំហុស ។ បទថា **មំ អច្ចគមា** (បានគ្របសង្កត់ខ្ញុំព្រះអង្គ) បានដល់ កំហុសបានគ្របសង្កត់

ខ្ញុំព្រះអង្គហើយ ។ បទថា **បដិគ្គណ្ហាតុ** (ប្រោសទទួល) បានដល់ សូមព្រះមានព្រះភាគទ្រង់មេត្តាប្រោសអត់ទោសផងចុះ ។ បទថា **អាយតឹ សំវរាយ** (**ដើម្បីសេចក្តីសង្រួមតទៅចុះ**) បានដល់ ដើម្បីសេចក្តីសង្រួមក្នុងអនាគត គឺ ដើម្បីមិនធ្វើខុសដូច្នេះទៀត ។

បទថា **តគ្ឃ** (**ពិតប្រាកដ**) គឺ ដោយចំណែកមួយ ។ បទថា **យថា-ធម្មំ បដិករោសិ** (**ត្រឡប់ធ្វើតាមធម៌វិញ**) បានដល់ លោកបានធ្វើតាមធម៌ដែលតាំងនៅហើយ មានពាក្យអធិប្បាយថា ឲ្យអត់ទោស ។ បទថា **តន្តំ មយំ បដិគ្គណ្ហាម** (**យើងយល់ព្រមទទួល (ជ្រាប) ទោសរបស់លោកនោះ**) បានដល់ យើងព្រមអត់នូវទោសកំហុសនោះដល់លោក ។ បទថា **វុឌ្ឍិ ហេសា ភិក្ខុ អរិយស្ស វិនយេ** (**នេះជាសេចក្តីចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ**) បានដល់ ភិក្ខុ នេះឈ្មោះថា សេចក្តីចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ គឺ ក្នុងពាក្យទូន្មានរបស់ព្រះមានព្រះភាគ ។ សួរថា សេចក្តីចម្រើនយ៉ាងណា ។ ឆ្លើយថា ការឃើញទោសថាជាទោស ហើយធ្វើតាមធម៌វិញ ដល់នូវការសង្រួមតទៅ ។ ក៏កាលព្រះមានព្រះភាគទ្រង់

ធ្វើទេសនាឲ្យជាបុគ្គលាធិដ្ឋាន ទើបត្រាស់ថា **យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ** (ភិក្ខុឃើញទោសថាជាទោស ហើយត្រឡប់ធ្វើតាមធម៌វិញ) ។

បទថា **ផលិស្សតិ** (នឹងបែកធ្លាក់) បានដល់ ក៏បើព្រះថេរៈមិនគប្បីអត់ទោសសោត សីសៈរបស់ភិក្ខុនោះគប្បីបែកជា ៧ ចំណែក ព្រោះទោសនោះឯង ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់យ៉ាងនោះ ។ បទថា **សាចេមមំ សោ** (បើលោក... ខ្ញុំព្រះអង្គ) បានដល់ បើភិក្ខុនេះពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា សូមលោកចូលអត់ទោសចុះ ។ បទថា **ខមតុ ច មេ សោ** (ចូរអត់ទោសដល់ខ្ញុំផង) បានដល់ ព្រះថេរៈ លុះអត់ទោសឲ្យដល់ភិក្ខុនោះហើយ ក៏ឲ្យភិក្ខុនោះអត់ទោសឲ្យដល់ខ្លួនចំពោះព្រះភក្ត្ររបស់ព្រះសាស្ដា យ៉ាងនេះថា សូមលោកអ្នកមានអាយុ ចូរអត់ទោសដល់ខ្ញុំផងចុះ ។

ចប់អដ្ឋកថា វុដ្ឋសូត្រទី ១

# អដ្ឋកថា ឧបាទិសេសសូត្រទី ២

## សឧបាទិសេសបុគ្គល ៩ ពួក

*គប្បីជ្រាបវិនិច្ឆ័យក្នុង សឧបាទិសេសសូត្រទី ២ ដូចតទៅនេះ ៖*

*[១២] បទថា **សឧបាទិសេសំ** (ជាសឧបាទិសេស) បានដល់ ជាបុគ្គលនៅសល់ការប្រកាន់ ។ បទថា **អនុបាទិសេសំ** (បុគ្គលដែលជាអនុបាទិសេស) បានដល់ ជាអ្នកប្រាសចាកឧបាទានដ៏សេស គឺ អស់សេចក្តីប្រកាន់ ។ បទថា **មត្តសោការី** (ការល្មមប្រមាណ) បានដល់ ជាអ្នកល្មមប្រមាណ គឺ នៅមិនទាន់បរិបូណ៌ ។ ក្នុងបទថា ន **តាវាយំ សារិបុត្ត ធម្មបរិយាយោ បដិភាសិ** (សារីបុត្រ ធម្មបរិយាយនេះនៅមិនទាន់ជាក់ច្បាស់ដល់... មុន) បានដល់ ឈ្មោះថា ការបិទបាំងការដឹង រមែងមិនមានដល់ព្រះមានព្រះភាគ ក៏សេចក្តីក្នុងប្រការនេះ មានដូច្នេះថា តថាគតនឹងមិនពោលធម្មបរិយាយនេះមុន ។ បទថា **មា ឥមំ ធម្មបរិយាយំ សុត្វា បមាទំ អាហរឹសុ** (ព្រោះជនទាំងឡាយស្តាប់ធម៌បរិយាយនេះហើយ កុំដល់នៅសេចក្តីប្រមាទ) បានដល់ បុគ្គលទាំងឡាយ កាលមិនធ្វើសេចក្តីព្យាយាម*

ដើម្បីព្រះអរហត្តក្នុងខាងដើម កុំដល់នូវសេចក្តីប្រមាទដោយយល់ថា ន័យថា យើងទាំងឡាយផុតហើយចាកអបាយ ៤ ។ បទថា **បញ្ហាធិប្បាយេន ភាសិតោ (ពោល... ដោយបំណងការឆ្លើយបញ្ហា)** ព្រះមានព្រះភាគទ្រង់សំដែងថា តថាគតពោលតាមបញ្ហាដែល (ព្រះសារីបុត្រ) សួរហើយ ។

ក៏ព្រះមានព្រះភាគទ្រង់ធ្វើសេចក្តីនោះឯងឲ្យដូចជាហេតុកើត ដើម្បីបន្ទាបង់ធន្ទរាគៈ ក្នុងភពទាំងឡាយរបស់បុគ្គល ៩ ពួក ទាំងនេះហើយ ទើបបានត្រាស់សូត្រនេះថា ម្នាលភិក្ខុទាំងឡាយ លាមកសូម្បីមានប្រមាណតិច រមែងមានក្លិនស្អុយ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ តថាគតមិនសរសើរសូម្បីភព ដោយប្រមាណតិចតួច ដោយទីបំផុតសូម្បីត្រឹមតែមួយផ្ទាត់ម្រាមដៃ ដូច្នេះដូចគ្នា ។ គតិជាប្រចាំចំពោះបុគ្គល ៩ ពួក ទាំងនោះប៉ុណ្ណោះត្រឹមតែម្យ៉ាងក៏មិនមាន ក៏ត្រកូលណាធ្វើបុណ្យជាប្រចាំបែបនេះ គឺ តាំងនៅក្នុងសរណៈ ៣ សមាទានសីល ៥ ថ្វាយសលាកភត្ត ១ ថ្វាយបិណ្ឌបាត ១ ថ្វាយសំពត់ចាំវស្សា ១ សាងស្រះបោក្ខរណី ១ អាវាស ១ គតិក៏ជារបស់ប្រចាំដល់ត្រកូលសូម្បីទាំងនោះ ត្រកូលទាំងនោះប្រាកដ

ដូចជាសោតាបន្នបុគ្គលនោះឯង ។

ចប់អដ្ឋកថា សឧចាទិសេសសូត្រទី ២

# អដ្ឋកថា កោដ្ឋិតសូត្រទី ៣

## បញ្ហារបស់ព្រះកោដ្ឋិតៈ

*គប្បីជ្រាបវិនិច្ឆ័យក្នុង កោដ្ឋិតៈសូត្រទី ៣ ដូចតទៅនេះ ៖*

*[១៣] បទថា **ទិដ្ឋធម្មវេទនីយំ** (ឲ្យផលក្នុងបច្ចុប្បន្ន) បានដល់ កម្មដែលឲ្យផលក្នុងអត្តភាពនេះប៉ុណ្ណោះ ។ បទថា **សម្បរាយវេទនីយំ** (ឲ្យផលក្នុងសម្បរាយភព) បានដល់ កម្មដែលឲ្យផលក្នុងអត្តភាពទី ២ ។ បទថា **សុខវេទនីយំ** (ឲ្យផលជាសុខ) បានដល់ កម្មតាក់តែងឲ្យកើតសុខវេទនា ។ បទថា **ទុក្ខវេទនីយំ** (ឲ្យផលជាទុក្ខ) បានដល់ កម្មតាក់តែងឲ្យកើតទុក្ខវេទនា ។ បទថា **បរិបក្កវេទនីយំ** (ឲ្យផលសម្រេចហើយ) បានដល់ កម្មដែលបានវារៈឲ្យផលហើយ ។ បទថា **អបរិក្កវេទនីយំ** (នៅមិនទាន់ឲ្យផល) បានដល់ កម្មដែលនៅមិនទាន់បានវារៈឲ្យផល ។ បទថា **ពហុវេទនីយំ** (ឲ្យផលច្រើន) បានដល់ កម្មដែលឲ្យវិបាកច្រើន ។ បទថា **អប្បវេទនីយំ** (ឲ្យផលតិច) បានដល់ កម្មឲ្យវិបាកមិនច្រើន ។ បទថា **វេទនិយំ** (កំពុងឲ្យផល) បានដល់ កម្មដែលកំពុងឲ្យវិបាក ។ បទថា*

*អវេទនីយំ (មិនឲ្យផល) បានដល់ កម្មមិនទាន់ឲ្យវិបាក ។ ក្នុងសូត្រនេះ លោកពោលទាំងវដ្តៈ និងវិវដ្តៈ ។*

ចប់អដ្ឋកថា កោដ្ឋិតសូត្រទី ៣

# អដ្ឋកថា សមិទ្ធិសូត្រទី ៤

## *ព្រះសមិទ្ធិឆ្លើយបញ្ហាព្រះសារីបុត្រ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សមិទ្ធិសូត្រទី ៤ ដូចតទៅនេះ ៖*

[១៤] *បទថា* ***សមិទ្ធិ (ព្រះសមិទ្ធិ)*** *បានដល់ ព្រះថេរៈដែលជាសទ្ធិវិហារិករបស់ព្រះថេរៈ (ព្រះសារីបុត្រ) មានឈ្មោះយ៉ាងនេះ ព្រោះការសម្រេចនៃអត្តភាព ។ បទថា* ***កិមារម្មណា (មានអ្វីជាអារម្មណ៍)*** *បានដល់ មានអ្វីជាបច្ច័យ ។ បទថា* ***សង្កប្បវិតក្កា (វិតក្កៈដែលជាសេចក្តីត្រិះរិះ)*** *បានដល់ វិតក្កៈដែលជាការនឹកគិត ។ បទថា* ***នាមរូបារម្មណា (មាននាមរូបជាអារម្មណ៍)*** *បានដល់ មាននាមរូបជាបច្ច័យ ។ ដោយបទនេះ លោកសំដែងថា អរូបក្ខន្ធ ៤ និងរូបទាំងជាភូតរូប និងឧបាទាយរូបជាបច្ច័យដល់វិតក្កៈទាំងឡាយ ។ បទថា* ***ក្វ នានត្តំ គច្ឆន្តិ (រមែងដល់សេចក្តីផ្សេងគ្នាក្នុងអ្វី)*** *បានដល់ រមែងដល់សភាពផ្សេងៗ គ្នា គឺ សេចក្តីផ្សេងគ្នាក្នុងទីណា ។ បទថា* ***ធាតូសុ (ក្នុងធាតុទាំងឡាយ)*** *បានដល់ ក្នុងរូបធាតុជាដើម ។ ព្រោះថា សេចក្តីត្រិះរិះក្នុងរូបផ្សេង សេចក្តីត្រិះរិះ*

ក្នុងសំឡេងជាដើមផ្សេង ។ បទថា **ផស្សសមុទយា (មានផស្សៈជាហេតុកើត)** បានដល់ មានផស្សៈដែលសម្បយុត្តជាបច្ច័យ ។ បទថា **វេទនាសមោសរណា (មានវេទនាជាទីប្រជុំចុះ)** បានដល់ មានវេទនា ៣ ជាទីរួមចុះ ។ លោកពោលកុសល និងអកុសលរួមគ្នា ដោយហេតុប្រមាណប៉ុណ្ណេះ ។ ចំណែកធម៌ **មានសមាធិជាប្រធាន (សមាធិប្បមុខា)** ជាដើម គប្បីជ្រាបថា ជាធម៌ចំណែកមិនសន្សំកិលេស ។ ក្នុងបទនោះ វិតក្កៈឈ្មោះថា **មានសមាធិជាប្រធាន** ព្រោះអត្ថថា វិតក្កៈទាំងនោះមានសមាធិជាប្រធាន ដោយអត្ថថា មានសភាពដល់មុន ឬដោយអត្ថថា ជាធំ ។ ឈ្មោះថា **សតាធិបតេយ្យា (មានសតិជាធំ)** ព្រោះអត្ថថា វិតក្កៈនោះមានសតិជាធំ ដោយអត្ថថា ជាហេតុនៃអ្នកជាធំ ។ ឈ្មោះថា **បញ្ញុត្តរា (មានបញ្ញាក្រៃលែងជាង)** ព្រោះអត្ថថា វិតក្កៈទាំងនោះ មានមគ្គបញ្ញាជាកំពូល ។ បទថា **វិមុត្តិសារា (មានវិមុត្តិជាខ្លឹម)** ព្រោះអត្ថថា សម្រេចផលវិមុត្តិ រមែងដល់នូវខ្លឹម ។ ឈ្មោះថា **អមតោគធា (មានអមតៈជាទីតាំងនៅ)** បានដល់ ព្រោះអត្ថថា ចុះកាន់អមតនិព្វាន ហើយតាំងនៅក្នុង

*អមតនិព្វាននោះ ដោយអំណាចជាអារម្មណ៍ ។ បទថា* **តេន វា មា មញ្ញិ** *(អ្នកកុំបានចិត្ត ព្រោះការវិសជ្ជនាប្រស្នានោះឡើយ) បានដល់ លោកកុំធ្វើសេចក្តីក្រអឺតក្រអោង ឬសេចក្តីបានចិត្ត ដោយការវិសជ្ជនានោះថា យើងឆ្លើយបញ្ហាដែលអគ្គសាវកសួរបានហើយ ។*

ចប់អដ្ឋកថា សមិទ្ធិសូត្រទី ៤

# អដ្ឋកថា គណ្ឌសូត្រទី ៥

## បុរសមានមុខដំបៅ ៩ កន្លែង

គប្បីជ្រាបវិនិច្ឆ័យក្នុង គណ្ឌសូត្រទី ៥ ដូចតទៅនេះ ៖

[១៥] ៣ ឆ្នាំ ៤ ឆ្នាំ ហៅថា វស្សគណៈ (ច្រើនឆ្នាំ) ។ បទថា **អនេកវស្សគណិកោ (កើតឡើងច្រើនឆ្នាំ)** ព្រោះអត្ថថា បុរសនោះកើតឡើងហើយរាប់បានច្រើនឆ្នាំ ។ បទថា **តស្សស្សុ (បុរសនោះគប្បីមាន)** បានដល់ គប្បីមានដល់ដំបៅនោះ ។ បទថា **អភេទនមុខានិ (មុខដំបៅដែលនៅមិនទាន់ធ្លាយ)** បានដល់ មិនមែនធ្លាយព្រោះបុគ្គលណាមួយធ្វើទេ តែជាដំបៅដែលកើតអំពីកម្មតែម្យ៉ាងពិតៗ ។ បទថា **ជេគុច្ឆិយំយេវ (គួរខ្ពើមនោះឯង)** បានដល់ គួរខ្ពើម គឺ ជារបស់បដិកូលនោះឯង ។ បទថា **ចាតុម្មហាភូតិកស្ស (របស់កាយដែលប្រកបដោយមហាភូតរូប ៤)** បានដល់ កាយសម្រេចដោយមហាភូតរូប ៤ ។ បទថា **ឱទនកុម្មាសុបចយស្ស (ចម្រើនឡើងដោយបាយទឹក និងនំ)** បានដល់ កាយសន្សំ គឺ ចម្រើនធំធាត់ហើយដោយបាយ និងនំ ។

បទថា **អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មស្ស** (មានសេចក្តីមិនទៀង មានកិរិយាប្រោះព្រំ គក់ប្រេបាច់ បែកធ្លាយវិនាសខ្ទាត់ខ្ចាយជាធម្មតា) បានដល់ មានការមិនទៀងជាធម្មតា ព្រោះអត្ថថា មានហើយមិនមាន មានកិរិយាដុសលាបជាធម្មតា ដោយការលាបដើម្បីកម្ចាត់បង់ក្លិនស្អុយ មានការគក់ប្រេបាច់ជាធម្មតា ដោយការគក់ប្រេបាច់ដើម្បីបន្ទោបង់ការឈឺចុកចាប់ត្រង់អវយវៈតូចធំ ម្យ៉ាងទៀត ក្នុងវេលានៅជាក្មេងតូចក៏មានការគក់ប្រេបាច់ជាធម្មតា ដោយការឲ្យដេកលើភ្លៅទាំងពីរ លាបថ្នាំនិងគក់ប្រេបាច់ជាដើម ដើម្បីធ្វើអវយវៈតូចធំនោះៗ ដែលតាំងនៅមិនល្អខណៈដែលនៅក្នុងគភ៌ឲ្យបរិបូណ៌ សូម្បីរក្សាហើយយ៉ាងនេះ ក៏មានការបែកធ្លាយជាធម្មតា អធិប្បាយថា មានសេចក្តីបែកធ្លាយខ្ទាត់ខ្ចាយជាសភាព ។ ក៏ក្នុងប្រការនេះ ត្រាស់ដល់ការរលត់នៃកាយនោះ ដោយបទថា មិនទៀង និងដោយបទថា បែកធ្លាយ ត្រាស់ការកើត ដោយបទដ៏សេស ។ បទថា **និព្វិន្ទថ** (ចូរនឿយណាយ) ព្រះមានព្រះភាគសំដែងថា លោកទាំងឡាយចូរនឿយណាយ គឺ លះបង់ចោលកាយនេះចេញចុះ ។ ក្នុងសូត្រនេះ ព្រះ

*មានព្រះភាគត្រាស់ដល់វិបស្សនាដ៏មានកម្លាំង ដោយប្រការដូច្នេះឯង ។*

ចប់អដ្ឋកថា គណ្ឌសូត្រទី ៥

# អដ្ឋកថា សញ្ញាសូត្រទី ៦

## សញ្ញា ៩ យ៉ាង

គប្បីជ្រាបវិនិច្ឆ័យក្នុង សញ្ញាសូត្រទី ៦ ដូចតទៅនេះ ៖

[១៦] សញ្ញាសូត្រទី ៦ មានន័យតាមដែលពោលមកហើយនោះឯង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់ញាណប៉ុណ្ណោះ ដោយមានសញ្ញាជាធំ ។

ចប់អដ្ឋកថា សញ្ញាសូត្រទី ៦

# អដ្ឋកថា កុលសូត្រទី ៧

## ត្រកូលដែលមិនគួរ និងគួរចូលទៅ

គប្បីជ្រាបវិនិច្ឆ័យក្នុង កុលសូត្រទី ៧ ដូចតទៅនេះ ៖

[១៧] បទថា ន មនាបេន បច្ចុដ្ឋេន្តិ (មិនត្រូវទទួលដោយសេចក្ដីពេញចិត្ត) បានដល់ ក្រោកចាកអាសនៈហើយ រមែងមិនធ្វើការទទួលដោយសេចក្ដីពេញចិត្ត គឺ ដោយអាការទាក់ទាញចិត្ត ។ បទថា ន មនាបេន អភិវាទេន្តិ (មិនថ្វាយបង្គំដោយសេចក្ដីពេញចិត្ត) បានដល់ រមែងមិនថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ បទថា អសក្កច្ចំ ទេន្តិ (ឲ្យដោយសេចក្ដីមិនគោរព) បានដល់ រមែងឲ្យដោយសេចក្ដីមិនរាប់អាន ។ បទថា នោ សក្កច្ចំ (មិន... ដោយសេចក្ដីគោរព) បានដល់ រមែងមិនឲ្យដោយដៃរបស់ខ្លួន ។ បទថា ន ឧបនិសីទន្តិ ធម្មស្សវនាយ (មិនអង្គុយជិតដើម្បីស្ដាប់ធម៌) បានដល់ រមែងមិនអង្គុយក្នុងទីជិត ដោយគិតថា យើងទាំងឡាយនឹងស្ដាប់ធម៌ ។ បទថា ន សេយន្តិ[១] (មិនត្រេកអរ) បានដល់ រមែង

---

(១) បិដក = ន រមិស្សន្តិ ។

មិនត្រេកអរ គឺ រមែងហូរត្រឡប់ ដូចជាទឹកដែលស្រោចលើពានផ្កាប់ ដូច្នេះ ។

ចប់អដ្ឋកថា កុលសូត្រទី ៧

# អដ្ឋកថា សត្តសូត្រទី ៨

## ការរក្សាឧបោសថដែលមានផលានិសង្សច្រើន

គប្បីជ្រាបវិនិច្ឆ័យក្នុង សត្តសូត្រទី ៧ ដូចតទៅនេះ ៖

[១៨] បទថា នវង្គសមន្នាគតោ (ឧបោសថប្រកបដោយអង្គ ៩) ដោយបន្ថែមមេត្តាភាវនា ដោយអំណាចអធ្យាស្រ័យរបស់វេនេយ្យបុគ្គល ។

ចប់អដ្ឋកថា សត្តសូត្រទី ៨

# អដ្ឋកថា ទេវតាសូត្រទី ៩

## *ទេវតាពោលផលនៃការគោរព*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទេវតាសូត្រទី ៩ ដូចតទៅនេះ ៖*

[១៩] *បទថា* ***វិប្បដិសារិនិយោ*** *(មានសេចក្តីក្តៅក្រហាយចិត្ត) បានដល់ ខ្ញុំព្រះអង្គទាំងឡាយមានសេចក្តីក្តៅក្រហាយ គឺ ភាពជាអ្នកអៀនប្រៀន ។ បទថា* ***ហីនំ កាយំ*** *(ពួកទេវតាជាន់ថោកទាប) បានដល់ ក៏ព្រោះអាស្រ័យទេវតាជាន់លើ លោកទើបហៅទេវតាជាន់ក្រោមថា ថោក-ទាប ។* ***នោ ច ខោ យថាសត្តិ យថាពលំ សំវិភជិម្ហា*** *(តែមិនបែងចែករបស់ឲ្យតាមដែលអាច តាមកម្លាំង) បានដល់ ខ្ញុំព្រះអង្គទាំងឡាយមិនបែងចែករបស់ឲ្យដល់លោកអ្នកមានសីលទាំងឡាយតាមសមគួរ ដែលនឹងអាច តាមសមគួរដល់កម្លាំងរបស់ខ្លួន ហើយបរិភោគ ។*

ចប់អដ្ឋកថា ទេវតាសូត្រទី ៩

# អដ្ឋកថា វេលាមសូត្រទី ១០

## ទានប្រៀបជាមួយទានរបស់វេលាមព្រាហ្មណ៍

*គប្បីជ្រាបវិនិច្ឆ័យក្នុង វេលាមសូត្រទី ១០ ដូចតទៅនេះ ៖*

*[២០] បទថា **អបិ នុ តេ គហបតិ កុលេ ទានំ ទិយ្យតិ (ម្នាល គហបតី ក្នុងត្រកូលអ្នកនៅឲ្យទានខ្លះដែរឬ)** បានដល់ សេចក្តីនេះ ព្រះមានព្រះភាគមិនបានត្រាស់សួរដល់ទាន ដែលអនាថបិណ្ឌកសេដ្ឋីថ្វាយដល់ភិក្ខុសង្ឃ តែក្នុងផ្ទះរបស់លោកសេដ្ឋីនៅឲ្យទានដ៏ប្រណីតជាប្រចាំដល់ភិក្ខុសង្ឃ ព្រះសាស្តាក៏ទ្រង់មិនមែនមិនដឹងដល់ប្រការនោះឡើយ ចំណែកទានដែលឲ្យដល់លោកិយមហាជនមានហើយ ទាននោះសៅហ្មង លោកសេដ្ឋីមិនសប្បាយចិត្ត ទើបត្រាស់សួរទាននោះ ។ បទថា **កាណាជកំ (បាយចុងអង្ករ)** បានដល់ អង្ករលាយជាមួយកន្ទក់ គឺ ដាំដោយអង្ករមួយប្រភេទលាយជាមួយកន្ទក់ ។ បទថា **ពិលង្គទុតិយំ (មានទឹកជ្រក់ជាគម្រប់ពីរ)** បានដល់ មានទឹកជ្រក់ជាគម្រប់ទី ២ ។*

*បទថា **អសក្កច្ចំ ទេតិ (ឲ្យ...ដោយមិនគោរព)** បានដល់ ឲ្យបែប*

មិនគោរព ។ បទថា **អបចិត្តិំ កត្វា ទេតិ** (**មិនធ្វើសេចក្តីមិនកោតក្រែង ហើយឲ្យ**) បានដល់ ឲ្យដោយមិនគោរព គឺ ដោយមិនគោរពក្នុងទក្ខិណេយ្យបុគ្គល ។ បទថា **អសហត្ថា ទេតិ** (**មិនឲ្យដោយដៃរបស់ខ្លួន**) បានដល់ មិនឲ្យដោយដៃរបស់ខ្លួន ឲ្យដោយដៃរបស់អ្នកដទៃ អធិប្បាយថា រមែងធ្វើត្រឹមតែបញ្ជាប៉ុណ្ណោះនោះឯង ។ បទថា **អបវិទ្ធំ ទេតិ** (**ឲ្យដូចបោះឲ្យ**) បានដល់ រមែងមិនឲ្យជាប់តគ្នា គឺ ឲ្យដូចជាអ្នកប្រាថ្នានឹងបោះចោល ដូចបុគ្គលដេញសត្វទន្សោងត្រង់ជំបូកកណ្តៀរ ដូចរុក្ខជាតិត្រាំស្រារបស់អ្នកលេងសុរាបក្ខរពល់ផ្ទាំងដូច្នោះ ។ បទថា **អនាគមនទិដ្ឋិកោ ទេតិ** (**ឃើញថាមិនមានផល ហើយឲ្យទាន**) បានដល់ មិនជឿកម្ម និងផលកម្ម ហើយឲ្យទាន ។

បទថា **យត្ថ យត្ថ** (**ក្នុងត្រកូលណាៗ**) បានដល់ ក្នុងត្រកូលណាៗ បណ្តាកុលសម្បទាទាំង ៣[១] ។ ក្នុងបទជាដើមថា **ន ឧឡារាយ ភត្តភោគាយ** (**មិន... ដើម្បីបរិភោគអាហារដែលល្អ**) មានវិនិច្ឆ័យដូចតទៅនេះ

(១) អ្នកប្រែ = ត្រកូលក្សត្រិយ៍ ព្រាហ្មណ៍ គហបតី ។

កាលបរិវារជនបង្អោនភោជនបាយសាលីក្រអូប ដែលមានរសឆ្ងាញ់ផ្សេងៗ ចូលទៅឲ្យ គេនឹងមិនបង្អោនចិត្តទៅ (ដើម្បីនឹងបរិភោគ) នឹងពោលថា លោកចូរនាំអាហារដែលបង្ករោគឲ្យកើតនេះចេញទៅ ពេញចិត្តបរិភោគបាយលាយកន្ទក់ជាមួយទឹកជ្រក់ដែលអន់ថយ ថាដូចជាអាហារទិព្វ ដូច្នោះ កាលគេបង្អោនសំពត់យ៉ាងល្អ មានសំពត់កាសីជាដើមចូលទៅឲ្យ ក៏ពោលថា លោកចូរនាំសំពត់ទាំងនេះទៅចុះ សំពត់ទាំងនេះមិនអាចសូម្បីនឹងបិទបាំងអ្នកស្លៀកបាន រមែងមិនជាប់នៅសូម្បីត្រង់រាងកាយ ចូលចិត្តស្លៀកសំពត់សាច់គ្រើមដូចជាឫសឈើ និងសំបករបស់ដើមដូងដែលធ្វើជាសំពត់ ដោយគិតថា មនុស្សស្លៀកសំពត់ទាំងនេះ រមែងដឹងត្រឹមតែថា ស្លៀកដណ្តប់ហើយ សំពត់ទាំងនេះ រមែងបិទបាំងសូម្បីវត្ថុដែលគួរបិទបាំងបាន កាលគេបង្អោនយានដំរី យានសេះ យានរថ ឬគ្រែស្នែងជាដើម ចូលទៅឲ្យ ក៏ពោលថា លោកចូរនាំយានទាំងនោះទៅចុះ នរណាៗ មិនអាចដើម្បីនឹងអង្គុយជាសុខក្នុងយាននេះបាន កាលគេបង្អោនរថចាស់គ្រាំគ្រាចូលទៅឲ្យ ក៏ពោលថា រថនេះជារថមិនញ័រ ក្នុងរថនេះអង្គុយបានជាសុខ រមែង

ត្រេកអរនឹងរឿងនោះ ។ បទថា **ន ឧឡារេសុ បញ្ចសុ កាមគុណេសុ** (មិន... កាមគុណ ៥ យ៉ាងល្អ) បានដល់ គេបានឃើញមនុស្សស្រីទាំងឡាយដែលមានរូបស្អាតប្រដាប់តាក់តែងហើយ គិតថា ឃើញដូចជានាងយក្ខិណី នាងយក្ខិណីទាំងនោះ ជាអ្នកប្រាថ្នានឹងបរិភោគយើង ប្រយោជន៍អ្វីដោយស្ត្រីទាំងឡាយទាំងនោះ រមែងឲ្យវេលាកន្លងទៅតាមសប្បាយ ។ បទថា **ន សុស្សូសន្តិ** (ជនទាំងនោះមិនស្តាប់) បានដល់ បរិវារជនទាំងឡាយរមែងមិនប្រាថ្នានឹងស្តាប់ អធិប្បាយថា រមែងមិនជឿ ដូច្នេះក៏មាន ។ បទថា **ន សោតំ ឱទហន្តិ** (មិនផ្ចង់ត្រចៀកស្តាប់) បានដល់ រមែងមិនផ្ចង់សោតបសាទចុះដើម្បីស្តាប់ពាក្យដែលគេពោលហើយ ។ បទជាដើមថា **សក្កច្ចំ** (ដោយគោរព) គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាជាមួយពាក្យដែលពោលហើយ ។

បទថា **វេលាមោ** (វេលាមៈ) បានដល់ ជាអ្នកមានឈ្មោះយ៉ាងនេះ ព្រោះប្រកបដោយគុណទាំងឡាយ មានជាតិ គោត្រ រូប ភោគៈ សទ្ធា និងបញ្ញាជាដើម ដ៏ធំកន្លងដែន ។ ក្នុងបទថា **សោ ឯវរូបំ ទានមទាសិ**

មហាទានំ (ព្រាហ្មណ៍នោះបានឲ្យទានជាមហាទានយ៉ាងនេះ) នេះ មានអនុ-បុព្វិកថាដូចតទៅនេះ ។

បានឮថា ក្នុងអតីត វេលាមព្រាហ្មណ៍នោះបានបដិសន្ធិហើយក្នុងផ្ទះរបស់បុរោហិត (ព្រាហ្មណ៍ជាទីប្រឹក្សាក្នុងផ្លូវទំនៀមទំលាប់ប្រពៃណី) នាក្រុងពារាណសី ។ ពួកញាតិបានតាំងឈ្មោះឲ្យគេថា វេលាមកុមារ ក្នុងវេលាអាយុ ១៦ ឆ្នាំ វេលាមកុមារនោះ បានទៅកាន់ក្រុងតក្កសិលាដើម្បីរៀនសិល្បៈជាមួយរាជកុមារក្រុងពារាណសី ។ អ្នកទាំងពីរនោះ រៀនសិល្បៈក្នុងសំណាក់អាចារ្យទិសាបាមោក្ខ ។ រាជកុមារ ៨៤.០០០ នាក់ សូម្បីពួកដទៃក្នុងជម្ពូទ្វីប ក៏ប្រាថ្នាដូចគ្នាជាមួយកុមារទាំងពីរនោះ ។ ព្រះពោធិសត្វក្នុងខណៈដែលខ្លួនរៀន ក៏ជាអ្នកជួយអាចារ្យឲ្យកុមារ ៨៤.០០០ នាក់សិក្សា សូម្បីខ្លួនឯងរៀនសិល្បៈដែលគេរៀនមកពីមុន ១៦ ឆ្នាំ ដោយវេលាត្រឹមតែ ៣ ឆ្នាំ ។ អាចារ្យដឹងថា សិល្បៈរបស់វេលាមកុមារស្ទាត់ជំនាញហើយ ទើបពោលថា កូនទាំងឡាយ វេលាមៈ រមែងដឹងសិល្បៈទាំងអស់ដែលយើងបានដឹងហើយ ពួកអ្នករាល់គ្នាចូរនាំគ្នាទៅរៀនសិល្បៈ

ក្នុងសំណាក់របស់វេលាមៈចុះ ហើយប្រគល់កុមារ ៨៤.០០០ នាក់ ឲ្យដល់ព្រះពោធិសត្វ ។

ព្រះពោធិសត្វថ្វាយបង្គំអាចារ្យហើយ ជាអ្នកមានកុមារ ៨៤.០០០ នាក់ ហែហម ចេញទៅ ដល់ក្រុងជិតមួយកន្លែងទើបឲ្យរាជកុមារដែលជាស្តេចរបស់ក្រុងនោះរៀន កាលគេជំនាញក្នុងសិល្បៈហើយ ទើបឲ្យគេបែកនៅក្នុងក្រុងនោះឯង ។ ព្រះពោធិសត្វទៅកាន់ក្រុង ៨៤.០០០ ក្រុង ដោយឧបាយនោះឯង ឲ្យរាជកុមារ ៨៤[1] នាក់ ហ្វឹកហាត់សិល្បៈរហូតជំនាញហើយ ទើបឲ្យរាជកុមារនោះៗ ត្រឡប់ទៅកាន់ក្នុងក្រុងនោះៗ ហើយក៏នាំយករាជកុមារក្រុងពារាណសីត្រឡប់មកនៅក្រុងពារាណសីវិញ ។ មនុស្សទាំងឡាយក្នុងក្រុងពារាណសីនោះ ទើបបានអភិសេករាជកុមារក្រុងពារាណសីដែលរៀនចប់សិល្បៈហើយទុកក្នុងរាជសម្បត្តិ បានឲ្យតំណែងបុរោហិតដល់វេលាមៈ ។ រាជកុមារ ៨៤.០០០ សូម្បីដទៃនោះ បានអភិសេកហើយក្នុងរាជសម្បត្តិទាំងឡាយរបស់ខ្លួន ក៏បាននាំគ្នាមកទំនុកបម្រុងព្រះរាជាក្រុង

---

(១) គួរតែ ៨៤.០០០ អង្គ ។

ពាកណាសីរាល់ៗ ឆ្នាំ ។ ព្រះរាជាទាំងនោះគាល់ព្រះរាជហើយ បានទៅកាន់សម្នាក់របស់វេលាមៈ ពោលថា បពិត្រលោកអាចារ្យ កាលខ្ញុំទាំងឡាយតាំងនៅហើយក្នុងរាជសម្បត្តិ លោកបំណងដោយវត្ថុណា គប្បីប្រាប់មកចុះ ហើយក៏នាំគ្នាទៅ កាលរាជកុមារទាំងនោះនាំយករទេះ រថ មេគោគោឈ្មោល មាន់ និងជ្រូកជាដើម ក្នុងវេលាទៅ និងវេលាមក ជនបទក៏ត្រូវបៀតបៀនយ៉ាងធ្ងន់ ។ មហាជនប្រជុំគ្នា ស្រែកតវ៉ានៅត្រង់ទីព្រះលានហ្លួង ។ ព្រះរាជាត្រាស់ឲ្យហៅវេលាមៈមក ហើយត្រាស់ថា បពិត្រលោកអាចារ្យ ជនបទត្រូវបៀតបៀន ព្រះរាជាទាំងឡាយរមែងធ្វើការប្ចូន់ជំ ក្នុងវេលាទៅ និងវេលាមក មនុស្សទាំងឡាយមិនអាចតាំងនៅស្ងប់បានលោកចូរធ្វើឧបាយណាមួយ ដើម្បីឲ្យជនបទស្ងប់ពីសេចក្តីបៀតបៀន ។ វេលាមៈក្រាបទូលថា បពិត្រមហារាជ ជាការល្អហើយ ខ្ញុំព្រះអង្គនឹងធ្វើឧបាយ ព្រះអង្គ មានសេចក្តីត្រូវការជនបទណា ព្រះអង្គចូលទ្រង់កំណត់ជនបទនោះ ហើយកាន់យក ។ ព្រះរាជាទ្រង់បានធ្វើយ៉ាងនោះ ។ វេលាមៈត្រាច់មើលក្នុងជនបទរបស់ព្រះរាជាទាំង ៨៤.០០០ ហើយ ទើបឲ្យប្រមូល

ចូលមកនៅក្នុងជនបទរបស់ព្រះរាជ ដូចរួបរួមការទេះទុកត្រង់ជុំ ដូច្នោះ ។ តាំងអំពីនោះមក ព្រះរាជាទាំងឡាយនោះ ស្ដេចមកក្ដី ស្ដេចទៅក្ដី រមែងត្រាច់ទៅតាមជនបទរៀងៗ ខ្លួន ប៉ុណ្ណោះ ទ្រង់មិនធ្វើការបូន់ ដោយទ្រង់ត្រិះរិះថា នេះជាជនបទរបស់យើងទាំងឡាយ ទ្រង់មិនបៀតបៀនសូម្បីជនបទរបស់ព្រះរាជា ដោយសេចក្ដីគោរពចំពោះព្រះរាជា ។ ជនបទទាំងឡាយក៏ស្ងប់ស្ងាត់មិនមានសំឡេងយំ ។ ព្រះរាជាទាំងឡាយទ្រង់រីករាយត្រេកអរ ទ្រង់បវារណាថា បពិត្រអាចារ្យ លោកត្រូវការដោយវត្ថុណា លោកចូរប្រាប់វត្ថុនោះដល់ខ្ញុំទាំងឡាយ ។

វេលាមៈផ្ងក់សីសៈ ហើយឲ្យបិទទ្វារបន្ទប់ពេញដោយរតនៈ ៧ ប្រការក្នុងនិវេសន៍របស់ខ្លួន ក្រឡេកមើលទ្រព្យដែលរក្សាទុក ៧ ជួរបុរសនៃត្រកូល ពិចារណាប្រាក់ចំណូល និងប្រាក់ចំណាយហើយ គិតថា យើងគួរឲ្យទាន ឲ្យឮសុះសាយទៅទូទាំងជម្ពូទ្វីប ហើយបានក្រាបទូលដល់ព្រះរាជា ឲ្យសាងចង្ក្រានទុកជាជួរប្រមាណ ១២ យោជន៍ ជិតច្រាំងទន្លេគង្គា ឲ្យសាងឃ្លាំងធំទុក ដើម្បីការរក្សាទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅ ប្រេង ល្ង

និងស្រូវជាដើម ក្នុងទីនោះៗ បានចាត់មនុស្សទាំងឡាយទុកថា ក្នុងទីនោះៗ ចូរចាត់មនុស្សប្រមាណប៉ុណ្ណេះៗ ទុក កាលរបស់ណាមួយដែលឈ្មោះថា ពួកមនុស្សនឹងគប្បីបាន សូម្បីត្រឹមតែមួយអស់ទៅ សូមលោកទាំងឡាយ គប្បីប្រាប់ដល់យើង ទើបឲ្យមនុស្សវាយស្គរ ដើរប្រកាសទូទៅក្នុងក្រុងថា សូមជនទាំងឡាយចូរបរិភោគទានរបស់វេលាមព្រាហ្មណ៍ តាំងពីថ្ងៃនេះ ។ កាលបុគ្គលអ្នកចាត់ការទានប្រាប់ថា រោងទានសម្រេចហើយ វេលាមៈក៏ស្លៀកដណ្តប់សំពត់តម្លៃមួយពាន់ ធ្វើសំពត់ចៀងស្មាតម្លៃ ៥០០ តាក់តែងគ្រឿងប្រដាប់គ្រប់យ៉ាង ដាក់ទឹកមានពណ៌ដូចកែវផលិកឲ្យពេញសុវណ្ណ-កិង្គារ (កំសៀវមាស) ហើយធ្វើសច្ចកិរិយាពិនិត្យមើលទានថា បើក្នុងលោកនេះ នៅមានទក្ខិណេយ្យបុគ្គលសមគួរទទួលទាននេះ សូមទឹកនេះហូរចេញហើយ ចូរសើមជ្រាបលើផែនដីចុះ បើមិនមាន ចូរតាំងនៅយ៉ាងនេះឯងហើយក៏បានផ្អៀងមាត់សុវណ្ណកិង្គារចុះ ។ ទឹកក៏ប្រាកដដូចជាបឹតទុកជាប់ក្នុងធម្មក្រក ។ ព្រះពោធិសត្វមិនបានទាស់ចិត្តថា ឱហ្ន៎ ជម្ពូទ្វីបសូន្យទទេរមែងមិនមានសូម្បីបុគ្គលម្នាក់ដែលគួរទទួលទក្ខិណា គិតហើយថា ប្រសិន

បើទក្ខិណានឹងបរិសុទ្ធិចំណែកទាយក សូមឲ្យទឹកហូរចេញទៅចុះ ចូរជ្រាបលើផែនដីទៅចុះ ។ ទឹកក៏ក្លាយជាពណ៌កែវផលិតហូរចេញ ហើយជ្រាបលើផែនដី ។ លោកចូលទៅរោងទានដោយគិតថា ឥឡូវនេះ យើងនឹងឲ្យទាន ក្រឡេកមើលទានហើយ ប្រើមនុស្សឲ្យបបរក្នុងវេលាបបរ ឲ្យរបស់ទំពារស៊ីក្នុងវេលាទំពារស៊ី និងឲ្យអាហារក្នុងវេលាអាហារនោះឯង ។ ព្រះពោធិសត្វបានឲ្យទានរាល់ៗ ថ្ងៃ ដោយទំនងនេះឯង ។ ឯក្នុងរោងទាននេះមិនមានពាក្យដែលនឹងគប្បីពោលថា ឈ្មោះវត្ថុនេះមាន ឈ្មោះវត្ថុនេះមិនមាន ។ ព្រះពោធិសត្វគិតថា ទាននេះនឹងមិនចប់ដោយហេតុត្រឹមតែប៉ុណ្ណោះ ទើបឲ្យនាំមាសចេញទៅធ្វើជាថាសមាស ហើយបញ្ជូនដំណឹងទៅដល់ព្រះរាជា ៨៤.០០០ ដើម្បីប្រយោជន៍ដល់ថាសមាស ៨៤.០០០ ថាសជាដើម ។ ព្រះរាជាទាំងឡាយទ្រង់ត្រិះរិះថា លោកអាចារ្យបានអនុគ្រោះពួកយើងមកយូរហើយ ទើបទ្រង់ឲ្យចាត់ចែងវត្ថុទាំងពួង បញ្ជូនទៅឲ្យ ។ ក្នុងកាលវេលាមព្រាហ្មណ៍ឲ្យទានដូច្នោះ វេលាក៏កន្លងទៅអស់ ៧ ឆ្នាំ ៧ ខែ ។ តមក វេលាមព្រាហ្មណ៍គិតថា យើងនឹងបែងចែកប្រាក់ឲ្យជាទាន ទើបឲ្យ

ចាត់ចែងទានត្រៀមទុកក្នុងឱកាសដ៏សំខាន់ លុះឲ្យត្រៀមស្រេចហើយ បាន ឲ្យថាសមាស ៨៤.០០០ ថាស តាំងអំពីដើមរហូតដល់ចុងក្រោយ ។

ក្នុងបទទាំងនោះ **រូបិយបូរានិ (ពេញដោយរូបិយៈ)** បានដល់ ពេញ ដោយថាសប្រាក់ ភាជនៈប្រាក់ និងមាសកៈប្រាក់ ។ ក៏ថាសទាំងឡាយ នរណាៗ មិនគួរកំណត់ថាតូច ។ ថាស ៤ ត្រូវប្រើទឹមានប្រមាណមួយ ករីសៈ ។ គម្របថាសជារតនៈ ៩ តាំងពីកណ្ដាប់មាត់សម្រេចជារតនៈ ៨ ។ រថសេះអាជានេយ្យដែលទឹមទុកព្រមហើយ រមែងរត់វិលនៅលើ កណ្ដាប់មាត់បាន ។ កាលឲ្យ ក៏បានឲ្យថាស ៨៤.០០០ ថាសយ៉ាងនេះ គឺ បានចាត់បដិគ្គាហកៈទុកជាពួកៗ មានចុងបំផុតនៅខាងក្រៅ ដាក់ក្នុង ថាសស្រេចហើយ លើកបញ្ជូនតគ្នាទៅរហូតដល់ខាងចុងនៃជួរ ។ សូម្បី ក្នុងពាក្យជាដើមថា **រូបិយបាតិ (ថាសរូបិយៈ)** ក៏មានន័យនេះដូចគ្នា ។ សូម្បីក្នុងបទនេះ បទថា **សុវណ្ណបូរានិ (ពេញដោយមាស)** បានដល់ ពេញ ដោយថាសមាស ភាជនៈមាស និងមាសកៈមាស ។ បទថា **ហិរញ្ញបូរានិ (ពេញដោយប្រាក់)** បានដល់ ពេញដោយរតនៈ ៧ យ៉ាង ។ បទថា

**សោវណ្ណាលង្ការានិ** (គ្រឿងប្រដាប់សុទ្ធតែមាស) បានដល់ គ្រឿងប្រដាប់ជាមាស ។ បទថា **កំសុបធារណានិ** (មានភាជនៈសំរិតទទួលទឹកដោះ) បានដល់ ភាជនៈទទួលទឹកដោះធ្វើដោយប្រាក់ ។ ចំណែកស្នែងទាំងពីររបស់មេគោទាំងនោះ បានពាក់ដោយស្រោមមាស ។ ត្រង់.កប្រដាប់ដោយកម្រងកែវម្ចិះ ត្រង់ជើងទាំង ៤ បានប្រដាប់ដោយគ្រឿងប្រដាប់ជើង ត្រង់ខ្នងគ្របដោយសំពត់សាច់ល្អដ៏ប្រសើរ ត្រង់.កមានចងកណ្ដឹងមាស ។ បទថា **វត្ថកោដិសហស្សានិ** (សំពត់ ៨៤.០០០ កោដិ ) បានដល់ សំពត់ ២០ គូ មនុស្សលោកហៅ ១ កោដិ តែក្នុងទីនេះ សំពត់ ១០ ផ្ទាំងៗ ហៅថា ១ កោដិ ។ ក្នុងបទជាដើមថា **ខោមសុខុមានំ** (ជាសំពត់សំបកឈើសាច់ល្អិត) គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បណ្ដាសំពត់សំបកឈើជាដើម សំពត់ណាៗ ជាសំពត់មានសាច់ល្អិត បានឲ្យហើយនូវសំពត់នោះៗ ប៉ុណ្ណោះ ។ ចំណែកទានពួកណាដែលឃើញហើយថា មិនមែនជាទាន គឺ ឥត្ថីទាន (ការឲ្យស្រីជាទាន) ឧសភទាន (ការឲ្យគោឧសភៈជាទាន) មជ្ជទាន (ការឲ្យទឹកស្រវឹងជាទាន) សមជ្ជទាន (ការឲ្យការលេងកំសាន្តជាទាន) នោះ

វេលាមព្រាហ្មណ៍បានឲ្យទានសូម្បីទាំងនោះ សម្រាប់ជាបរិវារដើម្បីកាត់ពាក្យនិយាយថា ឈ្មោះថា វត្ថុនេះក្នុងទានរបស់វេលាមៈរមែងមិនមាន ។ បទថា **នវជ្ជា មញ្ញេ វិស្សន្ទន្តិ** (ដូចជាស្ទឹងតែងហូរទៅ) បានដល់ រមែងហូរទៅដូចជាស្ទឹង ។

ព្រះសាស្តា ត្រាស់ទានរបស់វេលាមព្រាហ្មណ៍ដោយហេតុប្រមាណប៉ុណ្ណេះ ហើយត្រាស់ថា ម្នាលគហបតី បុគ្គលដទៃមិនបានឲ្យនូវមហាទាននោះ តថាគតបានឲ្យហើយ ក៏តថាគតសូម្បីកាលឲ្យទានបែបនោះ រកបុគ្គលសមគួរដើម្បីនឹងទទួលមិនមាន លោកបានឲ្យទានកាលព្រះពុទ្ធដូចជាតថាគតប្រាកដនៅក្នុងលោក ព្រោះហេតុអ្វី ទើបគិតដូច្នេះ ។ កាលទ្រង់បរិយាយទេសនាដល់សេដ្ឋី ទើបបានត្រាស់បទជាដើមថា **សិយា ខោ បន តេ** (ក៏លោកគប្បីមាន) ។ សួរថា ក៏រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណពួកណា មានហើយក្នុងកាលនោះ រូបជាដើមនោះ រលត់ហើយមិនមែនឬព្រោះហេតុអ្វី ព្រះមានព្រះភាគត្រាស់ថា សម័យនោះ តថាគតជាព្រាហ្មណ៍ឈ្មោះវេលាមៈ ។ ឆ្លើយថា ព្រោះមិនត្រូវកាត់សេចក្ដីជាប់តគ្នា ។ ព្រោះថា

រូបជាដើមនោះ កាលវេលត់ ក៏ឲ្យបច្ច័យដល់ខន្ធទាំង ៥ នេះហើយ ទើបវេលត់ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ក៏សំដៅដល់ការជាប់តគ្នាមកមិនដាច់ ។ បទថា **ន តំ កោចិ ទក្ខិណំ សោធេតិ (មិនមាននរណាៗ ធ្វើទក្ខិណានោះឲ្យបរិសុទ្ធ)** បានដល់ មិនមាននរណាៗ ជាសមណៈ ព្រាហ្មណ៍ ទេវតា ឬមារ ដែលបុគ្គលដទៃចេញមកបញ្ជាក់ថា រមែងជម្រះទក្ខិណាឲ្យបរិសុទ្ធបាន ។ ក៏អ្នកនឹងធ្វើទក្ខិណានោះឲ្យបរិសុទ្ធខ្ពង់ខ្ពស់ គឺ ព្រះពុទ្ធដោយទាបបំផុត គឺ សាវក ដូចជាព្រះធម្មសេនាបតីសារីបុត្រ គប្បីជម្រះឲ្យបរិសុទ្ធបាន ។

បទថា **ទិដ្ឋិសម្បន្នានំ (លោកអ្នកដល់ព្រមដោយទិដ្ឋិ)** បានដល់ បុគ្គលដែលដល់ព្រមដោយទស្សនៈ គឺ ព្រះសោតាបន្នៈ ។ បទថា **ឥទំ តតោ មហប្ផលតរំ (ទានដែល... មានផលច្រើនជាងទានដែលវេលាមព្រាហ្មណ៍ឲ្យជាមហាទាននោះ)** បានដល់ ទានដែលឲ្យហើយដល់បុគ្គលជាសោតា-បន្នៈនេះ មានផលច្រើនជាងទានដែលវេលាមព្រាហ្មណ៍ បរិច្ចាគមាសប្រាក់ប្រមាណប៉ុណ្ណេះឲ្យដល់លោកិយៈមហាជនអស់ ៧ ឆ្នាំ ៧ ខែ ។ ក្នុងបទ

នេះថា *យោ ច សតំ ទិដ្ឋិសម្បន្នានំ (បុគ្គលណាញុំាងបុគ្គលមានទិដ្ឋិល្អ ១ រូប ឲ្យបរិភោគ)* បានដល់ គប្បីជ្រាបការរាប់ព្រះសោតាបន្នបុគ្គល ១០១ នាក់ ស្មើព្រះសកទាគាមី ១ នាក់ ។ ដោយឧបាយនេះ គប្បីជ្រាបការរាប់បុគ្គលដោយធ្វើការគុណនឹង ១០០ តាមលំដាប់ ដែលមកហើយក្នុងខាងដើមៗ ក្នុងវារៈទាំងពួង ។

ក្នុងបទថា *ពុទ្ធប្បមុខំ (មានព្រះពុទ្ធជាប្រធាន)* នេះ សង្ឃដែលអង្គុយធ្វើព្រះសម្មាសម្ពុទ្ធឲ្យជាព្រះសង្ឃត្ថេរៈ គប្បីជ្រាបថា សង្ឃមានព្រះពុទ្ធជាប្រធាន ។ ក្នុងបទថា **ចាតុទ្ទិសំ សង្ឃំ ឧទ្ទិស្ស (ថ្វាយសង្ឃដែលមកអំពីទិសទាំង ៤)** ឈ្មោះថា វិហារដែលសាងថ្វាយសង្ឃដែលមកអំពីទិសទាំង ៤ គឺ ទីព្រះចេតីយ៍ដែលប្រតិស្ឋាន ធ្វើទីស្តាប់ព្រះធម៌ ទីដែលភិក្ខុទាំងឡាយមកអំពីទិសធំទាំង ៤ និងទិសតូច ហើយមិនត្រូវសាកសួរលាងជើងហើយ យកសោរបិទទ្វារ ធ្វើការសម្អាតសេនាសនៈ ស្នាក់នៅហើយ រមែងទៅបានតាមសប្បាយ វិហារនោះដោយទីបំផុតសូម្បីជាបណ្ណ-សាលាមានប្រមាណ ៤ ហត្ថ ក៏ហៅថា វិហារដែលសាងថ្វាយសង្ឃដែល

មកអំពីទិសទាំង ៤ ដូចគ្នា ។

ក្នុងបទថា **សរណំ គច្ឆេយ្យ** (ដល់... ជាសរណៈ) ទ្រង់បំណង យកសរណៈដែលមិនវិលត្រឡប់ ដែលបានមកហើយដោយមគ្គ ។ អាចារ្យ ពួកខ្លះពោលថា ការដល់សរណៈ មានផលច្រើនជាងវិហារទាននោះ ព្រោះ ប្រគល់ខ្លួនឲ្យហើយ ។ បទថា **សិក្ខាបទំ សមាទិយេយ្យ** (សមាទាន **សិក្ខាបទ**) បានដល់ កាន់យកបញ្ចសីល ។ សូម្បីសីល ក៏ត្រាស់សំដៅ យកសីលដែលមិនវិលត្រឡប់នោះឯង ដែលមកហើយដោយមគ្គ ។ អាចារ្យ ពួកខ្លះពោលថា ឈ្មោះថា សីល មានផលច្រើនជាងសរណគមន៍នោះ ព្រោះខ្លួនឲ្យអភ័យទានហើយដល់សត្វទាំងពួង ។ បទថា **គន្ធូហនមត្តំ** (បិដក **គទ្ទូហនមត្តំ**) (**ត្រឹមតែវេលាស្រូបក្លិនផ្កា**) បានដល់ ត្រឹមខណៈហិតក្លិនផ្កា គឺ ត្រឹមតែយកម្រាមដៃពីរចាប់យកដុំនៃគ្រឿងក្រអូបមកស្រូបក្លិន ។ ចំណែក អាចារ្យពួកខ្លះ ពោលព្រះបាលីថា **គោទោហនមត្តំ** ទើបបានពោលដោយ ន័យថា ត្រឹមតែយកទឹកដោះរបស់មេគោបន្តក់ក្អែកតែម្តង ។

បទថា **មេត្តចិត្តំ** (**មេត្តាចិត្ត**) បានដល់ ចិត្តដែលផ្សាយប្រយោជន៍

ដ៏ទូលាយដល់សត្វទាំងពួង ។ តែចិត្តនោះ ទ្រង់បានកាន់យកហើយដោយអំណាចអប្បនាប៉ុណ្ណោះ ។ បទថា **អនិច្ចសញ្ញំ** (អនិច្ចសញ្ញា) បានដល់វិបស្សនាដែលមានកម្លាំងជាអនន្តរប្បច្ច័យដល់មគ្គ ។ ចំណែកបុណ្យទាំងឡាយ មានទានជាដើមនេះ គប្បីជ្រាបដោយឧបាយយ៉ាងនេះ ។ ក៏ប្រសិនបើថា គេធ្វើជម្ពូទីបឲ្យជាផ្ទៃស្មើដូចជាផ្ទៃស្គរ ក្រាលបល្ល័ង្កតាំងអំពីដើមហើយគប្បីឲ្យព្រះអរិយបុគ្គលអង្គុយនៅក្នុងទីនោះ មានសោតាបន្នបុគ្គល ១០ ជួរ សកទាគាមីបុគ្គល ៥ ជួរ អនាគាមិបុគ្គលពីរជួរកន្លះ ព្រះខីណាស្រពមួយជួរកន្លះ ព្រះបច្ចេកពុទ្ធមួយជួរ ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គឯងប៉ុណ្ណោះ ទានដែលបុគ្គលថ្វាយចំពោះតែព្រះសម្មាសម្ពុទ្ធ មានផលច្រើនជាង ទានដែលថ្វាយហើយដល់ជនប្រមាណប៉ុណ្ណោះ ចំណែកទានក្រៅពីនេះ

គឺ វិហារទាន បិណ្ឌបាត សិក្ខា ការចម្រើនមេត្តា រមែងមិនដល់ចំណៀកទី ១៦ របស់បុគ្គលដែលពិចារណាដោយការអស់ទៅ ។

ព្រោះហេតុនោះឯង ព្រះមានព្រះភាគទើបត្រាស់ទុកក្នុងសម័យនឹងបរិនិព្វានថា ការបដិបត្តិធម៌សមគួរដល់ធម៌ ជាការបូជាដ៏ឧត្តម បទដ៏សេស

*ក្នុងទីទាំងពួង មានសេចក្ដីងាយយល់ហើយនោះឯង ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា វេលាមសូត្រទី ១០

## ចប់សីហនាទវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# សត្តាវាសវគ្គវណ្ណនាទី ៣

## អដ្ឋកថា ឋានសូត្រទី ១

### *ឋានៈដែលទេវតា និងមនុស្សប្រសើរជាងគ្នា*

*គប្បីជ្រាបវិនិច្ឆ័យក្នុងឋានៈសូត្រទី ១ ដូចតទៅនេះ៖*

[២១] *បទថា* ***ឧត្តរកុរុកា*** *(អ្នកឧត្តរកុរុទ្វីប) បានដល់ ជនអ្នកនៅក្នុងឧត្តរកុរុទ្វីប ។ បទថា* ***អធិគណ្ហន្តិ*** *(ប្រសើរជាង) បានដល់ រមែងជាធំ គឺ ជាអ្នកប្រសើរ ជាអ្នកចម្រើនបំផុត ។ បទថា* ***អមមា*** *(មិនមានទុក្ខ) បានដល់ មិនមានតណ្ហា ។ ចំណែកក្នុងអដ្ឋកថាលោកពោលថា មិនមានទុក្ខ ។ បទថា* ***អបរិគ្គហា*** *(មិនមានសេចក្តីអន្ទះសា) បានដល់ វៀរចាកការអន្ទះសា ថា វត្ថុនេះរបស់យើង ។ បទថា* ***និយតាយុកា*** *(មានអាយុទៀង) បានដល់ ក៏បុគ្គលទាំងឡាយនោះ មានអាយុមួយពាន់ឆ្នាំស្មើគ្នា សូម្បីគតិក៏ស្មើគ្នា ជនទាំងនោះស្លាប់អំពីនោះហើយ រមែងកើតក្នុងសួគ៌ប៉ុណ្ណោះ ។ បទថា* ***សតិមន្តោ*** *(ជាអ្នកមានសតិ) បានដល់ ក៏ពួកទេវតា*

រមែងមានសតិមិនតាំងមាំ ព្រោះមានសេចក្តីសុខដោយចំណែកមួយ ចំណែកមនុស្សជម្ពូទ្វីបទាំងនេះ ឈ្មោះថា មានសតិតាំងមាំ ព្រោះមានទាំងសុខទាំងទុក្ខលាយគ្នា ។ បទថា **ឥធ ព្រហ្មចរិយវាសោ (មានការប្រព្រឹត្តព្រហ្មចារ្យក្នុងជម្ពូទ្វីបនេះ)** បានដល់ សូម្បីការនៅប្រព្រឹត្តមគ្គព្រហ្មចារ្យដែលប្រកបដោយអង្គ ៨ រមែងមានតែក្នុងទ្វីបនេះប៉ុណ្ណោះ ព្រោះព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធ ឧប្បត្តិឡើងក្នុងជម្ពូទ្វីប ។

ចប់អដ្ឋកថា ឋានសូត្រទី ១

# អដ្ឋកថា ខឡុង្កសូត្រទី ២

## សេះល្អ សេះខូក មនុស្សល្អ មនុស្សខូក

*គប្បីជ្រាបវិនិច្ឆ័យក្នុង ខឡុង្កសូត្រទី ២ ដូចតទៅនេះ ៖*

[២២] *បទថា ជវសម្បន្នោ (មានសន្ទុះជើងល្អ) បានដល់ ដល់ព្រមដោយកាពរហ័សនៃជើង ។ បទថា ន វណ្ណសម្បន្នោ (សម្បុរមិនល្អ) បានដល់ មិនសម្បូរដោយសម្បុរកាយ ។ ក្នុងបុរសខូក មានវិនិច្ឆ័យដូច្នេះ ។ បទថា ជវសម្បន្នោ (ដែលសម្បូរដោយសន្ទុះ) បានដល់ អ្នកសម្បូរដោយសន្ទុះ គឺ ញាណ ។ បទថា ន វណ្ណសម្បន្នោ (មិនសម្បូរដោយគុណសម្បត្តិ) បានដល់ មិនដល់ព្រមដោយវណ្ណៈ គឺ គុណ ។ បទដ៏សេស គប្បីជ្រាបដោយន័យនៃបាលីនោះចុះ ។ ក៏ក្នុងព្រះសូត្រនេះ គួរនឹងពោលដល់ប្រការណា ប្រការនោះ បានអធិប្បាយទុកហើយក្នុងអដ្ឋកថាតិកនិបាតនោះឯង ។*

ចប់អដ្ឋកថា ខឡុង្កសូត្រទី ២

# អដ្ឋកថា តណ្ហាសូត្រទី ៣

## ធម៌មានតណ្ហាជាមូល ៩ ប្រការ

*គប្បីជ្រាបវិនិច្ឆ័យក្នុង តណ្ហាសូត្រទី ៣ ដូចតទៅនេះ ៖*

*[២៣] បទថា* ***តណ្ហំ បដិច្ច*** *(ព្រោះអាស្រ័យតណ្ហា) បានដល់ តណ្ហា ២ យ៉ាង គឺ* ***ឯសនតណ្ហា*** *(តណ្ហាក្នុងការស្វែងរក) និង* ***ឯសិតតណ្ហា*** *(តណ្ហាក្នុងភោគៈដែលស្វែងរកបានហើយ) ។ បុគ្គលដើរទៅតាមផ្លូវពពៃ និងផ្លូវដែលមានជន្លត់ដើមឈើជាដើម ស្វែងរកភោគៈដោយតណ្ហាណា តណ្ហានេះឈ្មោះថា* ***ឯសនតណ្ហា*** *។ តណ្ហាណា កាលបុគ្គលស្វែងរកបានភោគៈហើយ តណ្ហានេះឈ្មោះថា* ***ឯសិតតណ្ហា*** *។ តែក្នុងសូត្រនេះ គប្បីឃើញថា គឺ* ***ឯសនតណ្ហា*** *។ បទថា* ***បរិយេសនា (ការស្វែងរក)*** *បានដល់ ការស្វែងរកអារម្មណ៍ មានរូបជាដើម ក៏កាលឯសនតណ្ហាមាន ការស្វែងរកនោះក៏រមែងមាន ។ បទថា* ***លាភោ (ការបាន)*** *បានដល់ ការបានអារម្មណ៍មានរូបជាដើម ក៏ការស្វែងរកមាន ការបានក៏រមែងមាន ។*

*បទថា* ***វិនិច្ឆយោ (ការវិនិច្ឆ័យ)*** *មាន ៤ យ៉ាង គឺ ញាណវិនិច្ឆ័យ*

តណ្ហាវិនិច្ឆ័យ ទិដ្ឋិវិនិច្ឆ័យ និងវិតក្កវិនិច្ឆ័យ ។ ក្នុងវិនិច្ឆ័យ ៤ យ៉ាងនោះ វិនិច្ឆ័យនេះថា បុគ្គលគប្បីដឹងដល់សុខវិនិច្ឆ័យ[១] លុះដឹងដល់សុខវិនិច្ឆ័យហើយ គប្បីបំពេញឲ្យដល់សេចក្តីសុខក្នុងខាងក្នុង ឈ្មោះថា ញាណវិនិច្ឆ័យ ។ ក្នុងបទថា ពាក្យថា **វិនិច្ឆយា** បានដល់ វិនិច្ឆ័យពីរយ៉ាង គឺ តណ្ហាវិនិច្ឆ័យ និងទិដ្ឋិវិនិច្ឆ័យ ។ តណ្ហាវិចរិត ១០៨ ឈ្មោះថា តណ្ហាវិនិច្ឆ័យ , ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិវិនិច្ឆ័យ ។ តែក្នុងទីនេះ វិតក្កៈប៉ុណ្ណោះ ហៅថា វិនិច្ឆ័យ ដូចដែលមកក្នុងសូត្រនេះថា **ឆន្ទោ ខោ ទេវានមិន្ទ វិតក្កនិទានោ** (ស្តេចទេវតា ឆន្ទៈនេះឯងមានវិតក្កៈជាដែនកើត) ដូច្នេះ ។ បុគ្គលសូម្បីបានលាភហើយ ក៏នៅពិចារណាដល់វត្ថុដែលគួរពេញចិត្ត និងមិនគួរពេញចិត្ត ដល់វត្ថុល្អ និងមិនល្អដោយវិតក្កៈថា ប៉ុណ្ណេះនឹងមានដើម្បីរូបារម្មណ៍ដល់យើង ប៉ុណ្ណេះនឹងមានដើម្បីសទ្ទារម្មណ៍ដល់យើង ប៉ុណ្ណេះនឹងមានដល់យើង ប៉ុណ្ណេះនឹងមានដល់អ្នកដទៃ យើងនឹងបរិភោគប៉ុណ្ណេះ

---

(១) ដីកា = គឺ ញាណដែលដឹងសេចក្តីសុខដោយសភាវៈ ដោយហេតុកើត រលត់ ជាទោស ដោយគ្រឿងរលាស់ចេញ និងតាមសេចក្តីពិត ហើយប្រព្រឹត្តទៅ ។

យើងនឹងរក្សាទុកប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា លាភំ បដិច្ច វិនិច្ឆយោ (ការវិនិច្ឆ័យព្រោះអាស្រ័យការបាន) ។

បទថា **ឆន្ទរាគោ** (ឆន្ទរាគៈ) បានដល់ រាគៈដែលខ្សោយ និងរាគៈដែលមានកម្លាំង រមែងកើតឡើងក្នុងវត្ថុដែលត្រិះរិះដោយអកុសលវិតក្កៈនេះ ។ ពិតហើយ ពាក្យថា **ឆន្ទៈ** ក្នុងសូត្រនេះ ជាឈ្មោះរបស់រាគៈដែលខ្សោយ ។ បទថា **អជ្ឈោសានំ** (សេចក្តីជឿស៊ប់) បានដល់ ការកាត់ក្តីដែលមានកម្លាំងថា យើង របស់យើង ។ បទថា **បរិគ្គហោ** (សេចក្តីហួងហែង) បានដល់ ការធ្វើការប្រកាន់ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បទថា **មច្ឆរិយំ** (សេចក្តីកំណាញ់) បានដល់ ការអត់ទ្រាំចំពោះរបស់ទូទៅនៃអ្នកដទៃមិនបាន ព្រោះហេតុនោះឯង បុរាណាចារ្យទើបពោល អត្ថនៃសេចក្តីកំណាញ់នោះ យ៉ាងនេះថា ហៅថា សេចក្តីកំណាញ់ ព្រោះប្រព្រឹត្តទៅហើយថា សូមសេចក្តីអស្ចារ្យនេះចូរមានដល់យើងប៉ុណ្ណោះ សូមចូរកុំមានដល់អ្នកដទៃឡើយ ដូច្នេះ ។ បទថា **អារក្ខា** (ការរក្សា) បានដល់ ការរក្សាទុកដោយល្អ ដោយបិទទ្វារ និងរក្សាទុកក្នុងហិបជាដើម ។ ឈ្មោះថា

*អធិករណៈ ព្រោះអត្ថថា ធ្វើឲ្យក្រៃលែង ពាក្យនោះជាឈ្មោះរបស់ហេតុ ។ បទថា* ***អារក្ខាធិករណំ (ព្រោះការរក្សាជាហេតុ)*** *ជានបុំសកលិង្គ ភាវសាធនៈ អធិប្បាយថា ហេតុនៃការរក្សា ។ ក្នុងបទថា* ***ការចាប់កំណាត់ឈើជាដើម*** *គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ការកាន់កំណាត់ឈើដើម្បីការពារដល់អ្នកដទៃ ។ ឈ្មោះថា* ***ទណ្ឌាទានំ (ការចាប់កំណាត់ឈើ)*** *។ ការកាន់សស្ត្រាមានកាំបិតមុខម្ខាងជាដើម ឈ្មោះថា* ***សត្ថាទានំ (ចាប់សស្ត្រា)*** *។ ការឈ្លោះគ្នាដោយកាយក្តី ការឈ្លោះគ្នាដោយវាចាក្តី ឈ្មោះថា* ***កលហោ (ការឈ្លោះគ្នា)*** *ពាក្យដំបូងជា* ***វិគ្គហោ (ការវែកញែក)*** *ពាក្យក្រោយជា* ***វិវាទោ (ការវិវាទ)*** *។ បទថា* ***តុវំតុវំ (អាមឹងឯងហង)*** *បានដល់ និយាយពាក្យអាមឹងឯងហង ព្រោះមិនគោរពគ្នា ។*

ចប់អដ្ឋកថា តណ្ហាសូត្រទី ៣

# អដ្ឋកថា វិវត្តសញ្ញាសូត្រទី ៤

## សញ្ញាជាគ្រឿងកំណត់សត្វ

គប្បីជ្រាបវិនិច្ឆ័យក្នុង វិវត្តសញ្ញាសូត្រទី ៤ ដូចតទៅនេះ ៖

[២៤] បទថា *សត្តាវាសា (សត្តាវាសៈ)* បានដល់ ទីនៅរបស់សត្វទាំងឡាយ អធិប្បាយថា ជាទីកន្លែងនៅ ។ ក្នុងពាក្យនោះ សូម្បីសុទ្ធាវាសក៏ជាសត្តាវាសដូចគ្នា តែទ្រង់មិនបានបញ្ជាក់ទុក ព្រោះសុទ្ធាវាសមិនមានរហូតអស់កាល ។ ព្រោះថា សុទ្ធាវាស ដូចជាកន្លែងសម្រាប់ស្នាក់របស់ព្រះពុទ្ធទាំងឡាយ កាលបើព្រះពុទ្ធទ្រង់មិនទាន់បានឧប្បត្តិរហូតអស់អសង្ខេយ្យកប្ប ទីនោះក៏ទទេ ព្រោះហេតុនោះ ទើបទ្រង់មិនបញ្ជាក់ទុកព្រោះសុទ្ធាវាស មិនមានរហូតអស់កាលទេ ។ ពាក្យដ៏សេសក្នុងសូត្រនេះគប្បីជ្រាបដោយន័យដែលពោលហើយក្នុងវិញ្ញាណដ្ឋិតិនោះឯង ។

ចប់អដ្ឋកថា វិវត្តសញ្ញាសូត្រទី ៤

# អដ្ឋកថា បឋមសិលាយូបសូត្រទី ៥

## ចិត្តប្រៀបដូចសសរថ្ម

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមសិលាយូបសូត្រទី ៥ ដូចតទៅនេះ ៖

[២៥] បទថា **យតោ** (ក្នុងកាលណា) បានដល់ កាលណា ។ បទថា **សុបរិចិតំ ហោតិ** (អប់រំ... ឲ្យល្អ) បានដល់ អប់រំល្អហើយ ។ បទថា **កល្លំ វចនាយ** (គួរហៅ) បានដល់ គួរដើម្បីនឹងពោល ។ បទថា **វីតរាគំ** (ប្រាសចាករាគៈ) បានដល់ មានរាគៈទៅប្រាសហើយ ។ បទថា **អសារាគធម្មំ** (មិនមានរាគៈជាធម្មតា) បានដល់ អស់សភាពដែលនឹងឲ្យត្រេកអរដោយរាគៈ ។ បទថា **អនាវត្តិធម្មំ** (មិនវិលមក... ជាធម្មតា) បានដល់ អស់សភាពត្រឡប់មក គឺ មិនគួរកើតតទៅទៀត អធិប្បាយថា មានសភាពរលត់ស្អិទ្ធ ដោយមិនមានបដិសន្ធិតទៅទៀតឡើយ ។ ក្នុងសូត្រនេះ ត្រាស់ដល់ព្រះខីណាស្រពប៉ុណ្ណោះ ។

ចប់អដ្ឋកថា បឋមសិលាយូបសូត្រទី ៥

# អដ្ឋកថា ទុតិយសិលាយូបសូត្រទី ៦

## ចិត្តប្រៀបដូចសសរថ្ម

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយសិលាយូបសូត្រទី ៦ ដូចតទៅនេះ ៖

[២៦] បទថា **ចន្ទិកាបុត្តោ** (ព្រះចន្ទិកាបុត្រ) បានដល់ ព្រះថេរៈឈ្មោះចន្ទិកាបុត្រ ប្រាកដឈ្មោះតាមនាមមាតា ។ បទថា **ចេតសា ចិត្តំ សុបរិចិតំ ហោតិ** (អប់រំចិត្តឲ្យល្អដោយចិត្ត) បានដល់ ការប្រព្រឹត្តទៅនៃការប្រព្រឹត្តរបស់ចិត្តដែលភិក្ខុអប់រំល្អហើយ គឺ ចម្រើនល្អហើយ ឲ្យខ្ពស់ៗ ឡើងទៅ ដោយការប្រព្រឹត្តទៅនៃការប្រព្រឹត្តរបស់ចិត្ត ។ បទថា **នេវស្ស ចិត្តំ បរិយាទិយន្តិ** (រូបទាំងនោះក៏គ្របសង្កត់ចិត្តអ្នកមិនបាន) បានដល់ អារម្មណ៍ទាំងនោះមិនអាចដើម្បីគ្របសង្កត់ចិត្តុប្បាទរបស់ព្រះខីណាស្រពនោះឲ្យអស់ទៅ ហើយតាំងនៅបាន ។ បទថា **អមិស្សីកតំ** (មិនលាយដោយរូបទាំងនោះ) បានដល់ ចិត្តមិនលាយឡំដោយអារម្មណ៍ទាំងនោះ ព្រោះអារម្មណ៍ទាំងមិនជាប់តាម ។ បទថា **អានេញ្ជប្បត្តំ** (ដល់ការមិនញាប់ញ័រ) បានដល់ ការមិនញាប់ញ័រ គឺ មិនរន្ធត់ ។ បទថា **សិលា-**

យូបោ (សសរថ្ម) (សិលាត្ថម្ភោ) ។ បទថា **សោឡសកុក្កុកោ** (ប្រវែង ១៦ ហត្ថ) បានដល់ ប្រវែង ១៦ ហត្ថ ។ បទថា **ហេដ្ឋានេមស្ស** (លិចចុះទៅក្នុងរណ្តៅ) បានដល់ លិចចុះទៅក្រោមរណ្តៅ ។ បទថា **ឧបរិ-នេមស្ស** (ខាងលើរណ្តៅ) បានដល់ លើរណ្តៅ ។ បទថា **សុនិខាតត្តា** (កប់ជ្រៅ) បានដល់ យកអង្រែដែកជំឲ្យកប់ចូលជ្រៅ ។ ក្នុងបទថា **ឯវមេវ** ដែលកើតឡើងក្នុងទ្វារ ៦ ដូចខ្យល់ព្យុះ គប្បីជ្រាបថា កិលេសដែលកើតឡើងក្នុងទ្វារ ៦ មិនអាចញុាំង ចិត្តរបស់ព្រះខីណាស្រពឲ្យញាប់ញ័របានឡើយ ដូចកាលដែលខ្យល់បក់មកអំពីទាំងទិស ៤ មិនអាចឲ្យសសរថ្មញាប់ញ័របាន ដូច្នោះ ។ សូម្បីក្នុងសូត្រនេះ ព្រះសារីបុត្រក៏ពោលដល់ព្រះខីណាស្រពប៉ុណ្ណោះ ។

ចប់អដ្ឋកថា ទុតិយសិលាយូបសូត្រទី ៦

# អដ្ឋកថា បឋមវេរសូត្រទី ៧

## ធម៌ធ្វើឲ្យមាំមួន

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមវេរសូត្រទី ៧ ដូចតទៅនេះ ៖*

[២៧] *បទថា* ***ភយំ វេរំ បសវតិ*** *(រមែងប្រសព្វនូវភ័យ និងពៀរ) បានដល់ ប្រសព្វភ័យដែលកើតអំពីចិត្តភ័យខ្លាច និងពៀរកើតអំពីបុគ្គល ។ បទថា* ***ចេតសិកំ*** *(ផ្លូវចិត្ត) បានដល់ អាស្រ័យចិត្ត ។ បទថា* ***ទុក្ខំ*** *(ទុក្ខ) បានដល់ ទុក្ខមានកាយជាទីតាំង ។ បទថា* ***ទោមនស្សំ*** *(ទោមនស្ស) បានដល់ ទុក្ខដែលសម្បយុត្តដោយការប៉ះខ្ទប់ ។ ក្នុងសូត្រនេះ ព្រះមាន-ព្រះភាគត្រាស់ដល់សោតាបត្តិមគ្គ ។*

ចប់អដ្ឋកថា បឋមវេរសូត្រទី ៧

# អដ្ឋកថា ទុតិយវេរសូត្រទី ៨

## ធម៌ធ្វើឲ្យមាំមួន

[២៨] ទុតិយសូត្រទី ៨ ព្រះមានព្រះភាគត្រាស់ដល់ពួកភិក្ខុ តែនៅក្នុងសូត្រនេះ លោកពោលថា ព្រះមានព្រះភាគត្រាស់ដល់ព្រះសោតាបន្នប៉ុណ្ណោះ ។

ចប់អដ្ឋកថា ទុតិយវេរសូត្រទី ៨

# អដ្ឋកថា បឋមអាឃាតសូត្រទី ៩

## ហេតុកើតនៃសេចក្តីអាឃាត

គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមអាឃាតសូត្រទី ៩ ដូចតទៅនេះ ៖

[២៩] បទថា *អាឃាតវត្ថូនិ (អាឃាតវត្ថុ)* បានដល់ ហេតុនៃសេចក្តីអាឃាត ។ បទថា *អាឃាតំ ពន្ធតិ (អ្នកចងសេចក្តីក្រោធ)* បានដល់ ចងសេចក្តីក្រោធ គឺ ធ្វើសេចក្តីក្រោធឲ្យកើតឡើង ។

ចប់អដ្ឋកថា បឋមអាឃាតសូត្រទី ៩

# អដ្ឋកថា ទុតិយអាឃាតសូត្រទី ១០

## *ហេតុកម្ចាត់សេចក្ដីក្រោធ ៩ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ទុតិយអាឃាតសូត្រទី ១០ ដូចតទៅនេះ ៖*

*[៣០] បទថា **អាឃាតប្បដិវិនយា** (ហេតុជាគ្រឿងកម្ចាត់សេចក្ដីក្រោធ) បានដល់ ហេតុនៃការកម្ចាត់បង់សេចក្ដីក្រោធ ។ បទថា **តំ កុតេត្ថ លព្ភា** (ក្នុងបុគ្គលនេះ តថាគតគប្បីបានការប្រព្រឹត្តប្រយោជន៍អំពីទីណាហ្ន៎) សេចក្ដីថា តថាគតនឹងគប្បីបានក្នុងបុគ្គលនេះអំពីណា គឺ តថាគតអាចនឹងបានដោយហេតុណាថា ការប្រព្រឹត្តមិនជាប្រយោជន៍នោះ កុំមានឡើយ ។ បុគ្គលគិតយ៉ាងនេះថា ធម្មតាមនុស្សដទៃនឹងធ្វើសេចក្ដីវិនាសដល់អ្នកដទៃតាមសេចក្ដីពេញចិត្តរបស់ខ្លួន ហើយកម្ចាត់នូវអាឃាតចេញបាន ។ ម្យ៉ាងទៀត អធិប្បាយថា បើយើងគប្បីធ្វើសេចក្ដីក្រោធតប ការធ្វើសេចក្ដីក្រោធនោះ យើងនឹងគប្បីបានក្នុងបុគ្គលនេះអំពីណា គឺ យើងអាចនឹងបានដោយហេតុណា ។ បាឋៈថា **តំ កុតោ លាភា** ដូច្នេះក៏មាន ។ អធិប្បាយថា ប្រសិនបើយើងគប្បីធ្វើសេចក្ដីក្រោធក្នុងបុគ្គលនេះ ក្នុងការ*

ធ្វើសេចក្ដីក្រោធរបស់យើងនោះ នឹងបានលាភអំពីណា ឈ្មោះថា លាភអ្វីនឹងគប្បីមាន ។ ក៏ពាក្យថា តំ ក្នុងអត្ថនេះ ក៏ជានិបាតប៉ុណ្ណោះ ។

ចប់អដ្ឋកថា ទុតិយអាឃាតសូត្រទី ១០

# អដ្ឋកថា អនុបុព្វនិរោធសូត្រទី ១១

## *ការរលត់តាមលំដាប់ ៩ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុបុព្វនិរោធសូត្រទី ១១ ដូចតទៅនេះ ៖*

[៣១] *បទថា* ***អនុបុព្វនិរោធា*** ***(ការរលត់តាមលំដាប់)*** *បានដល់ រលត់ទៅដោយលំដាប់ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយហើយ ។*

ចប់អដ្ឋកថា អនុបុព្វនិរោធសូត្រទី ១១

## ចប់សត្តាវាសវគ្គវណ្ណនាទី ៣

ក្នុងវគ្គនេះ មាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១១ សូត្រ

# មហាវគ្គវណ្ណនាទី ៤

## អដ្ឋកថា បឋមវិហារសូត្រទី ១

### *អនុបុព្វវិហារ ៩ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុបុព្វវិហារសូត្រទី ១ ដូចតទៅនេះ ៖*

[៣២] *បទថា* ***អនុបុព្វវិហារា (អនុបុព្វវិហារ)*** *បានដល់ ធម៌ដែលជាគ្រឿងនៅ ដែលព្រះយោគាវចរគួរចូលដល់តាមលំដាប់ ។*

ចប់អដ្ឋកថា អនុបុព្វវិហារសូត្រទី ១

# អដ្ឋកថា ទុតិយវិហារសូត្រទី ២

## *អនុបុព្វវិហារសមាបត្តិ ៩ ប្រការ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង អនុបុព្វវិហារសូត្រទី ២ ដូចតទៅនេះ ៖*

[៣៣] *បទថា **យត្ថ កាមា និរុជ្ឈន្តិ (កាមទាំងឡាយរមែងរលត់ក្នុងទីណា)** បានដល់ កាមទាំងឡាយរមែងស្ងប់ទៅក្នុងទីណា ។ បទថា **និរោធេត្វា (រលត់... បានហើយ)** បានដល់ មិនត្រឡប់កើតទៀតឡើយ ។ បទថា **និច្ឆាតា (មិនមានសេចក្តីប្រាថ្នា)** បានដល់ អស់ប្រាថ្នា ព្រោះមិនមានសេចក្តីប្រាថ្នា គឺ តណ្ហា និងទិដ្ឋិតទៅ ។ បទថា **និព្វុតា (រលត់ស្និទ្ធហើយ)** បានដល់ រលត់ទុក្ខ ព្រោះមិនមានកិលេសជាគ្រឿងធ្វើឲ្យក្តៅក្រហាយក្នុងខាងក្នុង ។ បទថា **តិណ្ណា (ឆ្លងបានហើយ)** បានដល់ ឆ្លងផុតកាមទាំងឡាយ ។ បទថា **បារគតា (ដល់ត្រើយហើយ)** បានដល់ កន្លងត្រើយនៃកាម ។ បទថា **តទង្គេន (ដោយអង្គឈាននោះ)** បានដល់ ដោយអង្គនៃឈាននោះ ។ បទថា **ឯត្ថ កាមា និរុជ្ឈន្តិ (កាមទាំងឡាយរមែងរលត់ក្នុងបឋមឈាននេះ)** បានដល់ កាមទាំងឡាយរមែងរលត់ក្នុង*

*បឋមឈានទេះ ។ បទថា* ***តេ ច*** *(និងលោកទាំងនោះ) បានដល់ អ្នកណាចូលបឋមឈាន អ្នកនោះឈ្មោះថា វេលតកាមទាំងឡាយហើយ ។ បទថា* ***បញ្ជលិកោ*** *(ធ្វើអញ្ជលី) បានដល់ ជាអ្នកផ្គងអញ្ជលី ។ បទថា* ***បយិរុបាសេយ្យ*** *(ចូលទៅអង្គុយជិត) បានដល់ គប្បីចូលទៅទទួលបម្រើ ។ គប្បីជ្រាបសេចក្តីក្នុងពាក្យទាំងពួងដោយទំនងនេះចុះ ។*

ចប់អដ្ឋកថា ទុតិយវិហារសូត្រទី ២

# អដ្ឋកថា និព្វានសូត្រទី ៣

## និព្វានជាសុខដ៏ក្រៃលែង

គប្បីជ្រាបវិនិច្ឆ័យក្នុង និព្វានសូត្រទី ៣ ដូចតទៅនេះ ៖

[៣៤] បទថា *ឧទាយិ (ឧទាយី)* បានដល់ ព្រះលោឡុទាយីថេរៈ ។ បទថា *ឯតទេវ ខ្វេត្ថ (ព្រះនិព្វាននេះ... នោះឯង)* កាត់បទជា *ឯតទេវ ខោ ឯត្ថ* ។ បទថា *កាមសហគតា (ដែលសហគតដោយកាម)* បានដល់ ដែលអាស្រ័យកាម ។ បទថា *សមុទាចរន្តិ (រមែងផុស្សាយឡើង)* បានដល់ ត្រាច់ទៅក្នុងមនោទ្វារ ។ បទថា *អាពាធាយ (ដើម្បីបៀតបៀន)* បានដល់ ដើម្បីបៀតបៀន គឺ ញាំញី ។ បទថា *បរិយាយេន (ដោយបរិយាយ)* បានដល់ ដោយហេតុ ។ គប្បីជ្រាបសេចក្តីក្នុងវារៈទាំងអស់យ៉ាងនេះ ។ ក្នុងសូត្រនេះ ព្រះសារីបុត្រពោលដល់សុខដែលមិនមានវេទនា (អវេទយិតសុខ) ។

ចប់អដ្ឋកថា និព្វានសូត្រទី ៣

# អដ្ឋកថា គាវីសូត្រទី ៤

## *ឧបមាការរកអាហាររបស់មេគោ*

## *នឹងការបដិបត្តិរបស់ភិក្ខុ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង គាវីសូត្រទី ៤ ដូចតទៅនេះ ៖*

[៣៥] *បទថា* ***បត្យេយ្យា (ដើរទៅកាន់ភ្នំ)*** *បានដល់ មេគោដើរទៅតាមភ្នំ ។ បទថា* ***ន សុប្បតិដ្ឋិតំ បតិដ្ឋាបេត្វា (ញ៉ាំងជើងមុខចេញទៅក៏មិនល្អ)*** *បានដល់ មិនញ៉ាំងជើងមុខទុកឲ្យល្អ ។ បទថា* ***តំ និមិត្តំ (នូវនិមិត្តនោះ)*** *បានដល់ និមិត្ត គឺ បឋមឈាននោះ ។ បទថា* ***ន ស្វាធិដ្ឋិតំ អធិដ្ឋាតិ (មិនអធិដ្ឋាននិមិត្តនោះឲ្យល្អ)*** *បានដល់ មិនតាំងចិត្តទុកដោយល្អ ។ បទថា* ***អនភិហិសមានោ (មិនត្រេកអរត្រឹមតែ)*** *បានដល់ មិនពេញចិត្តត្រឹមតែ ។ បទថា* ***មុទុ ចិត្តំ ហោតិ កម្មនិយំ (ចិត្ត... ជាចិត្តទន់គួរដល់ការងារ)*** *បានដល់ វិបស្សនាចិត្តជាចិត្តទន់ អត់ទ្រាំដល់ការងារ គួរប្រកបការងារ ក្នុងខណៈនៃលោកុត្តរមគ្គ យ៉ាងណា ចិត្តក្នុងចតុត្ថជ្ឈានដែលជាផ្លូវប្រព្រឹត្តទៅនៃអភិញ្ញារបស់ភិក្ខុនោះ រមែងជាចិត្តទន់*

គួរដល់ការងារ ដូច្នោះ ។ បទថា **អប្បមាណោ សមាធិ** (នូវសមាធិដែលរកប្រមាណមិនបាន) បានដល់ សមាធិក្នុងព្រហ្មវិហារ ៤ ក្តី សមាធិក្នុងមគ្គផលក្តី ឈ្មោះថា សមាធិដែលរកប្រមាណមិនបាន តែក្នុងសូត្រនេះ សំដៅដល់អារម្មណ៍ដែលរកប្រមាណមិនបាន ព្រោះហេតុនោះ គប្បីឃើញថា សមាធិដែលជំនាញដោយល្អ ជាអប្បមាណសមាធិដោយបរិយាយនេះ ។ បទថា **សោ អប្បមាណេន សមាធិ សុភាវិតេន** (អ្នក... ដោយសមាធិដែលរកប្រមាណមិនបាន ដែលចម្រើនល្អហើយ) បានដល់ ភិក្ខុនេះចម្រើនវិបស្សនាក្នុងឋានៈនេះហើយ ក៏សម្រេចព្រះអរហត្ត ។ ឥឡូវនេះ ព្រះមាន-ព្រះភាគ កាលនឹងទ្រង់សំដែងតាមលំដាប់នៃអភិញ្ញារបស់ព្រះខីណាស្រព ទើបត្រាស់បទមានជាអាទិ៍ថា **យំ យស្សេវ** (ណាៗ នោះឯង) ដូច្នេះ ។

ចប់អដ្ឋកថា គាវីសូត្រទី ៤

# អដ្ឋកថា ឈានសូត្រទី ៥

## *អស់អាសវៈព្រោះអាស្រ័យឈាន*

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឈានសូត្រទី ៥ ដូចតទៅនេះ ៖*

[៣៦] *បទថា* ***អាសវានំ ខយំ (ការអស់ទៅនៃអាសវៈទាំងឡាយ)*** *បានដល់ ព្រះអរហត្ត ។ បទថា* ***យទេវ តត្ថ ហោតិ រូបគតំ (រូប... ដែលមាននៅក្នុងបឋមឈាននោះ)*** *បានដល់ ធម្មតារូបណាមែងប្រព្រឹត្ត ទៅក្នុងខណៈនៃបឋមឈាននោះ ដោយអំណាចជាទីតាំងក្តី ដោយមានចិត្ត ជាសមុដ្ឋានក្តី ។ គប្បីជ្រាប* ***វេទនាគតា (វេទនា)*** *ជាដើម ដោយអំណាច សម្បយុត្តវេទនា (វេទនាដែលប្រកបគ្នា) ជាដើម ។ បទថា* ***តេ ធម្មេ (ធម៌ទាំងឡាយនោះ)*** *បានដល់ ធម៌ គឺ បញ្ចក្ខន្ធ មានរូបជាដើមនោះឯង ។*

*ក្នុងបទទាំងឡាយមានជាអាទិ៍ថា* ***អនិច្ចតោ (ដោយភាពជារបស់ មិនទៀង)*** *គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា* ***ដោយភាពជារបស់ មិនទៀង*** *ព្រោះអាការមានហើយក៏មិនមានវិញ ឈ្មោះថា* ***ទុក្ខតោ (ជាទុក្ខ)*** *ព្រោះអាការបៀតបៀន ឈ្មោះថា* ***រោគតោ (ជារោគ)*** *ព្រោះអាការចាក់*

ដោត ឈ្មោះថា **គណ្ឌតោ** (ជាបូស) ព្រោះអត្ថថា ប្រទូសរាយខាងក្នុង ឈ្មោះថា **សល្លតោ** (ដូចជាកូនសរ) ព្រោះអត្ថថា មុតចូលទៅហើយ ដោយអត្ថថា ទម្លុះចូលទៅ ឈ្មោះថា **អឃតោ** (មិនមានសុខ) ព្រោះអត្ថថា ចិត្តជាទុក្ខ ឈ្មោះថា **អាពាធតោ** (ជាអាពាធ) ព្រោះអត្ថថា បៀត-បៀន ឈ្មោះថា **បរតោ** (ជារបស់ដទៃ) ព្រោះអត្ថថា មិនមែនជារបស់ខ្លួន ឈ្មោះថា **បលោកតោ** (ជារបស់ទ្រុឌទ្រោម) ព្រោះអត្ថថា វិនាសទៅ ឈ្មោះថា **សុញ្ញតោ** (សូន្យទទេ) ព្រោះអត្ថថា មិនមានម្ចាស់ ឈ្មោះថា **អនត្តតោ** (ជាអនត្តា) ព្រោះអត្ថថា មិននៅក្នុងអំណាច ។ បទថា **សម-នុបស្សតិ** (រមែងពិចារណាឃើញ) បានដល់ ឃើញដោយវិបស្សនាញាណដែលចាស់ក្លា ។ បទថា **តេហិ ធម្មេហិ** (ដោយធម៌ទាំងនោះ) បានដល់ ដោយធម៌ គឺ បញ្ចក្ខន្ធទាំងនោះ ។ បទថា **បតិដ្ឋាបេតិ** (រមែង... ឲ្យតាំងនៅ) បានដល់ រមែងឲ្យវិលត្រឡប់ដោយសេចក្ដីនឿយណាយ ។ បទថា **អមតាយ ធាតុយា** (ដើម្បីអមតធាតុ) បានដល់ និព្វានធាតុ ។ បទថា **ចិត្តំ ឧបសំហរតិ** (រមែងបង្អោនចិត្តទៅ) បានដល់ ឃើញដោយវិបស្សនា-

ញាណដ៏ចាស់ក្លា លុះឃើញអានិសង្សដោយញាណហើយរមែងឈានចុះ ។ បទថា **សន្តំ** (ស្ងប់) បានដល់ ឈ្មោះថា ស្ងប់ ព្រោះស្ងប់ចាកកិលេសដែលជាសត្រូវ ។ បទថា **បណីតំ** (ប្រណីត) បានដល់ មិនក្តៅក្រហាយ ។ បទថា **សោ តត្ថ ឋិតោ អាសវានំ ខយំ បាបុណាតិ** (**បុគ្គលតាំងនៅក្នុងបឋមឈាននោះ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ**) បានដល់ ភិក្ខុនោះតាំងនៅក្នុងបឋមឈាននោះ ចម្រើនវិបស្សនាចាស់ក្លាហើយ រមែងសម្រេចព្រះអរហត្ត ។

គប្បីជ្រាបន័យម្យ៉ាងទៀត បទថា **សោ តេហិ ធម្មេហិ** (**បុគ្គល... ដោយធម៌ទាំងនោះ**) បានដល់ ព្រោះក្នុងពាក្យថា **ដោយភាពជារបស់មិនទៀង** ជាដើម ព្រះមានព្រះភាគត្រាស់ដល់អនិច្ចលក្ខណៈដោយ ២ បទ គឺ **ដោយភាពជារបស់មិនទៀង ជារបស់ទ្រុឌទ្រោម** ត្រាស់ដល់ទុក្ខលក្ខណៈដោយ ៦ បទ មានបទថា **ជាទុក្ខ** ជាដើម ត្រាស់ដល់អនត្តលក្ខណៈដោយ ៣ បទ គឺ **ជារបស់ដទៃ សូន្យទទេ ជាអនត្តា** ដូច្នោះ ភិក្ខុនោះលើកឡើងកាន់ត្រៃលក្ខណ៍យ៉ាងនេះហើយ (រមែងញ៉ាំងចិត្តឲ្យតាំងនៅ) ដោយ

ធម៌ គឺ បញ្ចក្ខន្ធក្នុងខាងក្នុងសមាបត្តិ ដែលខ្លួនឃើញហើយទាំងនោះ ។ បទថា **ចិត្តំ បតិដ្ឋាបេតិ** (រមែងញុំាងចិត្តឲ្យតាំងនៅ) បានដល់ នាំចេញព្រលែង ដោះចិត្តចេញ ។ បទថា **ឧបសំហរតិ** (រមែងបង្អោន) បានដល់ ភិក្ខុបង្អោនវិបស្សនាចិត្តទៅដើម្បីអមតធាតុ ដែលមិនមានបច្ច័យតាក់តែងយ៉ាងនេះថា **និព្វានស្ងប់ដោយទីនៅ**[១] **ដោយការសរសើរ ដោយបរិយត្តិនិងដោយបញ្ញត្តិ** , ភិក្ខុរមែងពោល[២]ដល់និព្វានដែលជាមគ្គចិត្តយ៉ាងនេះថា នោះស្ងប់ នោះប្រណីត ដោយធ្វើឲ្យជាអារម្មណ៍ប៉ុណ្ណោះ អធិប្បាយថា ភិក្ខុចាក់ធ្លុះធម៌នោះដោយប្រការនេះ រមែងបង្អោនចិត្តចូលទៅក្នុងធម៌នោះ ។ បទថា **សោតត្ថ ឋិតោ** (លោកតាំងនៅក្នុងបឋមឈាននោះ) បានដល់ ភិក្ខុតាំងនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ ។ បទថា **អាសវានំ ខយំ បាបុណាតិ** (រមែងដល់ការអស់ទៅនៃអាសវៈទាំងឡាយ) បានដល់ ភិក្ខុចម្រើនមគ្គ ៤ តាមលំដាប់ហើយ រមែងសម្រេចព្រះអរហត្ត ។

---

(១) ភូមា = ដោយការស្ដាប់ , (២) រមែងមិនពោល ។

បទថា **តេនេវ ធម្មរាគេន** (ដោយសេចក្ដីត្រេកអរ... ក្នុងធម៌នោះឯង) បានដល់ ឆន្ទរាគៈក្នុងធម៌ គឺ សមថៈ និងវិបស្សនា ។ បទថា **ធម្មនន្ទិយា** (ភ្លើតភ្លើនក្នុងធម៌) ជាវេវចនៈរបស់បទថា **ធម្មរាគេន** (ត្រេកអរ... ក្នុងធម៌) នោះឯង ។ ពិតហើយ ភិក្ខុកាលអាចនឹងគ្របសង្កត់ឆន្ទរាគៈក្នុងសមថៈ និងវិបស្សនាបានដោយប្រការទាំងពួង រមែងសម្រេចព្រះអរហត្តបាន កាលមិនអាច ក៏នឹងជាព្រះអនាគាមី ។ បទថា **តិណបុរិសកេ វា** (រូបទីងមោងធ្វើដោយស្មៅ) បានដល់ រុំស្មៅជារូបមនុស្ស ។ ឈ្មោះថា **ទូរេបាតី** (បាញ់បានឆ្ងាយ) ព្រោះអត្ថថា បាញ់កូនសរឲ្យធ្លាក់ទៅឆ្ងាយ ។ ឈ្មោះថា **អក្ខណវេធី** (បាញ់មិនខុស) ព្រោះអត្ថថា បាញ់មិនខុស ។

ក្នុងបទថា **យទេវ តត្ថ ហោតិ វេទនាគតំ** (វេទនា... ដែលមាននៅក្នុងអាកាសានញ្ចាយតនឈាននោះ) នេះ មិនកាន់យករូប ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះឈានកន្លងទៅហើយ ។ ពិតហើយ ព្រះយោគាវចរនេះ ចូលដល់រូបាវចរឈានខាងដើម លុះឈានកន្លងរូបហើយ ចូលដល់អរូបាវចរសមាបត្តិ គឺ ព្រះយោគាវចរនេះ ឈានកន្លងរូប

ដោយអំណាចសមថៈ លុះពិចារណារូបខាងក្រោមហើយ ឈានកន្លងរូបទៅ ក្នុងពេលនេះរមែងពិចារណាអរូប គឺ ព្រះយោគាវចរនេះ ឈានកន្លងរូប ដោយអំណាចវិបស្សនា ក៏ក្នុងអរូប រមែងមិនមានរូបសូម្បីដោយប្រការទាំងពួង ព្រោះហេតុនោះ ក្នុងទីនេះមិនកាន់យករូប ព្រោះសំដៅសេចក្តីនេះ ។ សួរថា បើដូច្នោះ ព្រោះហេតុអ្វីទើបទ្រង់មិនកាន់យកនេវសញ្ញា-នាសញ្ញាយតនឈាននោះ ។ ឆ្លើយថា ព្រោះជារបស់ល្អិត ។ ពិតហើយ ក្នុងនេវសញ្ញានាសញ្ញាយតនឈាននោះ សូម្បីអរូបក្ខន្ធ ៤ ក៏ជារបស់ល្អិត ពិចារណាមិនបាន សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ***ឥតិ ខោ ភិក្ខវេ យាវតា សញ្ញាសមាបត្តិ តាវតា អញ្ញាបដិវេធោ (ម្នាលភិក្ខុទាំងឡាយ ដោយប្រការដូច្នេះឯង សញ្ញាសមាបត្តិមានប៉ុណ្ណា បដិវេធ គឺព្រះអរហត្តក៏មានប៉ុណ្ណោះ)*** ។ ប្រការនេះ មានអធិប្បាយដូច្នេះ ឈ្មោះថា សចិត្តកសមាបត្តិមានប៉ុណ្ណា ការចាក់ធ្លុះដល់ព្រះអរហត្តរមែងមានដល់អ្នកពិចារណាធម៌ដែលជារបស់គ្រោតគ្រាត មានប្រមាណប៉ុណ្ណោះ គេរមែងដល់ព្រះអរហត្ត តែនេវសញ្ញានាសញ្ញាយតនឈាន មិនពោលថា ជាសញ្ញា-

សមាបត្តិ ព្រោះជារបស់ល្អិត ។

បទថា ឈាយីហេតេ (ឈានទាំងនេះ ដែលភិក្ខុអ្នកបានឈាន) បានដល់ ឈានទាំងនេះ ដែលបុគ្គលអ្នកបានឈាន គឺ អ្នកត្រេកអរក្នុងឈាន ។ បទថា វុដ្ឋហិត្វា (ចេញហើយ) បានដល់ ចេញចាកសមាបត្តិនោះហើយ ។ បទថា សម្មទក្ខាតព្វានិ (គប្បីពោលដោយប្រពៃ) បានដល់ គប្បីពោលបានត្រឹមត្រូវ ។ បុគ្គលគប្បីពោល គប្បីរីករាយ គប្បីសរសើរ ត្រឹមតែម្យ៉ាង យ៉ាងនេះថា ស្ងប់ ប្រណីត ដូច្នេះ ។

ចប់អដ្ឋកថា ឈានសូត្រទី ៥

# អដ្ឋកថា អានន្ទសូត្រទី ៦

## ព្រះអានន្ទសំដែងបុគ្គលមិនសោយអាយតនៈ

គប្បីជ្រាបវិនិច្ឆ័យក្នុង អានន្ទសូត្រទី ៦ ដូចតទៅនេះ ៖

[៣៧] បទថា **សម្ពាធេ (ក្នុងទីចង្អៀត)** បានដល់ ក្នុងទីចង្អៀត គឺ កាមគុណ ៥ ។ បទថា **ឱកាសាធិគមោ (ការបានឱកាស)** បានដល់ ការបានចន្លោះ ។ បទថា **សត្តានំ វិសុទ្ធិយា (ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ)** បានដល់ ដើម្បីញុំាងសត្វទាំងឡាយឲ្យដល់សេចក្តីបរិសុទ្ធ ។ បទថា **សមតិក្កមាយ (ដើម្បីឈានកន្លង)** បានដល់ ដើម្បីប្រយោជន៍ដល់ការឈានកន្លងទៅ ។ បទថា **អត្ថង្គមាយ (ដើម្បីរលត់)** បានដល់ ដើម្បីប្រយោជន៍ដល់ការរលត់ទៅ ។ បទថា **ញាយស្ស អធិគមាយ (ដើម្បីសម្រេចញាយធម៌)** បានដល់ ដើម្បីប្រយោជន៍ដល់ការសម្រេចមគ្គព្រមដោយវិបស្សនា ។ បទថា **និព្វានស្ស សច្ឆិកិរិយាយ (ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន)** បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើនិព្វានដែលរកបច្ច័យមិនបានឲ្យឃើញប្រចក្ស ។ បទថា **តទេវ នាម ចក្ខុំ ភវិស្សតិ**

(ភ្នែកឈ្មោះថាជាភ្នែកនោះឯង) បានដល់ ចក្ខុបសាទនោះឯង ជាវត្ថុមិនលាយឡំគ្នា ។ បទថា **តេ រូបា** (រូបទាំងនោះ) បានដល់ រូបារម្មណ៍នោះឯង នឹងមកកាន់កន្លងចក្ខុបសាទ ។ បទថា **តញ្ចាយតនំ នោ បដិសំវេទិស្សតិ** (អាយតនៈនោះនឹងមិនសោយរូបទាំងនោះ) បានដល់ ភ្នែកនោះនឹងមិនដឹងរូបាយតនៈនោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **ព្រះឧទាយី** បានដល់ ព្រះកាឡុទាយិថេរៈ ។ បទថា **សញ្ញីមេវ នុ ខោ** (អ្នកមានសញ្ញាឬ...ហ្ន៎) បានដល់ ជាអ្នកមានចិត្តឬហ្ន៎ ។ ម អក្សរត្រឹមតែជាការតបទ ។ បទថា **កឹ សញ្ញី** (អ្នកមានសញ្ញាដូចម្តេច) បានដល់ ជាអ្នកមានសញ្ញាដោយសញ្ញាប្រភេទណា ។ ក្នុងបទថា **សព្វសោ រូបសញ្ញានំ** (រូបសញ្ញាដោយប្រការទាំងពួង) សួរថា ព្រោះហេតុអ្វី ព្រះអានន្ទទើបកាន់យករូបសញ្ញានេះ ការសោយអារម្មណ៍ មានរូបារម្មណ៍ជាដើម រមែងមានដល់បុគ្គលដែលព្រមព្រៀងដោយបឋមឈានជាដើមឬ ។ ឆ្លើយថា ការសោយអារម្មណ៍មានរូបជាដើម រមែងមិនមាន ក៏កសិណរូបនៅជាអារម្មណ៍ត្រឹមណា រូបឈ្មោះថា នៅមិនទាន់ឈានកន្លង

ទៅត្រឹមណោះ កសិណរូបនោះនឹងអាចជាបច្ច័យ ព្រោះនៅមិនទាន់កន្លងទៅ តែព្រះអានន្ទកាន់យកពាក្យនេះឯងដើម្បីសំដែងថា ក៏កសិណរូបនោះព្រោះមិនទាន់ឈានកន្លងទៅ[១] ទើបឈ្មោះថា មិនមាន គឺ មិនអាចដើម្បីជាបច្ច័យបាន ព្រោះការមិនមាន ។

បទថា *ជដិលគាហិយា (ជដិលគាហិយៈ)* បានដល់ ភិក្ខុនីអ្នកនៅក្នុងក្រុងជដិលគហៈ ។ ក្នុងបទថា *ន ចាភិណតោ (ដែលកិលេសបង្អោនទៅមិនបាន)* ជាដើម គប្បីជ្រាបសេចក្តីដូចតទៅនេះ សមាធិ ឈ្មោះថា *ន អាភិនតោ (ដែលកិលេសបង្អោនទៅមិនបាន)* ដោយអំណាចរាគៈ *ន អបនតោ (នាំទៅមិនបាន)* ដោយអំណាចទោសៈ បទថា *ន សង្ខារនិគ្គយ្ហវារិតវតោ (មិនមានការគ្របសង្កត់ ការហាមដោយធម៌ដែលប្រព្រឹត្តទៅជាមួយសង្ខារ)* ព្រោះអត្ថថា សង្កត់សង្កិនកិលេសទាំងឡាយដោយការបបួលដឹកនាំដោយការប្រកបហើយតាំងនៅ ក៏មិនមែន តែកើតឡើងបានក្នុងកាលកាត់កិលេសបានហើយ ។ បទថា *វិមុត្តត្តា ឋិតោ (តាំងមាំហើយ*

(១) ភូមា = ព្រោះឈានកន្លងទៅហើយ ។

ព្រោះរួចផុតចាកកិលេស) បានដល់ ឈ្មោះថា តាំងនៅហើយ ព្រោះរួចផុត កិលេសទាំងឡាយនោះឯង ។ បទថា **ឋិតត្តា សន្តុសិតោ** (ត្រេកអរហើយ ព្រោះតាំងមាំ) បានដល់ ឈ្មោះថា ត្រេកអរហើយ ព្រោះតាំងមាំហើយ នោះឯង ។ បទថា **សន្តុសិតត្តា នោ បរិតស្សតិ** (មិនតក់ស្លុត ព្រោះត្រេកអរហើយ) បានដល់ មិនដល់សេចក្ដីតក់ស្លុត ព្រោះជាអ្នកត្រេកអរហើយ ។ ដោយបទថា **អយំ ភន្តេ អានន្ទ សមាធិ កឹផលោ** (សមាធិនេះ... មានអ្វីជាផល) នេះ ព្រះថេរីកាន់យកសមាធិក្នុងអរហត្តផល ហើយសួរថា បពិត្រព្រះអានន្ទ សមាធិនេះដែលព្រះមានព្រះភាគត្រាស់ថា មានអ្វីជាផល ដូចកាន់យកផ្លែត្នោតហើយ សួរថា ផ្លែនេះឈ្មោះថា ផ្លែអ្វី ។ បទថា **អញ្ញាផលោ វុត្តោ** (ត្រាស់ថា មានព្រះអរហត្តជាផល) បានដល់ ព្រះមានព្រះភាគត្រាស់ហៅព្រះអរហត្តថា **អញ្ញា** អធិប្បាយថា ឈ្មោះថា សមាធិក្នុងអរហត្តនោះ ដែលព្រះមានព្រះភាគត្រាស់ទុកហើយ ។ បទថា **ឯវំសញ្ញីបិ** (សូម្បីអ្នកដែលមានសញ្ញាយ៉ាងនេះឯង) បានដល់ សូម្បីមានសញ្ញាដោយសញ្ញាក្នុងអរហត្តផលនេះ ក៏មិនសោយអាយតនៈនោះ ព្រោះ

*ហេតុនោះ ក្នុងសូត្រនេះ ព្រះអានន្ទពោលដល់សមាធិក្នុងអរហត្តផល ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា អានន្ទសូត្រទី ៦

# អដ្ឋកថា ព្រាហ្មណសូត្រទី ៧

## ត្រាស់ការដល់ទីបំផុតលោកដល់ព្រាហ្មណ៍

គប្បីជ្រាបវិនិច្ឆ័យក្នុង ព្រាហ្មណ៍សូត្រទី ៧ ដូចតទៅនេះ ៖

[៣៨] បទថា **លោកាយតិកា** បានដល់ ព្រាហ្មណ៍អ្នករៀនគម្ពីរលោកាយតៈ (វិជ្ជាដែលប្រកាន់ថា លោកកើតអំពីការរួមនៃវត្ថុធាតុ ៤) ។ បទថា **សតតំ (ជាប់តគ្នា)** បានដល់ មិនមានរវាងចន្លោះ ។ បទថា **តិដ្ឋតេតំ (ប្រការដែល... ផ្អាកទុកសិនចុះ)** កាត់បទជា **តិដ្ឋតុ ឯតំ** បានដល់ ពួកអ្នកកុំផ្តើមដល់រឿងនេះឡើយ រឿងនេះនឹងមានប្រយោជន៍អ្វីដល់ពួកអ្នក ។ បទថា **ធម្មំ វោ ព្រាហ្មណា ទេសេស្សាមិ (ម្នាលព្រាហ្មណ៍តថាគតសំដែងធម៌ដល់អ្នកទាំងឡាយ)** បានដល់ តថាគតនឹងសំដែងចតុសច្ចធម៌ដល់ពួកអ្នក ។ បទថា **ទឡ្ហធម្មោ (កាន់ធ្នូធ្ងន់)** បានដល់ ឈរកាន់ធ្នូធ្ងន់ ។ បទថា **ធនុគ្គហោ (នាយខ្មាន់ធ្នូ)** អ្នកបាញ់ធ្នូ ។ លោកហៅធ្នូដែលប្រើកម្លាំង ២.០០០ នាក់ ថា ធ្នូធ្ងន់ ។ ទម្ងន់ទឹក ១ ភារៈ[១]

---

(១) ១ ភារៈ ឧម្ងន់ ២.០០០ បៈលៈ ។ ១ បៈលៈ ធ្ងន់ស្មើនឹងឧម្ងន់ទឹក ១.៦០០ គ្រាប់ស្រូវ ។

នៃដុំលោហៈជាដើម ដែលគេចងទុកត្រង់ខ្សែនៃធ្នូណាដែលត្រូវទាញ ដែលបុគ្គលចាប់ធ្នូហើយលើកឡើងប្រមាណត្រឹម.ក ឲ្យផុតអំពីផែនដី ធ្នូនោះឈ្មោះថា ធ្នូដែលប្រើកម្លាំង ២.០០០ ។ បទថា **សិក្ខិតោ (សិក្សាមក)** បានដល់ រៀនសិល្បៈក្នុងសំណាក់អាចារ្យរហូត ១០ ឆ្នាំ ១២ ឆ្នាំ ។

បទថា **កតហត្ថោ (មានដៃស្ទាត់ហើយ)** បានដល់ អ្នកបាញ់ធ្នូម្នាក់រៀនសិល្បៈនោះនៅមិនទាន់ស្ទាត់ជំនាញ តែអ្នកបាញ់ធ្នូនេះ ជាអ្នកស្ទាត់ជំនាញហើយ គឺ ជាអ្នកមានជំនាញដែលសន្សំល្អហើយ ។ បទថា **កតុ-បាសនោ (ប្រឡងមានថ្វីដៃហើយ)** បានដល់ បានសំដែងថ្វីដៃក្នុងរាជត្រកូលជាដើមមកហើយ ។ បទថា **លហុកេន អសនេន (យកព្រួញដ៏ស្រាល)** បានដល់ ដោយកូនសរដ៏ស្រាល ធ្វើខាងក្នុងឲ្យមានប្រហោង យកសំឡីគរជាដើមញាត់ឲ្យពេញ ធ្វើជាគ្រឿងសម្គាល់ ។ ពិតហើយ កូនសរធម្មតាបាញ់ទៅបានចម្ងាយត្រឹម ១ ឧសភៈ កាលធ្វើយ៉ាងនេះហើយ រមែងស្ទុះទៅបាន ២ ឧសភៈ ។ល។ កូនសរធម្មតាបាញ់ទៅបានចម្ងាយត្រឹម ៨ ឧសភៈ តែកូនសរដែលធ្វើហើយរមែងបាញ់ទៅបានចម្ងាយ ១៦ ឧសភៈ ។ បទថា

*អប្បកសិរេន (ដោយងាយ)* បានដល់ ដោយមិនលំបាក ។ បទថា *អតិ-
បាតេយ្យ (បាញ់រំលង)* បានដល់ កន្លងទៅបាន ។ មានពាក្យអធិប្បាយថា
នាយខ្មាន់ធ្នូនោះ បាញ់កូនធ្នូនោះកន្លងស្រមោលប្រមាណ ១ ចំអាម ៤
ធ្នាប់ បានយ៉ាងរហ័ស យ៉ាងណា បុគ្គលអ្នកមានជំហានដើររហ័ស អាច
ឈានកន្លងសកលចក្រវាឡបាន យ៉ាងរហ័ស ក៏ដូច្នោះ ។ បទថា *សន្ធា-
វនិកាយ (ដោយការរត់)* បានដល់ រត់ទៅដោយជើង ។ បទថា *ឯវមា-
ហំសុ (ពោល... យ៉ាងនេះ)* បានដល់ រមែងពោលយ៉ាងនេះ ។

ចប់អដ្ឋកថា ព្រាហ្មណសូត្រទី ៧

# អដ្ឋកថា ទេវសូត្រទី ៨

## ទេវាសុរសង្គ្រាម និងការផ្ចាញ់មារ

គប្បីជ្រាបវិនិច្ឆ័យក្នុង ទេវសូត្រទី ៨ ដូចតទៅនេះ ៖

[៣៩] បទថា ***សមុបព្យូឡ្ហា អហោសិ*** (បានប្រកៀកគ្នា) បានដល់ បានប្រឡូកកៀកមុខគ្នានឹងគ្នា ។ បទថា ***សង្គាមេយ្យាម*** (គប្បីធ្វើសង្គ្រាម) បានដល់ ធ្វើសង្គ្រាម គឺ ច្បាំងគ្នា ។ បទថា ***អបយ្យឹសុ្វ*** បាននាំគ្នា គេចចេញទៅ) បានដល់ ពួកទេវតានាំគ្នាលបគេចចេញទៅ ។ បទថា ***ឧត្តរាភិមុខា*** (តម្រង់ទៅទិសខាងជើង) បានដល់ បែរមុខទៅទិសឧត្តរ ។ បទថា ***អភិកយន្តេវ*** (នាំគ្នាដេញតាមមក) បានដល់ រមែងជាប់តាមទៅនោះឯង ។ បទថា ***ភីរុត្តាណគតេន*** (បានគ្រៀងការពារខ្លួនចាកការភ័យខ្លាចហើយ) បានដល់ បានគ្រៀងការពារភ័យ បានគ្រៀងហាមភ័យ បាននូវទីពឹង ។ បទថា ***អករណីយា*** (ធ្វើអ្វីយើងមិនបាន) បានដល់ ពួកអសុរធ្វើការច្បាំងអ្វីៗ មិនបាន ។

សួរថា ក៏ព្រោះហេតុអ្វី ពួកទេវតា និងអសុរទើបច្បាំងគ្នា ។ ឆ្លើយ

ថា ព្រោះពួកអសុរធ្លាប់នៅក្នុងភពតាវតឹង្សមកអំពីមុន លុះដល់វេលាផ្កាចិត្តបាតលិរីក ពួកអសុររឭកដល់ផ្កាបារិច្ឆត្តកៈជាទិព្វ តពីនោះ ពួកអសុរកើតសេចក្តីក្រោធឡើង ហើយពោលថា ពួកអ្នកចូរចាប់ទេវតា ទើបនាំគ្នាឡើងកាន់ភ្នំសិនេរុ ច្បាំងគ្នា ចំណែកពួកទេវតាក៏នាំគ្នាចេញមក ។ ការច្បាំងរបស់ទេវតា និងអសុរទាំងនោះ ដូចជាពួកក្មេងឃ្វាលគោយកកំណាត់ឈើវាយគ្នា ។ សក្កទេវរាជតាំងរក្សាទុកក្នុងទី ៥ កន្លែងនៅជាន់ក្រោម ចំណែកក្នុងជាន់លើ ទ្រង់ឲ្យតាំងរូបដូចព្រះអង្គ ព្រះហស្តទ្រង់វជិរាវុធ ហែហមដោយទេវបុរី ។ ពួកអសុរផ្តេកទី ៥ នៃជាន់ខាងក្រោមក៏ឡើងទៅ បានឃើញរូបព្រះឥន្ទ្រ ក៏នាំគ្នាត្រឡប់ទៅកាន់អសុរបុរីមួយរំពេច ។

បទថា **ទក្ខិណេនាភិ មុខា (ឆ្ពោះមុខទៅទិសខាងត្បូង)** បានដល់ បែរមុខទៅទិសខាងត្បូង ។ បទថា **អបទំ ពន្ធិត្វា (ឲ្យជាប់តាមស្នាមជើងមិនបាន)** បានដល់ មិនឲ្យមានស្នាមជើង មិនឲ្យសល់ស្នាមជើងទុកដើម្បីឲ្យជាប់តាម ។ បទថា **អទស្សនំ គតោ (ឲ្យមើលមិនឃើញ)** បានដល់ សូម្បីមារក៏ដឹងចិត្តរបស់ភិក្ខុអ្នកចូលរូបាវចរចតុត្ថឈាន ដែលមានវត្ថុៈជា

*បាទ ដឹងចិត្តរបស់ភិក្ខុអ្នកចូលសមាបត្តិ ដែលមានវិបស្សនាជាបាទនោះឯង មាររមែងមិនដឹងចិត្តរបស់ភិក្ខុអ្នកចូលអរូបាវចរសមាបត្តិ ដែលមានវដ្តៈជាបាទ ឬមានវិបស្សនាជាបាទ ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា អទស្សនំគតោ បាបិមតោ (បិទ... អ្នកមានបាបឲ្យមើលមិនឃើញ)* ដូច្នេះ ។

ចប់អដ្ឋកថា នៃសូត្រទី ៨

# អដ្ឋកថា នាគសូត្រទី៩

## ការគេចចេញចាកពួករបស់ស្តេចដំរី និងភិក្ខុ

គប្បីជ្រាបវិនិច្ឆ័យក្នុង នាគសូត្រទី ៩ ដូចតទៅនេះ ៖

[៤០] បទថា **អារញ្ញកស្ស (ព្រៃ)** បានដល់ នៅក្នុងព្រៃ ។ បទថា **គោចរប្បសុតស្ស (ត្រាច់រកចំណី)** បានដល់ ទៅរកអាហារ ។ បទថា **ហត្ថិកុឡភាចិ (ដំរីស្ទាវ)** បានដល់ កូនដំរីដែលទើបនឹងធំ ។ **ហត្ថិច្ឆាបាចិ (កូនដំរី)** បានដល់ កូនដំរីតូច ។ បទថា **ឱភគ្គោភគ្គំ (បានកាច់បាក់ខ្ទេចខ្ទីហើយ)** បានដល់ ប្រយ័តឲ្យទន់ចុះមក ។ បទថា **ឱគាហំ ឱតិណ្ណស្ស (ចុះកាន់ស្រះ)** បានដល់ ដំរីចុះកាន់កំពុងទឹកដែលបានឈ្មោះថា ឱគាហៈ ព្រោះជាទីដែលដំរីគប្បីចុះទៅបាន ។ បទថា **ឱគាហា ឧត្តិណ្ណស្ស (ឡើងពីស្រះ)** បានដល់ ដំរីឡើងអំពីកំពង់ទឹក ។ បទថា **វូបកដ្ឋោ (ចៀសចេញ)** បានដល់ ជាអ្នកចៀសចេញទៅតែម្នាក់ឯង ។ ឥឡូវនេះ ព្រោះព្រះទសពលមិនមានកិច្ចដោយស្តេចដំរី តែព្រះអង្គទ្រង់នាំព្រះតម្រាស់នេះមក ដើម្បីសំដែងដល់បុគ្គលប្រៀបដូចដំរីនោះ ក្នុងព្រះសាសនា ដូច្នោះ កាលព្រះអង្គ

*ទ្រង់សំដែងដល់បុគ្គលនោះ ទើបត្រាស់បទមានជាអាទិ៍ថា ឯវមេវ ខោ (ដូច្នេះដូចគ្នា) ។*

ចប់អដ្ឋកថា នាគសូត្រទី ៩

# អដ្ឋកថា តបុស្សសូត្រទី ១០

## ត្រាស់អនុបុព្វវិហារដល់តបុស្សគហបតី

គប្បីជ្រាបវិនិច្ឆ័យក្នុង តបុស្សសូត្រទី ១០ ដូចតទៅនេះ ៖

[៤១] បទថា **មល្លកេសុ** (ក្នុងដែនមល្ល:) បានដល់ ក្នុងដែនរបស់មល្លក្សត្រ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា នឹងមានការសន្ទនាគ្នារវាងតបុស្សគហបតីជាមួយព្រះអានន្ទនៅក្នុងទីនេះ តថាគតនឹងសំដែងធម្មបរិយាយច្រើន មានរឿងនោះជាហេតុ ទើបត្រាស់ពាក្យនេះថា **ឥធេវ តាវ ត្វំ អានន្ទ ហោហិ** (ម្នាលអានន្ទ អ្នកចូរនៅក្នុងទីនេះសិន) ។ បទថា **ឧបសង្កមិ** (ចូលទៅរក) បានដល់ បានឮថា តបុស្សគហបតីនោះបរិភោគអាហារពេលព្រឹកហើយ គិតថា យើងនឹងទៅគាល់ព្រះទសពល ទើបចេញទៅ ឃើញព្រះថេរៈអំពីចម្ងាយ ទើបចូលទៅរកព្រះអានន្ទដល់ទីនៅ ។

បទថា **បបាតោ វិយ ខាយតិ យទិទំ នេក្ខម្មំ** (នេក្ខម្ម:ទើបប្រាកដ... ដូចអន្លង់) បានដល់ នេក្ខម្ម: ពោលគឺ បព្វជ្ជានេះ ប្រាកដដោយល្អ គឺប្រាកដដល់យើងទាំងឡាយដូចជាអន្លង់ធំ ។ បទថា **នេក្ខម្មេ ចិត្តំ បក្ខន្ទតិ**

(ចិត្ត... រមែងស្ទុះទៅ... ក្នុងនេក្ខម្មៈ) បានដល់ ចិត្តរមែងស្ទុះទៅក្នុងបព្វជ្ជា ដោយអំណាចធ្វើឲ្យជាអារម្មណ៍ រមែងជ្រះថ្លា (បសីទតិ) ព្រោះធ្វើបព្វជ្ជា នោះឯងឲ្យជាអារម្មណ៍ រមែងតាំងមាំ (សន្តិដ្ឋតិ) ក្នុងបព្វជ្ជានោះឯង រមែងរួចផុត (វិមុច្ចតិ) ចាកធម៌ដែលជាសត្រូវទាំងឡាយ ។ បទថា ឯតំ សន្តន្តិ បស្សតោ (ភិក្ខុពិចារណាឃើញថា នេក្ខម្មៈនោះស្ងប់) បានដល់ របស់ភិក្ខុ ដែលឃើញយ៉ាងនេះថា នេក្ខម្មៈនោះស្ងប់ គឺ ប្រាសចាកសេចក្តីខ្វាយខ្វល់ និងសេចក្តីក្តៅក្រហាយ ។ បទថា ពហុនា ជនេន វិសភាគោ (ជាអ្នកតាក់តែងជាមួយជនដ៏ច្រើន) បានដល់ នេក្ខម្មៈនោះ របស់ភិក្ខុទាំងឡាយ មានសេចក្តីផ្សេង គឺ មិនដូចនឹងមហាជនចំណែកច្រើន ។

បទថា កថាបាភតំ (ហេតុនៃការក្រាបទូល) បានដល់ ហេតុដែលនិយាយចចារគ្នា ។ បទថា តស្ស មយ្ហំ អានន្ទ នេក្ខម្មេ ចិត្តំ ន បក្ខន្ទតិ (ចិត្តរបស់យើងនោះ... នៅមិនស្ទុះទៅ... ក្នុងនេក្ខម្មៈ) បានដល់ ចិត្តរបស់យើងសូម្បីត្រិះរិះហើយយ៉ាងនោះ ក៏នៅមិនចុះកាន់ក្នុងបព្វជ្ជា ។ បទថា ឯតំ សន្តន្តិ បស្សតោ (ភិក្ខុពិចារណាឃើញថា នេក្ខម្មៈនោះស្ងប់)

បានដល់ សូម្បីពិចារណាឃើញថា នេក្ខម្មៈនេះស្ងប់ ព្រោះការត្រិះរិះដោយជុំវិញថា នេក្ខម្មៈល្អពិត ។ បទថា **អនាសេវិតោ (នៅមិនទាន់បានសេព)** បានដល់ នៅមិនទាន់សេព គឺ នៅមិនទាន់ពាល់ត្រូវសម្ផស្ស នៅមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ បទថា **អធិគម្ម (សម្រេច)** បានដល់ សូម្បីប៉ះ គឺ សូម្បីធ្វើឲ្យជាក់ច្បាស់ ។ បទថា **តមាសេវេយ្យំ (គប្បីសេពអានិសង្សនោះឲ្យច្រើន)** បានដល់ គប្បីសេព គឺ គប្បីសេពក្នុងអានិសង្សនោះ ។ បទថា **យម្មេ (ដែលចិត្តរបស់យើង)** បានដល់ ព្រោះហេតុដែលចិត្តរបស់យើង ។ បទថា **អធិគម្ម (សម្រេច)** បានដល់ សម្រេចហើយ ។ បទថា **ស្វាស្ស មេ ហោតិ អាពាធោ (ប្រការនោះជាអាពាធរបស់យើង)** បានដល់ ប្រការនោះជាអាពាធរបស់យើង ដោយអត្ថថា បៀតបៀន ។ បទថា **អវិតក្កេ ចិត្តំ ន បក្ខន្ទតិ (ចិត្ត... មិនស្ទុះទៅ... ក្នុងទុតិយឈានដែលមិនមានវិតក្កៈ)** បានដល់ ចិត្តរមែងមិនស្ទុះទៅក្នុងទុតិយឈាន ដែលមិនមានវិតក្កៈមិនមានវិចារៈដោយអំណាចជាអារម្មណ៍ ។ បទថា **វិតក្កេសុ (ក្នុងវិតក្កៈ)** បានដល់ ក្នុងវិតក្កៈ និងវិចារៈ ។ បទដ៏សេសក្នុងទីទាំងពួង

*មានសេចក្ដីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា តបុស្សសូត្រទី ១០

## ចប់មហាវគ្គវណ្ណនាទី ៤

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

# បញ្ចាលវគ្គវណ្ណនាទី ៥

## អដ្ឋកថា បញ្ចាលសូត្រទី ១

### *គាថារបស់បញ្ចាលចណ្ឌទេវបុត្រ*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បញ្ចាលសូត្រទី ១ ដូចតទៅនេះ ៖*

[៤២] *បទថា* ***ឧទាយិ*** *(ព្រះឧទាយី) បានដល់ ព្រះថេរៈឈ្មោះថា កាឡុទាយី ។ បទថា* ***អពុទ្ធា*** *(ទ្រង់បានដឹងហើយ) បានដល់ ទ្រង់បានដឹងទូទៅហើយ ។ បទថា* ***ភូរិមេធសោ*** *(អ្នកមានបញ្ញាធំទូលាយ) បានដល់ មានបញ្ញាច្រើន ។ បទថា* ***យោ ឈានមពុជ្ឈិ ពុទ្ធោ*** *(ព្រះពុទ្ធអង្គណា... បានត្រាស់ដឹងឈានហើយ) បានដល់ ព្រះពុទ្ធអង្គណា បានត្រាស់ដឹងឈាន ។ បទថា* ***បដិលីននិសភោ*** *(ជាអ្នកពួនសម្ងំ និងជាអ្នកប្រសើរ) បានដល់ ជាអ្នកពួនសម្ងំដោយអំណាចការនៅតែម្នាក់ឯង និងជាអ្នកប្រសើរ ដោយអត្ថថា ខ្ពស់បំផុត ។ បទថា* ***មុនិ*** *(ទ្រង់ជាមុនី) បានដល់ ព្រះពុទ្ធមុនី ។ បទថា* ***បរិយាយេន*** *(ដោយបរិយាយ) បានដល់ ដោយហេតុណាមួយ ។ ក៏បឋមឈាន ឈ្មោះថា សម្រេចឱកាសដោយត្រឹម*

តែមិនមានសេចក្ដីចង្អៀតចង្អល់ គឺ កាមប៉ុណ្ណោះ មិនទូទៅទាំងអស់ទេ ។ បទថា **តត្របត្តិ សម្ពាធោ** (សូម្បីក្នុងបឋមឈាននោះ ទីចង្អៀតក៏នៅមាន) បានដល់ សូម្បីបានបឋមឈាននោះ សេចក្ដីចង្អៀតចង្អល់ គឺ ការបៀតបៀន ក៏នៅមាននោះឯង ។ បាលីថា **តត្ថបត្តិ** ដូច្នេះក៏មាន ។ បទថា **កិញ្ច តត្ថ សម្ពាធោ** (អ្វីឈ្មោះថា ទីចង្អៀតក្នុងបឋមឈាននោះ) បានដល់ ក៏ក្នុងឈាននោះ អ្វីឈ្មោះថា ទីចង្អៀត ។ បទថា **អយមេត្ថ សម្ពាធោ** (ឈ្មោះថាទីចង្អៀតក្នុងបឋមឈាននោះ) បានដល់ កាលវិតក្កៈ និងវិចារៈ នៅមិនទាន់រលត់ទៅ នេះឈ្មោះថា ទីចង្អៀត គឺ បៀតបៀនរឿយៗ ។ គប្បីជ្រាបសេចក្ដីក្នុងវារៈទាំងអស់ដោយឧបាយនេះចុះ ។ បទថា **និប្បរិយាយេន** (ដោយនិប្បរិយាយ) បានដល់ ដោយអាការតែមួយក៏មិនមាន ដោយពិត ធម្មតាការអស់ទៅនៃអាសវៈ ឈ្មោះថា ជាការសម្រេចឱកាស ដែលជាឯកទាំងអស់ ព្រោះលះសេចក្ដីចង្អៀតចង្អល់ទាំងអស់បាន ។

ចប់អដ្ឋកថា បញ្ចាលសូត្រទី ១

# អដ្ឋកថា កាយសក្ខិសូត្រទី ២

## កាយសក្ខិបុគ្គល

*គប្បីជ្រាបវិនិច្ឆ័យក្នុង បឋមកាមទេសសូត្រទី ២ ដូចតទៅនេះ ៖*

[៤៣] *បទថា* ***យថា យថា ច តទាយតនំ (និងអាយតនៈ គឺ បឋមឈានទោះមាននៅដោយឱកាសណាៗ)*** *បានដល់ អាយតនៈ គឺ បឋមឈាននោះ រមែងមានដោយហេតុណាៗ គឺ ដោយអាការណាៗ ។ បទថា* ***តថា តថា នំ កាយេន ផុសិត្វា វិហរតិ (លោករមែងពាល់ត្រូវអាយតនៈនោះ ដោយកាយដោយអាការនោះៗ)*** *បានដល់ ភិក្ខុពាល់ត្រូវសមាបត្តិនោះ ដោយសហជាតនាមកាយដោយហេតុនោះៗ គឺ ដោយអាការនោះៗ អធិប្បាយថា ចូលដល់ ។ បទថា* ***កាយសក្ខិ វុត្តោ ភគវតា បរិយាយេន (ដោយបរិយាយ... ព្រះមានព្រះភាគត្រាស់ហៅបុគ្គលថា កាយសក្ខិ)*** *បានដល់ ព្រោះភិក្ខុធ្វើបឋមឈានឲ្យជាក់ច្បាស់ដោយនាមកាយនោះ ដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា កាយសក្ខិដោយបរិយាយនេះ ។ បទថា* ***និប្បរិយាយេន (ដោយនិប្បរិយាយ)*** *បានដល់ វត្ថុមានប្រមាណប៉ុណ្ណា គប្បី*

*ធ្វើឲ្យជាសក្ខី (សាក្សី) ផ្ទាល់កាយ បុគ្គលនេះឈ្មោះថា កាយសក្ខីដោយនិប្បរិយាយ (ដោយត្រង់) ព្រោះបានធ្វើវត្ថុមានប្រមាណប៉ុណ្ណោះ ទាំងអស់ហើយ ។*

ចប់អដ្ឋកថា កាយសក្ខិសូត្រទី ២

# អដ្ឋកថា បញ្ញាវិមុត្តសូត្រទី ៣

## *បុគ្គលរួចផុតដោយបញ្ញា*

*គប្បីជ្រាបវិនិច្ឆ័យក្នុង បញ្ញាវិមុត្តសូត្រទី ៣ ដូចតទៅនេះ ៖*

[៤៤] *បទថា* បញ្ញាយ បន បជានាតិ *(លោករមែងជ្រាបច្បាស់ដោយបញ្ញា) បានដល់ ដឹងអាយតនៈនោះៗ ដោយបឋមឈាន និងវិបស្សនាបញ្ញា ។ សូម្បីក្នុងព្រះសូត្រនេះ គប្បីជ្រាបសេចក្តីជាបរិយាយ និងនិប្បរិយាយ តាមន័យមុននោះឯង ។ ក៏ក្នុងព្រះសូត្រនេះយ៉ាងណា សូម្បីក្នុងសូត្រដទៃអំពីនេះ ក៏យ៉ាងនោះដូចគ្នា ។*

ចប់អដ្ឋកថា បញ្ញាវិមុត្តសូត្រទី ៣

# អដ្ឋកថា ឧភតោភាគវិមុត្តសូត្រទី ៥

## (បុគ្គលរួចផុតដោយចំណែកទាំងពីរ)

*គប្បីជ្រាបវិនិច្ឆ័យក្នុង ឧភតោភាគវិមុត្តសូត្រទី ៥ ដូចតទៅនេះ ៖*

*[៤៥] បទថា **ឧភតោភាគវិមុត្តោ** (បុគ្គលរួចផុតដោយចំណែកទាំងពីរ) បានដល់ ផុតហើយចាកកិលេសដែលជាសត្រូវនៃសមថៈ និងវិបស្សនាដោយចំណែកទាំងពីរ ។ ក្នុងប្រការចុងក្រោយ គប្បីជ្រាបថា ឈ្មោះថា **បុគ្គលរួចផុតដោយចំណែកទាំងពីរ** ព្រោះរួចផុតចាករូបកាយដោយសមាបត្តិ រួចផុតចាកនាមកាយដោយអរិយមគ្គ ។*

ចប់អដ្ឋកថា ឧភតោភាគវិមុត្តសូត្រទី ៥

# បឋមសន្ទិដ្ឋិកសូត្រទី ៥

[៤៦] *ធម៌ដែលបុគ្គលចាក់ធ្លុះគប្បីឃើញខ្លួនឯង*

# ទុតិយសន្ទិដ្ឋិកសូត្រទី ៦

[៤៧] និព្វានដែលបុគ្គលចាក់ធ្លុះគប្បីឃើញខ្លួនឯង

# និព្វានសូត្រទី ៧

[៤៨] *ពោលដោយនិព្វាន*

# បរិនិព្វានសូត្រទី ៨

[៤៩] *ពោលដោយបរិនិព្វាន*

# គន្ធសូត្រទី ៩

[៥០] *ពោលដោយគន្ធនិព្វាន*

# ទិដ្ឋធម្មិកសូត្រទី ១០

[៥១] *ពោលដោយតទង្គនិព្វាន*

# អដ្ឋកថាកែសូត្រចុងក្រោយនាំង ៦ រួមគ្នា

*គប្បីជ្រាបវិនិច្ឆ័យពីបឋមសន្ទិដ្ឋិកសូត្រជាដើម ដូចតទៅនេះ ៖*

*[៤៦-៥១] បទថា **សន្ទិដ្ឋិកោ** (ដែលបុគ្គលសម្រេចនឹងគប្បីឃើញដោយខ្លួនឯង) បានដល់ ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ។ បទថា **និព្វានំ** (និព្វាន) បានដល់ ការរលត់កិលេស ។ បទថា **បរិនិព្វានំ** (បរិនិព្វាន) ជាវេវចនៈរបស់ពាក្យថា **និព្វាន** នោះ ។ បទថា **តទង្គនិព្វានំ** (តទង្គនិព្វាន) បានដល់ និព្វានដោយអង្គឈាននោះ មានបឋមឈានជាដើម ។ បទថា **ទិដ្ឋធម្មនិព្វានំ** (ទិដ្ឋធម្មនិព្វាន) បានដល់ និព្វានក្នុងអត្តភាពនេះនោះឯង ។ បទដ៏សេសក្នុងទីទាំងពួង មានសេចក្តីងាយយល់ហើយ ។*

ចប់អដ្ឋកថានាំង ៦ សូត្រ

## ចប់បញ្ចាលវគ្គវណ្ណនាទី ៥

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១០ សូត្រ

## ចប់បឋមបណ្ណាសកៈ

# ខេមវគ្គវណ្ណនាទី ១

## មាន ១១ សូត្រ

## អដ្ឋកថាកែសេចក្ដីរួមទាំង ១១ សូត្រ

*គប្បីជ្រាបវិនិច្ឆ័យពីខេមសូត្រជាដើម ដូចតទៅនេះ ៖*

[៥២-៦២] *បទថា **ខេមំ** (ខេមៈ) បានដល់ មិនមានអន្តរាយ ។*

*បទថា **ខេមបត្តោ** (ខេមបត្តៈ) បានដល់ ដល់ភាពជាអ្នកមិនមានអន្តរាយ ។*

ចប់អដ្ឋកថាទាំង ១១ សូត្រ

**ចប់ខេមវគ្គវណ្ណនាទី ១**

ក្នុងវគ្គនេះមាន ១១ សូត្រ ព្រះអដ្ឋកថាកែអត្ថ ១១ សូត្រ

# សតិប្បដ្ឋានវគ្គវណ្ណនាទី ២

## អដ្ឋកថា សិក្ខាសូត្រទី ១

*ហេតុជាគ្រឿងធ្វើឲ្យសិក្ខាទុព្វល*

*គប្បីជ្រាបវិនិច្ឆ័យក្នុង សិក្ខាសូត្រទី ១ ដូចតទៅនេះ ៖*

[៦៣] *បទថា សិក្ខាទុព្វល្យានិ (ហេតុជាគ្រឿងធ្វើសិក្ខាឲ្យទុព្វល) បានដល់ ហេតុនៃការអស់កម្លាំងរបស់សិក្ខា ។ ពាក្យដ៏សេសក្នុងទីទាំងពួង មានសេចក្តីងាយទាំងអស់ហើយ ។*

ចប់អដ្ឋកថា សិក្ខាសូត្រទី ១

# អដ្ឋកថា សូត្រទី ២-១០

[៦៤-៧២] *ពីសូត្រទី ២-១០ មិនមានអដ្ឋកថា ។*

## ចប់សតិប្បដ្ឋានវគ្គវណ្ណនាទី ២

ក្នុងវគ្គនេះមាន ១០ សូត្រ ព្រះអដ្ឋកថាកែអត្ថ ០១ សូត្រ

# សម្មប្បធានវគ្គវណ្ណនាទី ៣

# ឥទ្ធិបាទវគ្គវណ្ណនាទី ៤

# និងវគ្គទី ៥

មិនមានអដ្ឋកថាកែសេចក្ដីទេ

# នវកនិបាត ចប់ដោយបរិបូរណ៍

# ចប់អដ្ឋកថា

# អង្គុត្តរនិកាយ នវកនិបាត

# ឈ្មោះ

# មនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| ភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ | |
| សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង | |
| ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |


ព្រះរាជាណាចក្រកម្ពុជា